## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សុំកូន និងការទទួលស្គាល់កូន

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ: **សេខ ស្រីខួ** | លោក **ម៉ៅ មុន្នី** |

| | | |
|---|---|---|
| ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ | ឆ្នាំសិក្សា | ២០១៣ |
| ជំនាន់ទី១៧ | ឆ្នាំសរសេរសារណា | ២០១៧ |

# អារម្ភកថា

ក្នុងនាមនាងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាញនីតិសាស្ត្រ ជំនាន់ទី២២ ក្រុមL4A3 ហើយក៏ជាអ្នករៀបរៀង និង ចងក្រងសៀវភៅនេះឡើង ដែលសិក្សាលំអិតអំពីស៊ុំកូន និងការទទួលស្គាល់ ហើយខ្ញុំក៏ជឿថា សៀវភៅនេះនឹងក្លាយជាឯកសារជំនួយស្មារតីដល់មិត្តអ្នកអានគ្រប់រូបដែលចង់ស្វែងយល់ពីស៊ុំកូន និងការទទួលស្គាល់កូន។ សៀវភៅនេះបានកើតឡើងជាសមិទ្ធផលដោយសារការខិតខំប្រឹងប្រែង ប្រមូលផ្តុំរាល់បណ្តុំឯកសារដែលមានស្រាប់ ដើម្បីយកមកធ្វើជាជំនួយក្នុងការរៀបរៀង ដោយរួមផ្សំ ជាមួយការតាក់តែងឃ្លោងឃ្លា ផ្តុំបានជាអត្ថបទ និងរំលិចឱ្យក្លាយជាសៀវភៅមួយ ដែលមានខ្លឹម សារពេញលេញ។

ការជ្រើសរើសប្រធានបទក្នុងការសរសេរជាសៀវភៅ ជាធាតុដ៏សំខាន់ ក្នុងការទាក់ទាញអ្នក អានឱ្យមានភាពចង់ដឹង និងស្វែងយល់។ ពេលណាអ្នកអាន ចាប់អាន ចំណុចដែលគេត្រូវមើលមុន ដំបូងបង្អស់ គឺប្រធានបទ រួចមកមាតិកានៃខ្លឹមសារក្នុងសៀវភៅ ដែលជាប្រទីបឱ្យគេយល់ពីចំណុច ដែលមាននៅក្នុងសៀវភៅ។

សមិទ្ធផលសម្រេចបាន ក្នុងការចងក្រងសៀវភៅនេះវាជាស្នាដៃរបស់នាងខ្ញុំផ្ទាល់ ដើម្បីរួម ចំណែកការបណ្តុះបណ្តាល ពង្រឹងពុទ្ធិនាងខ្ញុំផ្ទាល់ ក៏ដូចជាមិត្តនិស្សិតអ្នកអានផងដែរ។ នាងខ្ញុំ រង់ ចាំជានិច្ចរាល់ការរិះគន់ដើម្បីស្ថាបនា ពីសំណាក់លោកសាស្ត្រាចារ្យក៏ដូចជាអ្នកអាន ក្នុងទិសដៅកែ លំអស្នាដៃ រាល់ខ្លឹមសារក្នុងសៀវភៅនេះបន្ថែមទៀត ដើម្បីឲ្យស្នាដៃនេះរឹតតែមានភាពពេញលេញ និងសមស្របតាមចំណងជើងរបស់ប្រធានបទនៃសារណាបញ្ចប់ការសិក្សាមួយនេះ។

ជាចុងបញ្ចប់នាងខ្ញុំសូមថ្លែងអំណរគុណលោកសាស្ត្រាចារ្យ **ម៉ៅ បុណ្ណា** ដែលលោកបាន ស្វះស្វែងក្នុងការណែនាំនាងខ្ញុំ និងមិត្តអ្នកអានទាំងអស់ដែលបានយកចិត្តទុកដាក់ក្នុងការអាន ស្នាដៃមួយនេះ ដែលជាស្នាដៃរបស់នាងខ្ញុំ ហើយក៏សូមជូនពរអោយអ្នកទាំងអស់ជួបតែសំណាងល្អ និងមានសុខភាពល្អគ្រប់ៗគ្នា។

# សេចក្ដីថ្លែងអំណរគុណ

ក្នុងនាមនាងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាញនីតិសាស្ត្រ ជំនាន់ទី២២ ក្រុមL4A3 នាងខ្ញុំសូមថ្លែងការដឹងគុណចំពោះអ្នកមានគុណទាំងពីរ ដោយលោកបានផ្ដល់ជីវិតឱ្យនាងខ្ញុំបានកើតមកជាមនុស្សម្នាពេញលក្ខណៈនៅលើទឹកដីសុវណ្ណភូមិដ៏ប្រពៃមួយនេះ និងបានចិញ្ចឹមបីបាច់ អប់រំ ថែរក្សា យ៉ាងយកចិត្តទុកដាក់បំផុត។ លើសពីនេះទៀតលោកទាំងពីរថែមទាំងជាអ្នកផ្ដល់កម្លាំងចិត្ត ដ៏មុតមាំ និងផ្គត់ផ្គង់រូបនាងខ្ញុំគ្រប់បែបយ៉ាងមិនដែលខ្វះខាតឡើយ ជាពិសេសការសិក្សាតាំងពីថ្នាក់មូលដ្ឋាន ដល់ថ្នាក់បរិញ្ញាបត្រនេះ។

បន្ទាប់មកទៀត ក៏សូមអរគុណឯកឧត្តមសាកលវិទ្យាធិការ ថ្នាក់ដឹកនាំសាកលវិទ្យាល័យគ្រប់ជាន់ថ្នាក់ និងសាស្ត្រាចារ្យគ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរួមចំណែកទាំងកម្លាំងកាយចិត្ត និងស្មារតីក្នុងបេសកម្មជួយកសាងធនធានមនុស្ស ដែលប្រកបដោយគុណភាពជូនជាតិមាតុភូមិកម្ពុជាដោយមិនចេះនឿយហត់។ ជាពិសេស នាងខ្ញុំសូមថ្លែងអំណរគុណដល់ **លោកសាស្ត្រាចារ្យ ម៉ៅ បុណ្ណា** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចូលរួមបណ្ដុះបណ្ដាល ក៏ដូចជាណែនាំនាងខ្ញុំយ៉ាងយកចិត្តទុកដាក់ ថែមទាំងលោកពន្យល់ពីវិធីសាស្ត្រក្នុងការសរសេរសារណា ដោយបានផ្ដល់ជាបំណិនថ្មីៗជាច្រើន ដូចជា បំណិនក្នុងការស្រាវជ្រាវឯកសារជំនួយផ្សេងៗ បំណិនក្នុងការអានស្វែងយល់ពីឯកសារច្បាប់ ឬ បទដ្ឋានច្បាប់ផ្សេងៗដែលទាក់ទងនឹងប្រធានបទ ដែលនិយាយពីស៊ុំកូន និងការទទួលស្គាល់កូន គឺធ្វើយ៉ាងណាឱ្យមានភាពទាក់ទាញ ស៊ីជម្រៅ និងលម្អិត ដើម្បីឱ្យអ្នកបានអានងាយស្រួលស្វែងយល់។

ជាចុងបញ្ចប់នាងខ្ញុំសូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យជាខ្លាំងម្ដងទៀត និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន និងគ្រប់ជាន់ថ្នាក់ដែលបានយកចិត្តទុកដាក់ក្នុងការអានសារណាមួយនេះ ដែលជាស្នាដៃរបស់នាងខ្ញុំ ហើយក៏សូមជូនពរអោយអ្នកទាំងអស់គ្នាជួបតែសំណាងល្អ សុខភាពល្អ សុខដុម និងជោគជ័យគ្រប់ៗគ្នា។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១

**ជំពូកទី១**
**សុំកូន**

**ផ្នែកទី១៖ សុំកូនក្នុងស្រុក** ........ ៣
**១.១. សុំកូនពេញលេញ** ........ ៤
**១.១.១. លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ** ........ ៤
**១.១.១.១. លក្ខខណ្ឌសារធាតុ** ........ ៥
ក. លក្ខខណ្ឌចំពោះអ្នកសុំ (ឪពុកម្ដាយចិញ្ចឹម) ........ ៥
ក.១. អាយុ ........ ៥
ក.២. ស្ថានភាពគ្រួសារ ........ ៥
ក.៣. ជីវភាព ........ ៦
ខ. ចំពោះកូនសុំ ........ ៦
ខ.១. អាយុ ........ ៦
ខ.២. ស្ថានភាព ........ ៧
គ. ការយល់ព្រមរបស់ឪពុកម្ដាយបង្កើត ........ ៨
**១.១.១.២. លក្ខខណ្ឌទម្រង់** ........ ៨
ក. ការដាក់ពាក្យសុំ ........ ៨
ខ. អ្នកមានសិទ្ធិដាក់ពាក្យសុំ ........ ៨
គ. ទម្រង់នៃពាក្យសុំ ........ ៩
ឃ. ទីកន្លែងនៃការដាក់ពាក្យសុំ\ ........ ៩
ង. ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ ........ ១០

**១.១.២. អានុភាពនៃសុំកូនពេញលេញ** ........................................ ១០
១.១.២.១. ការបង្កើតញាតិភាពរវាងឪពុកម្តាយចិញ្ចឹម ........................................ ១០
១.១.២.២. ការបញ្ចប់ញាតិភាពរវាងឪពុកម្តាយបង្កើត ........................................ ១០
**១.១.៣. ក្រោយនីតិវិធីនៃការសុំកូន** ........................................ ១១
១.១.៣.១. អំឡុងពេលសាកល្បងចិញ្ចឹម ........................................ ១១
១.១.៣.២. ការចុះបញ្ជី និងការរក្សាការសម្ងាត់នៃសុំកូនពេញលេញ ........................................ ១២
១.១.៣.៣. សិទ្ធិទទួលដឹងអំពីកំណើតខ្លួន ........................................ ១២
**១.១.៤. ការបញ្ចប់ទំនាក់ទំនងសុំកូនពេញលេញ** ........................................ ១៣
១.១.៤.១. ការកាត់កាល់តាមបណ្តឹង ........................................ ១៣
ក. អ្នកមានសិទ្ធិធ្វើបណ្តឹង ........................................ ១៣
ខ. មូលហេតុនៃការកាត់កាល់សុំកូនពេញលេញ ........................................ ១៤
១.១.៤.២. អានុភាពនៃការកាត់កាល់សុំកូនពេញលេញ ........................................ ១៥
**១.២. សុំកូនធម្មតា** ........................................ ១៥
**១.២.១. លក្ខណ្ឌនៃការបង្កើតសុំកូនធម្មតា** ........................................ ១៦
១.២.១.១.លក្ខខណ្ឌសារធាតុ ឬ លក្ខខណ្ឌគ្រឹះ ........................................ ១៦
ក. លក្ខខណ្ឌចំពោះកូន ........................................ ១៦
ក.១. អាយុ ........................................ ១៦
១.២. ស្ថានភាព ........................................ ១៦
ខ. លក្ខខណ្ឌចំពោះអ្នកសុំ ........................................ ១៧
ខ.១. អាយុ ........................................ ១៧
ខ.២. ស្ថានភាព ........................................ ១៧
១.២.១.២. លក្ខខណ្ឌទម្រង់ ........................................ ១៨
ក. ការដាក់ពាក្យសុំ ........................................ ១៨
ខ. អ្នកមានសិទ្ធិដាក់ពាក្យសុំ ........................................ ១៨
គ. ទម្រង់នៃពាក្យសុំ ........................................ ១៩

ឃ. ទីកន្លែងនៃការដាក់ពាក្យសុំ ...... ១៩
ង. ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ...... ១៩
**១.២.២. អានុភាពនៃការសុំកូនធម៌តា ...... ១៩**
១.២.២.១. ការបង្កើតញាតិភាពរវាងឪពុកម្តាយចិញ្ចឹម...... ១៩
១.២.២.២. ការបន្តញាតិភាពរវាងឪពុកម្តាយបង្កើត ...... ១៩
**១.២.៣. ការបញ្ចប់ទំនាក់ទំនងសុំកូនធម៌តា...... ២០**
១.២.៣.១. ការកាត់កាល់តាមការព្រមព្រៀង ...... ២០
១.២.៣.២. ការកាត់កាល់តាមបណ្តឹង...... ២១
១.២.៣.៣. អានុភាពនៃការកាត់កាល់សុំកូនធម្មតា...... ២១
**ផ្នែកទី២៖ សុំកូនអន្តរប្រទេស ...... ២២**
**២.១. និយមន័យ...... ២២**
**២.២. គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស...... ២២**
**២.៣. លក្ខខណ្ឌនៃការបង្កើតសុំកូនអន្តរប្រទេស...... ២៤**
**២.៣.១. លក្ខខណ្ឌគ្រឹះ ឬ លក្ខខណ្ឌសារធាតុ ...... ២៤**
**២.៣.១.១.ចំពោះអ្នកសុំ...... ២៤**
ក. អាយុ ...... ២៤
ខ. ស្ថានភាព...... ២៤
**២.៣.១.២.. ចំពោះកូនសុំ...... ២៥**
ក. អាយុ ...... ២៥
ខ . ស្ថានភាព ...... ២៥
ខ.១. កុមារដែលមានអត្តសញ្ញាណ ...... ២៥
ខ.២. កុមារដែលពុំមានអត្តសញ្ញាណ ...... ២៦
ខ.៣. កុមារកំព្រាដែលមានអ្នកមានអំណាចមេបាក្រលំបាក ......២៧
**២.៣.១.៣. ឪពុកម្តាយបង្កើត ឬអាណាព្យាបាល......២៧**
ក. ការយល់ព្រមរបស់ឪពុកម្តាយបង្កើត ......២៧

ខ. ការបញ្ឈប់ការយល់ព្រមលើសុំកូន ........................................................ ២៨
គ. ការដកហូតអំណាចមេបាពីឪពុកម្តាយបង្កើត .......................................... ២៩
**២.៣.២. លក្ខខណ្ឌទម្រង់** ............................................................................ ២៩
**២.៣.២.១. ការដាក់ពាក្យ** ........................................................................ ២៩
**២.៣.២.២. ទម្រង់នៃពាក្យសុំ** .................................................................... ៣០
**២.៣.២.៣. នីតិវិធីនៃការសុំ** ..................................................................... ៣០
ក. នីតិវិធីរដ្ឋបាល ........................................................................................ ៣០
ក.១. ការគ្រប់គ្រងសំណុំឯកសារ ........................................................... ៣០
ក.២. ការពិនិត្យពាក្យសុំ ......................................................................... ៣១
ក.៣. ការផ្ទៀងផ្ទាត់លក្ខណសម្បត្តិ .......................................................... ៣២
ក.៣.១. ការតបទៅអ្នកសុំ ............................................................... ៣២
ក.៣.២. ការជួប ................................................................................ ៣៣
ក.៣.៣.យោបល់កុមារ ...................................................................... ៣៤
ក.៣.៤. ការសម្រេចលើការសុំ ......................................................... ៣៤
ក.៤. សោហ៊ុយចំពោះរដ្ឋបាលសុំកូនអន្តរប្រទេស ................................. ៣៥
ខ. នីតិវិធីតុលាការ ...................................................................................... ៣៥
ខ.១. ការពិនិត្យសំណុំឯកសារ ............................................................... ៣៥
ខ.២. នីតិវិធីនៃការប្តឹងជំទាស់ ................................................................ ៣៦
ខ.២.១. អ្នកមានសិទ្ធិ ........................................................................ ៣៦
ខ.២.២. រយៈពេល ............................................................................. ៣៦
ខ.២.៣. សមត្ថកិច្ចយុត្តាធិការលើបណ្តឹងជំទាស់ ................................ ៣៦
ខ.៣.សោហ៊ុយក្នុងនីតិវិធីតុលាការ ........................................................... ៣៧
**២.៣.៣. ដំណើរការក្រោយនីតិវិធីសុំ** ..................................................... ៣៧
**២.៣.៣.១. ការប្រគល់កុមារ** ..................................................................... ៣៧
**២.៣.៣.២. ការតាមដានស្ថានភាពកុមារ** ...................................................... ៣៨

២.៣.៣.៣. ការតំកល់សំណុំឯកសារ ........ ៣៨
២.៣.៣.៤. សិទ្ធិដឹងពីកំណើតខ្លួន ........ ៣៩
**២.៣.៤. អានុភាពនៃសុំកូនអន្តរប្រទេស** ........ ៣៩
**២.៣.៥. ការបញ្ចប់ទំនាក់ទំនងសុំកូនអន្តរប្រទេស** ........ ៣៩
**២.៣.៦. ទណ្ឌកម្ម** ........ ៤០

## ជំពូកទី២

## ការទទួលស្គាល់

**ផ្នែកទី១៖ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត** ........ ៤៣
១.១. សមត្ថភាពក្នុងការទទួលស្គាល់កូន ........ ៤៤
១.២. ការទទួលស្គាល់របស់ឪពុក ........ ៤៤
១.២.១. កូនជាអនីតិជន ........ ៤៤
១.២.២. ទារកក្នុងគភ៌ ........ ៤៤
១.២.៣. កូនជានីតិជន ........ ៤៥
១.២.៤. កូនដែលទទួលមរណភាព ........ ៤៥
១.៣. ទម្រង់នៃការទទួលស្គាល់ ........ ៤៦
១.៣.១. ការទទួលស្គាល់ដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ........ ៤៦
១.៣.២. ការទទួលស្គាល់តាមមតកសាសន៍ ........ ៤៦
**ផ្នែកទី២៖ ការទទួលស្គាល់ដោយបង្ខំ** ........ ៤៧
២.១. បណ្តឹងដែលធ្វើឡើងដោយកូន ........ ៤៧
២.២. បណ្តឹងដែលធ្វើឡើងដោយបច្ចាញាតិផ្ទាល់របស់កូន ........ ៤៧
២.៣. បណ្តឹងដែលធ្វើឡើងដោយកូន ឬ បច្ចាញាតិផ្ទាល់របស់កូននោះ (ដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ) ........ ៤៧
២.៤. បណ្តឹងដែលធ្វើឡើងដោយកូន ឬ បច្ចាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ........ ៤៨
២.៥. បណ្តឹងដែលធ្វើឡើងដោយកូនជាជននៅក្រោមអាណាព្យាបាលទូទៅ ........ ៤៨

**ផ្នែកទី៣៖ បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព** ............................ ៥០
**៣.១. បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព**........................................... ៥០
៣.១.១. អ្នកមានសិទ្ធិធ្វើបណ្តឹង ....................................................................... ៥១
៣.១.២. អំឡុងពេលនៃការធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព.. ៥២
**៣.២. អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព** .............................. ៥២
**សេចក្តីសន្និដ្ឋាន** ........................................................................................... ៥៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅក្នុងពិភពលោក ប្រទេសនីមួយៗសុទ្ធតែមានគម្លាតរវាងអ្នកមាន និងអ្នកក្រ។ កង្វះខាតខាងផ្នែកជីវភាព ជាកត្តាចំបង ដែលរាជរដ្ឋាភិបាលនៃប្រទេសនីមួយៗគួរតែយកចិត្តទុកដាក់ ដែលវាក៏ជាកម្លាំងចលករដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ។ ភាពក្រីក្រ អាចកើតឡើងតាមច្រើនទម្រង់ ដែលពេលខ្លះកើតឡើងដោយសារកង្វះការងារ ឬតម្រូវការមានការកើនឡើងខ្ពស់ តែចំណូលបែរជាថតចុះទៅវិញ។ នៅក្នុងសង្គមមួយ កត្តានៃភាពក្រីក្រនឹងធ្វើឱ្យមនុស្សខ្វះនូវអ្វីៗគ្រប់បែបយ៉ាង ជាពិសេសគឺការអប់រំ ដែលជាផ្នែកមួយដ៏សំខាន់របស់មនុស្សគ្រប់គ្នា។ អ្នកដែលទទួលបន្ទុកធ្ងន់ក្នុងគ្រួសារ គឺឪពុកម្តាយ ដែលលោកមានតួនាទីក្នុងការរកចំណូលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ក៏ដូចជាការមើលថែទាំកូនៗរបស់ពួកគេ។ កុមារ គឺជាផ្នែកមួយយ៉ាងសំខាន់បំផុតរបស់សង្គម ដូច្នេះ កុមារត្រូវតែទទួលបានការមើលថែ យកចិត្តទុកដាក់ពីសំណាក់គ្រួសារ ជាពិសេសឪពុកម្តាយនៃកុមារផ្ទាល់។ ក្នុងនោះ កុមារមួយចំនួនបែរជាក្លាយជាបុគ្គលដែលខ្វះភាពកក់ក្តៅ តាមរយៈការខ្ជីខ្ជារបស់ឪពុកម្តាយ ឬក៏មានការប៉ះទង្គិចខាងផ្លូវចិត្ត ដែលកើតឡើងតាមរូបភាពនៃការធ្វើបាបពីសំណាក់ឪពុកម្តាយ។ ដោយសារតែមានបញ្ហាទាំងនេះ ទើបអ្នកច្បាប់ ក៏ដូចជាក្រសួងដែលពាក់ព័ន្ធ បានបង្កើតឱ្យមានរបបសុំកូន ដែលមានគោលដៅជួយដល់កុមារដែលខ្វះខាត និងជួយកាត់បន្ថយក្មេងកំព្រា។ បើយើងមើលក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩៦៧ ក៏បានបញ្ញត្តិអំពីសុំកូននេះ ក្រោយមកក្នុងឆ្នាំ១៩៨៩ យើងក៏មានច្បាប់ពិសេស គឺច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ។ តាមច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ សុំកូនត្រូវបានបញ្ញត្តិចាប់ពីមាត្រា១០៨ ដល់មាត្រា១២២ ដោយរបបសុំកូននេះខុសពីរបបសុំកូនក្នុងក្រមរដ្ឋប្បវេណី ព្រោះថាវាបានបង្កើតឡើងត្រឹមតែកិច្ចសន្យារវាងភាគីប៉ុណ្ណោះ ដោយមិនចាំបាច់ធ្វើតាមផ្លូវតុលាការនោះទេ ប៉ុន្តែក្នុងច្បាប់នេះ មានកម្រិតអំពីចំនួនកូន គឺជាគោលការណ៍មិនឱ្យលើសពីពីរនាក់។ ចំណែកឯក្រមរដ្ឋប្បវេណី ដើម្បីអាចបង្កើតសុំកូនឱ្យមានអានុភាពតាមផ្លូវច្បាប់ លុះត្រាតែធ្វើឡើងតាមផ្លូវតុលាការ តែមិនមានមាត្រាណាមួយកំណត់អំពីចំនួនកូនដែលជាកម្មវត្ថុនៃការសុំឡើយ។ ប៉ុន្តែច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ត្រូវបាននិរាករណ៍ទៅហើយ ហើយសព្វថ្ងៃយើងអនុវត្តតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិអំពីការសុំកូន ហើយក៏បានសិក្សាលំអិត ដោយឈរលើផលប្រយោជន៍របស់កុមារជាចំបង។ ក្នុងនោះរបបសុំកូនត្រូវបានចែកជាពីរ គឺសុំកូនពេញលេញ និងសុំកូនធម្មតា ដែលសុំកូនទាំងពីរ មានគុណសម្បត្តិ និងគុណវិបត្តិមិនដូចគ្នាទេ។ យ៉ាងណាមិញ បើទោះបីជាមានរបបសុំកូនទាំងពីររួចហើយក៏ដោយ ក៏ក្រមរដ្ឋប្បវេណីជាច្បាប់ដែលស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញ ហើយរដ្ឋធម្មនុញ្ញជាច្បាប់ជាតិ ដែលមានវិសាលភាពត្រឹមតែក្នុងប្រទេស

ប៉ុណ្ណោះ។ ដូច្នេះ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់បន្ថែមលើរបបសុំកូនទាំងពីរ ដោយបង្កើតឱ្យមានរបបសុំកូនអន្តរប្រទេស តាមរយៈច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ របបសុំកូនអន្តរប្រទេស បង្កើតឡើងដើម្បីផ្តល់ឱ្យគ្រួសារមួយពេញលេញដល់កុមារ និងអាចជួយសម្រួលបន្ទុកគ្រួសារ ដែលមិនមានលទ្ធភាពក្នុងការបីបាច់ថែរក្សាកូន ហើយវាក៏ជាការបង្កើតឱ្យមានឱកាសថ្មីមួយដល់កុមារដែលវាមានលក្ខណៈល្អជាងការអនុវត្តរបបសុំកូនក្នុងក្រមរដ្ឋប្បវេណី។ ប្រទេសកម្ពុជាយើង បានបង្កើតឱ្យមានរបបសុំកូនអន្តរប្រទេសនេះឡើង ដោយសង្ឃឹមថានឹងអាចមានលទ្ធភាពជួយដល់កុមារដែលជួបផលពិបាកឱ្យបានច្រើន ប៉ុន្តែបែរជាមានការអនុវត្តផ្ទុយពីកម្មវត្ថុនៃសុំកូនអន្តរប្រទេសទៅវិញ ទើបធ្វើឱ្យដំណើរការសុំកូនអន្តរប្រទេសនេះត្រូវផ្អាកក្នុងឆ្នាំ២០០៣។ បន្ទាប់មក ក្នុងឆ្នាំ ២០០៧ រដ្ឋាភិបាល បានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងឡាអេស្តីពី ការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ដើម្បីអាចធានាសុវត្ថិភាពដល់កុមារ ដោយបញ្ចៀសឱ្យបានការជួញដូរកុមារ ។ ក្រោយមក នៅឆ្នាំ២០០៩ រដ្ឋាភិបាលបានបង្កើតឱ្យមានច្បាប់ស្តីពីសុំកូនអន្តរប្រទេស ដែលក្នុងនោះបានបញ្ញត្តិអំពីគោលគំនិតនៃច្បាប់ ដោយរួមបញ្ចូលយ៉ាងលំអិតអំពីនីតិវិធីនៃការសុំកូនអន្តរប្រទេស និងចុងបញ្ចប់នៃច្បាប់បានចែងពីទោសប្បញ្ញត្តិផងដែរ។

សុំកូនអន្តរប្រទេស បានប្រកាសឱ្យប្រើ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ។ សុំកូនអន្តរប្រទេសដាច់ខាតត្រូវតែជាសុំកូនពេញលេញ ដូច្នេះ អានុភាពនៃសុំកូនអន្តរប្រទេសនេះ គឺមានលក្ខណៈដូចគ្នានឹងសុំកូនពេញលេញក្នុងក្រមរដ្ឋប្បវេណីដែរ។

លើសពីនេះទៀត ក្រមរដ្ឋប្បវេណីក៏បានបង្កើតរបបមួយដែលអាចជួយដល់តម្រូវការជាចាំបាច់របស់កុមារ ហើយអាចមានអ្នកមើលថៃ ក៏ដូចជាមានគ្រួសារមួយពេញលេញជូនកុមារ ដែលរបបមួយនោះហៅថា ការទទួលស្គាល់។ ការទទួលស្គាល់ គឺជារបបមួយដែលតម្រូវឱ្យឪពុកធ្វើការទទួលស្គាល់កូនដោយឆន្ទៈរបស់ឪពុកផ្ទាល់ ឬ តាមបណ្តឹងដែលធ្វើដោយអ្នកមានសិទ្ធិ ដើម្បីមានការទទួលស្គាល់។

ដើម្បីឱ្យកាន់តែស៊ីជម្រៅ ដូច្នេះយើងនឹងធ្វើការបកស្រាយ

ជំពូកទី១៖ សុំកូន និង

ជំពូកទី២៖ ការទទួលស្គាល់

## ជំពូកទី១៖ សុំកូន

តាមមាត្រា ៣១៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦៧ ចែងថា សុំកូន គឺជាកិច្ចសន្យាមួយយ៉ាងឱឡារិក ដែលចងបុគ្គលពីរ គឺម្នាក់ហៅថា ឪពុកសុំ ហើយម្នាក់ទៀតហៅថា កូនសុំ ឱ្យមានចំណងទាក់ទងគ្នា ដូចជាបុត្តភាពមានខាន់ស្លាដែរ។

តាមមាត្រា ១០៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ចែងថា សុំកូន គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ហើយម្នាក់តៀតហៅថា កូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នា ដូចជាបុត្តភាពមានខាន់ស្លា។

តាមក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ មិនមានមាត្រាណាមួយចែងពីនិយមន័យនៃសុំកូនទេ ប៉ុន្តែបើយើងឈរលើខ្លឹមសារនៃបញ្ញត្តិដែលចែងពីសុំកូន គឺយើងអាចទាញនិយមន័យបានថា សុំកូន គឺជារបបមួយដែលទទួលស្គាល់ជនដែលគ្មានទំនាក់ទំនងសាច់ញាតិ ឱ្យបង្កើតទំនាក់ទំនងជាឪពុកម្តាយ និងកូន ដូចនឹងឪពុកម្តាយ និងកូនបង្កើតដែរ។មានន័យថា គឺជាការបង្កើតឱ្យមានទំនាក់ទំនងញាតិលោហិតថ្មី ដើម្បីបង្កើតសន្តិជននៃទ្រព្យសម្បត្តិរបស់គ្រួសារចិញ្ចឹម ក៏ដូចជាបន្ថែមកម្លាំងការងារ និងមើលថែរក្សាគ្នាទៅវិញទៅមករវាងឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹម (កូនសុំ) ។

សុំកូនដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងក្នុងក្រមរដ្ឋប្បវេណី គឺសឹងតែដូចគ្នា ប៉ុន្តែច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារចែងត្រឹមតែពាក្យថាសុំកូន ដែលន័យនេះគឺសំដៅដល់សុំកូនពេញលេញដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។

សុំកូនចែកចេញជា ២ប្រភេទ គឺ៖

- សុំកូនក្នុងស្រុក
- សុំកូនអន្តរប្រទេស

### ផ្នែកទី១៖ សុំកូនក្នុងស្រុក

សុំកូនក្នុងស្រុក ឬសុំកូនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី គឺជាទិដ្ឋភាពនៃការសុំរវាងអ្នកសុំដែលមានសញ្ជាតិខ្មែរ ជាមួយកូនសុំដែលមានសសញ្ជាតិខ្មែរ ដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការសុំកូននេះ គឺដើម្បីបង្កើតឱ្យមានអ្នកស្នងត្រកូល ក៏ដូចជាបង្កើតឱ្យមាននូវសន្តតិជន និងកម្លាំងការងារ ជាពិសេសអាចរួមចំណែកក្នុងការកាត់បន្ថយក្មេងកំព្រាផងដែរ។

សុំកូនក្នុងស្រុក ឬ សុំកូនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី មាន ២ប្រភេទ គឺ៖

- សុំកូនពេញលេញ និង
- សុំកូនធម្មតា

ចំពោះរបបសុំកូនពេញលេញ និងសុំកូនធម្មតា វាមានលក្ខខណ្ឌ និងអានុភាពមិនដូចគ្នាទេ។ របបសុំកូនពេញលេញ គឺជារបបសុំកូនដែលមាលក្ខខណ្ឌតឹងតែងជាងរបបសុំកូនធម្មតា ព្រោះថាគេបានកម្រិតពីកម្មវត្ថុនៃសុំកូន ដែលវាមានដូចជា អាយុនៃកូនសុំ អាយុនៃអ្នកសុំ ហើយជាពិសេសភាពមានសហព័ទ្ធ។ យ៉ាងណាមិញ បើនិយាយដល់អានុភាពវិញ របបសុំកូនពេញលេញនឹងបង្កើតឱ្យមានចំណងញាតិលោហិតថ្មី ដោយផ្តាច់ចំណងញាតិលោហិតចាស់ (ឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត)។ រីឯរបបសុំកូនធម្មតាវិញ គឺមិនទាមទារឱ្យកូនសុំផ្តាច់ចំណងញាតិលោហិតជាមួយឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះទេ គឺអនុញ្ញាតឱ្យរក្សាចំណងញាតិពីមុនឱ្យនៅដដែល។

ដើម្បីឱ្យកាន់តែស៊ីជម្រៅលើរបបសុំកូនទាំងពីរខាងលើ ដូច្នេះយើងនឹងសិក្សាលំអិតអំពីសុំកូនពេញលេញ (កថាខណ្ឌទី១) និងសុំកូនធម្មតា (កថាខណ្ឌទី២)។

## ១.១. សុំកូនពេញលេញ

សុំកូនពេញលេញ គឺជាការបង្កើតឱ្យមានទំនាក់ទំនងរវាងឪពុកម្តាយ និងកូន ដូចឪពុកម្តាយ និងកូនបង្កើតដែរ។ ហេតុនេះហើយ ពេលដែលបានបង្កើតសុំកូន ទំនាក់ទំនងរវាងឪពុកម្តាយ និងកូនបង្កើត គឺត្រូវរលត់តាមផ្លូវច្បាប់ ឬ ជាការសុំកូនដែលបង្កើតឱ្យមានទំនាក់ទំនងញាតិលោហិតថ្មី និងបញ្ចប់ទំនាក់ទំនងញាតិលោហិតចាស់។

បានន័យថា កូនសុំត្រូវផ្តាច់រាល់ទំនាក់ទំនងគតិយុត្តទាំងអស់ជាមួយឪពុកម្តាយបង្កើត ហើយត្រូវផ្សារភ្ជាប់ទំនាក់ទំនងគតិយុត្តថ្មីជាមួយឪពុកម្តាយចិញ្ចឹម ឱ្យដូចទៅនឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ។

សុំកូនពេញលេញ ជារបបមួយសម្រាប់ផ្តល់គ្រួសារសុខដុមរមនាមួយ ចំពោះកុមារអភ័ព្វក្នុងគោលបំណងចិញ្ចឹមកូននោះឱ្យមានសុខភាពល្អ ហើយដែលជារបបមួយប្រហាក់ប្រហែលនឹងឪពុកម្តាយបង្កើត។

ម៉្យាងទៀត ចំពោះរបបសុំកូនពេញលេញនេះ បុគ្គលដែលមិនអាចក្លាយទៅជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមបានឡើយ បើសិនជាសហព័ទ្ធម្ខាងទៀតមិនក្លាយជាឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម។

### ១.១.១. លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ

យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដើម្បីឱ្យសុំកូនពេញលេញអាចប្រព្រឹត្តទៅបាន លុះត្រាតែបានបំពេញលក្ខខណ្ឌដែលបានបញ្ញត្តិក្នុងច្បាប់ស្តីពីសុំកូនពេញលេញ ដែលមានលក្ខខណ្ឌធំៗពីរ គឺ លក្ខខណ្ឌសារធាតុ និងលក្ខខណ្ឌទម្រង់។

### **១.១.១.១. លក្ខខណ្ឌសារធាតុ**

លក្ខខណ្ឌសារធាតុ ជាលក្ខខណ្ឌដែលចាំបាច់ដើម្បីឱ្យតុលាការចេញដីកាសម្រេច។

លក្ខខណ្ឌសារធាតុបញ្ញត្តិអំពីលក្ខណសម្បត្តិរបស់ភាគី វត្ថុមានភាគីដែលមានប្រយោជន៍ និងអំឡុងពេលសាកល្បង ។

ដើម្បីសម្រេចឱ្យមានការបង្កើតសុំកូន តុលាការត្រូវពិនិត្យមើល ថាតើស្របនឹងលក្ខខណ្ឌខាងលើដែររទេ?

#### **ក. លក្ខខណ្ឌចំពោះអ្នកសុំ (ឪពុកម្តាយចិញ្ចឹម)**

##### **ក.១. អាយុ**

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ឆ្នាំ ឡើងទៅ ហើយត្រូវមានអាយុច្រើនជាកូនសុំ ២០ឆ្នាំ[1] ។

បើយើងនិយាយដល់អានុភាពនៃសុំកូន លុះត្រាតែមានដីកាសម្រេចស្តីពីការសុំកូនត្រូវបានប្រកាសចាប់ផ្តើមដោយតុលាការ។ ដូច្នេះ ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ឆ្នាំ ឡើងទៅ គឺចង់សំដៅដល់ ការដល់អាយុ ២៥ឆ្នាំ យ៉ាងតិចត្រឹមមានដីកាសម្រេចឱ្យបង្កើតសុំកូនពីតុលាការ។

ម៉្យាងទៀតលក្ខខណ្ឌមួយនេះ គឺតម្រូវឱ្យមានភាពសមស្របរវាងលក្ខខណ្ឌអ្នកដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និងកូនសុំ ដែលអាចឱ្យពួកគេមានគម្លាតអាយុដ៏សមរម្យដូចនឹងឪពុកម្តាយ និងកូនបង្កើតដែរ។ ហេតុនេះចំពោះឪពុកម្តាយចិញ្ចឹម ដែលមានអាយុ ២៥ឆ្នាំ អាចសុំកូនដែលមានអាយុតិចជាង ៥ឆ្នាំ ដែលមានអាយុតិចជាងឪពុកម្តាយចិញ្ចឹម យ៉ាងតិចណាស់ ២០ឆ្នាំ។

##### **ក.២. ស្ថានភាពគ្រួសារ**

បុគ្គលដែលនឹងក្លាយជា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ដាច់ខាតត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ដោយត្រូវមានការសហការ និងឯកភាពគ្នារវាងប្តីប្រពន្ធ។ បើមិនដូច្នេះទេ ប្តី ឬ ប្រពន្ធ តែម្ខាងមិនអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ បើសហព័ទ្ធម្ខាងទៀតមិនមែនជាឪពុក ឬ ម្តាយចិញ្ចឹមនៃកូនសុំនោះ។

ប៉ុន្តែអាចប្រព្រឹត្តទៅបានចំពោះសហព័ទ្ធដែលនឹងក្លាយទៅជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមនៃកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត[2]។

---

[1] មាត្រា១០០៩ នៃច្បាប់ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[2] មាត្រា១០០៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ស្មុំកូនពេញលេញ គឺជាការផ្តល់នូវគ្រួសារដែលមានឪពុកម្តាយ និងមានលំនឹងគ្រប់គ្រាន់ដល់កុមារដែលអភ័ព្វ ដូច្នេះ មាត្រានេះបានបញ្ញត្តិដោយយកគោលការណ៍ស្មុំកូនដោយសហការរវាងប្តីប្រពន្ធ។ ប៉ុន្តែ ក្នុងករណីប្តីប្រពន្ធណាម្ខាងក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ន្ធម្ខាងទៀត ពោលគឺករណីដែលអនាគតកូនចិញ្ចឹមត្រូវជាកូនចុងនោះ ស្មុំកូនមិនចាំបាច់ត្រូវមានការសហការរវាងប្តីប្រពន្ធនោះទេ។

### ក.៣. ជីវភាព

ក្នុងករណីនេះ ជាតួនាទីរបស់តុលាការក្នុងការពិចារណាលើស្ថានភាពរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ថាតើពិតជាមានលក្ខណសម្បត្តិ លទ្ធភាព និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកុមារដែរឬទេ?

មុននឹងចេញសេចក្តីសម្រេចអនុញ្ញាតឱ្យមានការបង្កើតស្មុំកូនពេញលេញ តុលាការត្រូវតែកំណត់ឱ្យឪពុកម្តាយចិញ្ចឹម ធ្វើការចិញ្ចឹមកុមារនោះក្នុងរយៈពេល ៦ខែ (ប្រាំមួយ) ពីព្រោះថាការធ្វើបែបនេះ តុលាការអាចស្ទាបស្ទង់អំពីការរស់នៅរបស់កុមារជាមួយបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានច្បាស់។

### ខ. ចំពោះកូនសុំ

តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ គេអាចសុំកូនបានតែ ២នាក់ប៉ុណ្ណោះ។ បើកូនសុំនោះមានមួយណាស្លាប់ គេអាចសុំកូនម្នាក់ទៀតបាន [3] ។

ផ្ទុយមកវិញ បើយើងមើលទៅក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ វិញ យើងមិនបានឃើញមានមាត្រាណាមួយកំណត់ពីចំនួនកូន នៃស្មុំកូនឡើយ។

ដូច្នេះ បើយើងធៀបច្បាប់ទាំង២ វាលេចឡើងនូវបញ្ហា ថាតើតុលាការនឹងអនុញ្ញាតឱ្យមានការស្មុំកូនបានប៉ុន្មាននាក់ បើច្បាប់ដែលកំពុងអនុវត្តន៍មិនបានចែងដូច្នេះ។

### ខ.១. អាយុ

ជាគោលការណ៍ កូនសុំត្រូវមានអាយុយ៉ាងច្រើន ៨ឆ្នាំ [4] ។

តាមស្មារតីនៃមាត្រានេះ គឺគេបានកម្រិតអាយុកូនសុំ ដោយមិនឱ្យលើសពី ៨ឆ្នាំ នោះទេព្រោះថារបបស្មុំកូនពេញលេញនេះ គឺតម្រូវឱ្យកូនសុំផ្តាច់នូវរាល់ទំនាក់ទំនងទាំងអស់ជាមួយឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ហើយត្រូវបង្កើតចំណងគតិយុត្តមួយថ្មី

---

[3] មាត្រា១១១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។

[4] មាត្រា១០១០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ទៀតជាមួយឪពុកម្តាយចិញ្ចឹម ដោយកូនសុំនោះត្រូវស្ថិតនៅក្រោមការគ្រប់គ្រង មើលថែរក្សា ពីសំណាក់ឪពុកម្តាយចិញ្ចឹមទាំងស្រុង។

ចំពោះចំណុចនេះ បើគេអនុញ្ញាតឱ្យកូនសុំមានអាយុច្រើនពេកនោះ ពេលខ្លះវាអាចនឹងបង្កឱ្យមានផលវិបាកដល់ឪពុកម្តាយចិញ្ចឹម។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មាត្រានេះវាគ្រាន់តែជាគោលការណ៍ប៉ុណ្ណោះ ដូច្នេះយើងក៏អាចបកស្រាយផ្សេងពីនេះផងដែរ ដែលគេអាចបកស្រាយបន្ថែមដោយយោងថា តើបុគ្គលដែលជាអ្នកសុំនោះមានអង្គហេតុស្តីពីការចិញ្ចឹមបីបាច់កុមារនោះ មុនពេលដាក់ពាក្យសុំបង្កើតស្មុំកូននោះដែរឬទេ? ក្នុងករណីនេះ វាក៏ជាចំណុចស្ថិតនៅក្នុងការពិចារណារបស់តុលាការ ថាតើគួរអនុវត្តន៍យ៉ាងណា? បើតាមទិដ្ឋភាពជាក់ស្តែង តុលាការគួរតែអនុញ្ញាតឱ្យបង្កើត បើកូននោះមានអាយុចន្លោះពី ៨ ទៅ ១០ឆ្នាំ យ៉ាងច្រើន។

### ខ.២. ស្ថានភាព

ចំពោះស្ថានភាពកុមារ គេនឹងពិនិត្យទៅលើទិដ្ឋភាពកុមារ ក្នុងករណីកុមារមាន៖

- **ភាពលំបាកខ្លាំង៖** ឪពុកម្តាយកុមារក្រីក្រខ្លាំង ឬ មានជម្ងឺផ្នែកស្មារតីធ្ងន់ធ្ងរ ឬ កំពុងបាត់ខ្លួន ជាអាទិ៍។

- **ការគ្រប់គ្រងកុមារមិនសមរម្យពីសំណាក់ឪពុកម្តាយ៖** អាចនឹងមានការបំពានផ្លូវចិត្ត ឬផ្លូវកាយ តាមរយៈពាក្យសម្តី ឬអាចជាការមិនយកចិត្តទុកដាក់ក្នុងការមើលថែកុមារ។

- **ភាពចាំបាច់ដើម្បីផលប្រយោជន៍កូន៖** អាចឱ្យកុមារមានភាពល្អប្រសើរទាំងផ្លូវចិត្ត និងផ្លូវកាយ និងការផ្គត់ផ្គង់ចាំបាច់ដល់កុមារបានល្អជាងឪពុកម្តាយបង្កើត [5]។

មាត្រានេះ បញ្ញត្តិអំពីមូលដ្ឋានសារធាតុដ៏សំខាន់ ដើម្បីវិនិច្ឆ័យក្នុងករណីដែលតុលាការសម្រេចបង្កើតស្មុំកូន។ តុលាការនឹងពិនិត្យលើចំណុចទាំងនេះ ហើយបើយល់ឃើញថា មិនសមរម្យឱ្យឪពុកម្តាយបង្កើតគ្រប់គ្រងថែរក្សាកូន ដូចជាករណីដែលឪពុកម្តាយបាត់ខ្លួន ឬ មានវិបត្តិផ្នែករាងកាយ ដែលធ្វើឱ្យមានការពិបាកក្នុងការគ្រប់គ្រងថែរក្សាកុមារ ឬ ឪពុកម្តាយដែលធ្វើបាប ឬ បោះបង់កុមារចោល ដោយយល់ឃើញថា ដើម្បីផលប្រយោជន៍កុមារ ចាំបាច់ត្រូវបញ្ចប់ញាតិភាពជាមួយឪពុកម្តាយនោះ ហើយបង្កើតស្មុំកូនជាមួយឪពុកម្តាយចិញ្ចឹម ទើបតុលាការអាចសម្រេចឱ្យបង្កើតស្មុំកូនបាន។

---

[5] មាត្រា១០១២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ៣. ការយល់ព្រមរបស់ឪពុកម្តាយបង្កើត

ដើម្បីអាចបង្កើតស្មុំកូនពេញលេញបាន ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំនោះ ។ ប៉ុន្តែ ក្នុងករណីដែលឪពុកម្តាយបង្កើតរបស់កូនសុំមិនអាចបង្ហាញឆន្ទៈបាន ឬករណីមានការធ្វើបាបដោយឪពុកម្តាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬហេតុផ្សេងទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំធ្ងន់ធ្ងរ [6] ។

ក្នុងករណីដែលមានស្ថានភាពពិបាកនឹងទទួលការយល់ព្រមពីឪពុកម្តាយបង្កើត ឬ ក្នុងករណីដែលមានការជំទាស់របស់ឪពុកម្តាយបង្កើតបំពានយ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍កុមារដែលនឹងក្លាយជាកូនសុំ ការយល់ព្រមពីឪពុកម្តាយបង្កើត មិនចាំបាច់ឡើយ។

ដើម្បីឱ្យការស្មុំកូនអាចសម្រេចទៅបាន ត្រូវមានការព្រមព្រៀងពីឪពុកម្តាយ ឬ អ្នកអាណាព្យាបាលនៃកូនដែលសុំនោះ។ បើជាទារកដែលគេបោះបង់ចោល ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំ ឬសង្កាត់ [7] ។

### ១.១.១.២. លក្ខខណ្ឌទម្រង់

លក្ខខណ្ឌទម្រង់ ជាដំណើរការនីតិវិធីស្មុំកូន។ មានន័យថា ជានីតិវិធីក្នុងការដាក់ពាក្យសុំទៅតុលាការ និងការទទួលដីកាសម្រេចពីតុលាការក្នុងការអនុញ្ញាតឱ្យស្មុំកូន។

### ក. ការដាក់ពាក្យសុំ

បុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយ ត្រូវដាក់ពាក្យសុំបង្កើតស្មុំកូនពេញលេញទៅតុលាការ [8] ។

ការតម្រូវឱ្យឆ្លងកាត់តុលាការ វាជាភាពចាំបាច់ ព្រោះកម្មវត្ថុនៃស្មុំកូនពេញលេញ គឺកំណត់យកអនីតិជន ហើយការកំណត់បែបនេះ ដើម្បីឱ្យមានការស្រាវជ្រាវ និងវិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍របស់កុមារ ។

### ខ. អ្នកមានសិទ្ធិដាក់ពាក្យសុំ

បុគ្គលដែលក្លាយជាឪពុកម្តាយចិញ្ចឹមជាអ្នកមានសិទ្ធិក្នុងការដាក់ពាក្យសុំ ហើយពាក្យសុំនោះត្រូវមានការចូលរួមពីសំណាក់សហព័ទ្ធម្ខាងទៀតផងដែរ។ ប៉ុន្តែ បើក្នុងករណីការយកកូនរបស់

---

[6] មាត្រា១០១១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[7] មាត្រា១១២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។

[8] មាត្រា១០០៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សហព័ទ្ធមកធ្វើជាកូនចិញ្ចឹម បុគ្គលដែលនឹងក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម អាចដាក់ពាក្យតែម្នាក់ឯងបាន [9] ។

### គ. ទម្រង់នៃពាក្យសុំ

តាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនមានបញ្ញត្តិណាមួយបានចែងស្ដីអំពីទម្រង់នៃពាក្យសុំបង្កើតសុំកូនពេញលេញនោះទេ ។ ប៉ុន្តែវាបានបញ្ញត្តិពិសេស នៅក្នុងច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង បានចែងថា៖ [10]

១. ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន

២. នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់បាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ។

៣. ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្ដីថ្លែងការណ៍នូវចំណុចនីមួយៗ នៅចំពោះមុខក្រឡាបញ្ជី។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ។

៤. ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ។

### ឃ. ទីកន្លែងនៃការដាក់ពាក្យសុំ

ពាក្យសុំត្រូវដាក់នៅតុលាការខាងលំនៅឋានរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម (ឧបសម្ព័ន្ធទី៤ ចំណុចទី៧ នៃច្បាប់ស្ដីអំពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

ក្នុងករណីដែលបុគ្គលដែលជាអ្នកសុំ មិនមានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូច្នេះគេនឹងកំណត់យកទីសំណាក់របស់បុគ្គលនោះដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើជាលំនៅឋាន [11] ។

[9] មាត្រា១០០៧ និងមាត្រា១០០៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[10] មាត្រា២៦ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង ឆ្នាំ២០១១។

[11] មាត្រា៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ខ. ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ

តាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥០០០(ប្រាំពាន់) រៀល [12] ។

## ១.១.២. អានុភាពនៃសុំកូនពេញលេញ

សុំកូនលេញលេញនឹងមានអានុភាពតាមផ្លូវច្បាប់ លុះត្រាតែវាបង្កើតឡើងតាមផ្លូវច្បាប់ ដោយត្រូវឆ្លងកាត់តាមផ្លូវតុលាការ ។ នៅពេលដែលមានដីកាសម្រេចអនុញ្ញាតឱ្យបង្កើតសុំកូន នោះអានុភាពនៃសុំកូនពេញលេញនឹងលេចឡើងនូវរូបភាព ២យ៉ាង គឺៈ

### ១.១.២.១. ការបង្កើតញាតិភាពរវាងឪពុកម្តាយចិញ្ចឹម

ទំនាក់ទំនងឪពុកម្តាយ និងកូនតាមច្បាប់ ត្រូវបានបង្កើតឡើងរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំចាប់ពីបង្កើតសុំកូន (ដីកាសម្រេចបង្កើតឱ្យសុំកូនចូលជាស្ថាពរ) ហើយទំនាក់ទំនងញាតិភាពរវាងកូនសុំជាមួយនឹងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមដែលដូចគ្នាទៅនឹងទំនាក់ទំនងញាតិលោហិតតាំងពីកំណើត ក៏ត្រូវកើតឡើងដែរ។ កូនសុំមានឋានៈដូចគ្នានឹងកូនបង្កើត ទទួលបានសិទ្ធិ និងករណីកិច្ចដូចនឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម ហើយកូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនរបស់ខ្លួនបាន [13] ។ កូនសុំ ត្រូវស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម [14] ។ ប៉ុន្តែក្នុងករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬម្តាយចិញ្ចឹមរបស់កូនបង្កើតរបស់សហាព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬម្តាយបង្កើត និងឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម [15] ។

### ១.១.២.២. ការបញ្ចប់ញាតិភាពរវាងឪពុកម្តាយបង្កើត

ក្រោយបង្កើតសុំកូនពេញលេញ ញាតិភាពជាមួយឪពុកម្តាយបង្កើត ត្រូវបានបញ្ចប់ មានន័យថា ឪពុកម្តាយ និងកូនបង្កើតក្លាយជាអ្នកដទៃលែងជាប់សាច់ឈាមនឹងគ្នា ហើយញាតិលោហិតរបស់ឪពុកម្តាយបង្កើតក៏ត្រូវបញ្ចប់ដែរ លើកលែងតែកូនសុំជាកូនរបស់សហាព័ទ្ធម្ខាងទៀត [16] ។ ហេតុនេះ សិទ្ធិធ្វើសន្តតិកម្មចំពោះគ្នាទៅវិញទៅមកត្រូវបានបាត់បង់ និងមិនអាចទទួលកាតព្វកិច្ចទៅវិញទៅមកបានទៀតទេ ហើយឪពុកម្តាយបង្កើតក៏ពុំមានសិទ្ធិសួរសុខទុក្ខកូនដែរ។

---

[12] មាត្រា២២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១១។
[13] មាត្រា១០២៥ កថាខណ្ឌទី១ និងទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[14] មាត្រា១០១៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ និងមាត្រា១០៣៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។
[15] មាត្រា១០១៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[16] មាត្រា១០១៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ការកំណត់បែបនេះ ដោយហេតុថា គោលការណ៍នៃការបង្កើតសុំកូនពេញលេញ គឺបង្កើតញាតិថ្មីមួយនៅក្នុងមជ្ឈដ្ឋាននៃគ្រួសាររបស់ឪពុកម្ដាយចិញ្ចឹមដែលមានស្ថេរភាពល្អ ហើយកូនសុំតត្រូវស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់ឪពុកម្ដាយចិញ្ចឹម ហេតុនេះដើម្បីជៀសវាងការរំខាន ឬ ជ្រៀតជ្រែកដោយមិនសមរម្យរបស់ឪពុកម្ដាយបង្កើត ត្រូវតែបញ្ចប់ទំនាក់ទំនងជាមួយឪពុកម្ដាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើត។ ម្យ៉ាងវិញទៀត ការបង្កើតសុំកូនពេញលេញ កុមារនឹងត្រូវរស់ក្នុងមជ្ឈដ្ឋានថ្មីនៃគ្រួសារឪពុកម្ដាយចិញ្ចឹម ហេតុនេះ ការគិតថា ឪពុកម្ដាយចិញ្ចឹម គឺជាឪពុកម្ដាយបង្កើតរបស់ខ្លួន គឺជាភាពចាំបាច់ដើម្បីឱ្យទំនាក់ទំនងរវាងឪពុកម្ដាយចិញ្ចឹម នុងកូនសុំមានភាពសុខដុមរមនានឹងគ្នា ការបញ្ចប់ញាតិភាពជាមួយឪពុកម្ដាយបង្កើត គឺជាមូលដ្ឋានសមរម្យ។ ទោះបីជាទំនាក់ទំនងញាតិនេះ ត្រូវបញ្ចប់ដោយការកំណត់របស់ច្បាប់ក៏ដោយ ប៉ុន្តែញាតិភាពជាមួយឪពុកម្ដាយបង្កើត និងញាតិភាពជាមួយញាតិលោហិតរបស់ឪពុកម្ដាយបង្កើត វាជាឈាមជ័រតាមធម្មជាតិ ហេតុនេះ ការហាមឃាត់រៀអាពាហ៍ពិពាហ៍ជាមួយញាតិលោហិតនៅតែបន្ត [17] ។

**សំគាល់៖** ចំពោះអានុភាពនៃសុំកូនពេញលេញ ដែលមានវិការៈនៅអំឡុងពេលដាក់ពាក្យសុំ បើសិនជាតុលាការ បានចេញដីកាសម្រេចឱ្យបង្កើតសុំកូនពេញលេញ ហើយដីកានោះបានចូលជាស្ថាពរ ក៏អានុភាពនៃសុំកូនត្រូវបានបង្កើតឡើងដដែល។

### ១.១.៣. ក្រោយនីតិវិធីនៃការសុំកូន

#### ១.១.៣.១. អំឡុងពេលសាកល្បងចិញ្ចឹម

ហេតុអ្វីចាំបាច់បង្កើតឱ្យមានអំឡុងពេលសាកល្បងចិញ្ចឹម? ហើយគេអនុវត្តយ៉ាងដូចម្ដេច?

អំឡុងពេលសាកល្បង គឺជារយៈពេលដែលតុលាការបានកំណត់ ដើម្បីឈានដល់ការសម្រេចសេចក្ដីក្នុងការបង្កើតសុំកូនពេញលេញ ដែលវាអាចឱ្យតុលាការធ្វើការពិចារណាមុននឹងវិនិច្ឆ័យ អំពីភាពអាច ឬ មិនអាច ក្នុងការបង្កើតសុំកូនពេញលេញ។

ពិចារណាទៅលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦(ប្រាំមួយ) ខែ [18] ។

បើតាមស្មារតីនៃមាត្រានេះ មានន័យថា អំឡុងពេលសាកល្បងនឹងចាប់អនុវត្តក្រោយពេលអ្នកសុំបានដាក់ពាក្យសុំបង្កើតសុំកូនទៅតុលាការ មិនមែនកើតឡើងមុនការដាក់ពាក្យសុំទៅតុលាការនោះទេ។ ការបង្កើតអំឡុងពេលសាកល្បងចិញ្ចឹម ដើម្បីពិនិត្យថា តើឪពុកម្ដាយចិញ្ចឹមមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងថែរក្សាកុមារដែរឬទេ? ហើយតើអាចបង្កើតទំនាក់ទំនងល្អ

[17] មាត្រា៩៥១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[18] មាត្រា១០១៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ជាមួយកូនសុំដែរឬទេ? ឬថា តើមានភាពចុះសម្រុងគ្នារវាងកូនសុំ និងឪពុកម្ដាយចិញ្ចឹមដែរឬយ៉ាងណា?

### ១.១.៣.២. ការចុះបញ្ជី និងការរក្សាការសម្ងាត់នៃសុំកូនពេញលេញ

ប្រសិនបើបានបង្កើតសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្ដីសម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្ដីពីសុំកូនឡើយ [19] ។

បើកាលណាមានការបង្ហាញនូវអង្គហេតុនៃសុំកូន អាចបំពានភាពឯកជន ហើយផ្ដល់ផលអាក្រក់ដល់ការចម្រើនលូតលាស់ដ៏ល្អរបស់កុមារ។ ម្យ៉ាងទៀត បើមានការបង្ហាញចំណុចសុំកូននៅក្នុងសំបុត្រកំណើត ឬ សេចក្ដីសម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត នោះនឹងនាំឱ្យមានហានិភ័យ ដូចជា ការជ្រៀតជ្រែកពីសំណាក់ឪពុកម្ដាយបង្កើត ដែលវានឹងនាំមកនូវផលអវិជ្ជមានចំពោះគ្រួសារកូនសុំ ក៏ដូចជាកូនសុំផ្ទាល់។ ការធ្វើបញ្ជីកំណើតថ្មីឱ្យកូនសុំ ត្រូវចុះថា ឪពុកម្ដាយចិញ្ចឹម គឺជាឪពុកម្ដាយបង្កើត។

### ១.១.៣.៣. សិទ្ធិទទួលដឹងអំពីកំណើតខ្លួន

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្ដីពីសុំកូនបាន។ ចំពោះការរក្សាទុកសំណុំរឿង និងវិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិរបស់តុលាការ [20] ។

តាមស្មារតីនៃមាត្រានេះ គឺមិនបានកំណត់ឱ្យមានការយល់ព្រមពីឪពុកម្ដាយបង្កើតឡើយ។

បើតាមមាត្រានេះ តើពាក្យថាក្នុងទំហំដែលចាំបាច់មានន័យយ៉ាងណា?

ក្នុងករណីនេះ ពាក្យថាក្នុងទំហំដែលចាំបាច់ គឺសំដៅដល់ភាពចាំបាច់ក្នុងការព្យាបាលជម្ងឺរបស់កូនសុំដែលបានដល់នីតិភាព ការរៀបអាពាហ៍ពិពាហ៍ ជាអាទិ៍។

## ១.១.៤. ការបញ្ចប់ទំនាក់ទំនងសុំកូនពេញលេញ

បើទោះបីជាមិនមែនជាកូនបង្កើត ក៏សុំកូនពេញលេញបានបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំ ឱ្យដូចទៅនឹងកូនបង្កើត។ ដូច្នេះចំណងមួយនេះនឹងមិនអាចបញ្ចប់ដោយងាយស្រួលបានឡើយ។ បើទោះបីជាច្បាប់បានកំណត់ថាកូននោះជាកូនបង្កើតក៏ដោយ ក៏ធាតុពិតមិន

[19] មាត្រា១០១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[20] មាត្រា១០១៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

មែនជាកូនបង្កើតនៃឪពុកម្តាយចិញ្ចឹមនោះទេ ដោយហេតុដូច្នេះ ច្បាប់ក៏បានបញ្ញតិអំពីការបញ្ចប់ស្មុំកូនដែលអាចធ្វើតាមរយៈការកាត់កាល់។

នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនបានឱ្យនិយមន័យនៃពាក្យការកាត់កាល់ទេ ប៉ុន្តែបើយោងតាមវចនានុក្រមរបស់សម្តេចសង្ឃរាជ **ជួន ណាត** បានឱ្យនិយមន័យថា ការកាត់កាល់ គឺជាការបោះបង់លែងរាប់អានតទៅទៀត។ ដូច្នេះយើងអាចទាញន័យបានថា ការកាត់កាល់ គឺជាស្ថានភាពមួយដែលបញ្ចប់ទំនាក់ទំនងញាតិឱ្យលែងមានតទៅទៀតរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ។

ចំពោះការកាត់កាល់ គឺត្រូវធ្វើឡើងតាមរយៈបណ្តឹងទាមទារឱ្យកាត់កាល់ ដែលត្រូវធ្វើឡើងតាមផ្លូវតុលាការ។ ចំពោះសេចក្តីសម្រេចអំពីការកាត់កាល់ត្រូវអនុលោមតាមច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល [21] ។

### ១.១.៤.១. ការកាត់កាល់តាមបណ្តឹង

#### ក. អ្នកមានសិទ្ធិធ្វើបណ្តឹង

ចំពោះស្មុំកូនពេញលេញ អ្នកដែលមានសិទ្ធិប្តឹងទាមទារឱ្យមានការកាត់កាល់ មានតែកូនសុំ ឪពុកម្តាយបង្កើត ឬ តំណាងអយ្យការ [22] ។ មានន័យថា កូនសុំ ឪពុកម្តាយបង្កើត ឬ តំណាងអយ្យការ ទើបអាចមានសិទ្ធិដាក់ពាក្យសុំកាត់កាល់ស្មុំកូនពេញលេញបាន ឪពុកម្តាយចិញ្ចឹមមិនអាចដាក់ពាក្យសុំឱ្យកាត់កាល់កូនសុំបាននោះទេ ព្រោះថា ស្មុំកូនពេញលេញ គឺបង្កើតឡើងដើម្បីផលប្រយោជន៍កូន។

ក្នុងករណីកូនសុំជាដើមបណ្តឹង នោះឪពុកម្តាយចិញ្ចឹមជាចុងចម្លើយ [23] ។

ក្នុងករណីឪពុកម្តាយបង្កើតជាដើមបណ្តឹង នោះឪពុកម្តាយចិញ្ចឹម និងកូនសុំ ជាចុងចម្លើយ [24]។

ក្នុងករណីតំណាងអយ្យការជាដើមបណ្តឹង នោះឪពុកម្តាយចិញ្ចឹមជាចុងចម្លើយ [24] ។

---

[21] មាត្រា៣ ចំណុច ជ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១។

[22] មាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[23] មាត្រា៧ ចំណុច១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១។

[24] មាត្រា៧ ចំណុច២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១។

## ខ. មូលហេតុនៃការកាត់កាល់ស្មុំកូនពេញលេញ

លក្ខខណ្ឌដែលនាំឱ្យមានការកាត់កាល់ រួមមាន៖ [22]

- ការបំពានផលប្រយោជន៍កូនសុំ៖ បើមានការធ្វើបាបដោយឪពុកម្តាយ បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ មូលហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ។
- លទ្ធភាពនៃឪពុកម្តាយបង្កើត៖ ឪពុកម្តាយអាចគ្រប់គ្រងថែរក្សាកូនដោយសមរម្យ។

ផ្អែកតាមមូលហេតុទាំងពីរ ទើបអាចនាំឱ្យមានការកាត់កាល់ស្មុំកូនពេញលេញ ដូច្នេះយើងនឹងលើកយកបញ្ហាមួយចំនួនដែលបានលេចឡើងនៅចន្លោះលក្ខខណ្ឌទាំងពីរនេះដែលវាអាចជា៖

- បើក្នុងករណីកូនសុំត្រូវបានទទួលការធ្វើបាបពីសំណាក់ឪពុកម្តាយចិញ្ចឹម ហើយក្នុងស្ថានភាពនោះ ឪពុកម្តាយបង្កើតក៏មិនមានលទ្ធភាពក្នុងការចិញ្ចឹមកូនបាន តើតុលាការគួរអនុញ្ញាតឱ្យកូនសុំ ធ្វើការកាត់កាល់ឪពុកម្តាយចិញ្ចឹមនោះដែរឬទេ?

ក្នុងករណីនេះ លក្ខខណ្ឌទី២ នៃការកាត់កាល់ស្មុំកូនពេញលេញ មិនត្រូវបានបំពេញនោះទេ។ ដូច្នេះ ដើម្បីឱ្យស្របបតាមមាត្រា ១០១៦ នោះតុលាការមិនគួរអនុញ្ញាតឱ្យកូនសុំ ធ្វើការកាត់កាល់ឪពុកម្តាយចិញ្ចឹមទេ។ យ៉ាងណាមិញ ស្មុំកូនបង្កើតឡើងដើម្បីផលប្រយោជន៍កូនសុំ តែបែរជាមានការបំពានផលប្រយោជន៍កូនសុំទៅវិញ ដោយការធ្វើបាបពីសំណាក់ឪពុកម្តាយចិញ្ចឹមនោះ ដើម្បីអាចជួយសង្គ្រោះដល់កុមារ យើងគួរតែសុំឱ្យតុលាការ ធ្វើការព្យួរ ឬដកហូតអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ដែលអ្នកដែលអាចទាមទារទៅតុលាការឱ្យធ្វើការព្យួរ ឬ ដកហូតអំណាចមេបា មានញាតិក្នុង ៤ថ្នាក់របស់កូនសុំ មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារៈណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន [25] ។

- បើក្នុងករណីឪពុកម្តាយចិញ្ចឹមមិនបានធ្វើបាបកូនសុំនោះទេ ប៉ុន្តែមិនមានលទ្ធភាពក្នុងការចិញ្ចឹមបីបាច់កូនសុំបន្ត ហើយឪពុកម្តាយបង្កើតរបស់កូនសុំ គឺស្ថិតក្នុងស្ថានភាពដែលអាចចិញ្ចឹមកូនបាន តើតុលាការគួរអនុញ្ញាតឱ្យកូនសុំ ធ្វើការកាត់កាល់ឪពុកម្តាយចិញ្ចឹមនោះដែរឬទេ?

ក្នុងករណីនេះ គឺមិនបានបំពេញតាមលក្ខខណ្ឌដែលបានចែងក្នុងមាត្រា ១០១៦នោះទេ ដូច្នេះតុលាការក៏មិនអាចអនុញ្ញាតឱ្យកូនសុំធ្វើការកាត់កាល់ឪពុកម្តាយចិញ្ចឹមនោះបានឡើយ។

[25] មាត្រា១០៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ប៉ុន្តែតុលាការផ្តល់សិទ្ធិដល់ឪពុកម្តាយចិញ្ចឹម ដោយឱ្យគាត់មានសិទ្ធិក្នុងការលាឈប់ពីអ្នកមានអំណាចមេបា[26] ។

- បើក្នុងករណីកូនសុំជាជនដែលសាហាវឃោរឃៅ បានវាយដំឪពុកម្តាយចិញ្ចឹម តើតុលាការគួរអនុញ្ញាតឱ្យឪពុកម្តាយចិញ្ចឹម ធ្វើការកាត់កាល់កូនសុំបានដែរឬទេ?

ក្នុងករណីនេះ តុលាការមិនអាចអនុញ្ញាតឱ្យឪពុកម្តាយចិញ្ចឹម ធ្វើការកាត់កាល់កូនសុំនោះទេ ព្រោះថាការកាត់កាល់ធ្វើឡើងបានតែកូនសុំ ចំពោះឪពុកម្តាយចិញ្ចឹមតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ កាលណាមានបញ្ហា គឺត្រូវតែមានដំណោះស្រាយ។ តាមក្រមរដ្ឋប្បវេណី បើទោះបីជាឪពុកម្តាយចិញ្ចឹមមិនអាចកាត់កាល់កូនបាន ប៉ុន្តែ ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យទៅតុលាការ ដើម្បីលាឈប់ពីអ្នកមានអំណាចមេបា[27] ។

### ១.១.៤.២. អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ដោយសុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់[28] ។

មាត្រានេះអនុម័តយកទស្សនៈនៃការបង្កើតឡើងវិញដោយស្វ័យប្រវត្តិនូវញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ដែលត្រូវបានបញ្ចប់ដោយការបង្កើតសុំកូន នៅពេលដែលសុំកូនពេញលេញត្រូវបានរំលាយដោយការកាត់កាល់ ហើយការទទួលស្គាល់ដោយស្វ័យប្រវត្តិនេះ គិតចាប់ពីថ្ងៃកាត់កាល់នោះតែម្តង។

## ១.២. សុំកូនធម្មតា

សុំកូនធម្មតា ឬ សុំកូនសាមញ្ញ គឺជាការសុំកុមារដែលបង្កើតឱ្យមានទំនាក់ទំនងញាតិលោហិតថ្មី និងបន្តទំនាក់ទំនងញាតិលោហិតចាស់។

មានន័យថា ជារបបមួយដែលបង្កើតឱ្យមានចំណងញាតិលោហិតថ្មី តាមរយៈឪពុកម្តាយចិញ្ចឹម ប៉ុន្តែមិនបានតម្រូវឱ្យកាត់ផ្តាច់ចំណងញាតិចាស់ជាមួយឪពុកម្តាយបង្កើត និងសាច់ញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះឡើយ។ យ៉ាងណាមិញ របបសុំកូននេះ ត្រូវបង្កើតឡើយតាមផ្លូវតុលាការ ព្រោះដើម្បីបង្កើតអានុភាពញាតិលោហិតទៅតាមផ្លូវច្បាប់ ដោយអាចរក្សាបាននូវផលប្រយោជន៍ដូចជា សន្តតិកម្ម និងអាហារកិច្ច ជាអាទិ៍។

---

[26] មាត្រា១០៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[27] មាត្រា១០៥០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[28] មាត្រា១០១៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ១.២.១. លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា

យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដើម្បីឱ្យសុំកូនពេញលេញអាចប្រព្រឹត្តទៅបាន លុះត្រាតែបានបំពេញលក្ខខណ្ឌដែលបានបញ្ញត្តិក្នុងច្បាប់ស្តីពីសុំកូនពេញលេញ ដែលមានលក្ខខណ្ឌធំៗពីរ គឺ លក្ខខណ្ឌសារធាតុ និងលក្ខខណ្ឌទម្រង់។

#### ១.២.១.១. លក្ខខណ្ឌសារធាតុ ឬលក្ខខណ្ឌគ្រឹះ

លក្ខខណ្ឌសារធាតុ ជាលក្ខខណ្ឌដែលចាំបាច់ដើម្បីឱ្យតុលាការចេញដីកាសម្រេច។ លក្ខខណ្ឌទាំងនោះមានដូចជា៖

##### ក. លក្ខខណ្ឌចំពោះកូន

##### ក.១. អាយុ

អាយុរបស់កូនសុំពុំត្រូវបានកំណត់ឡើយ។ ប៉ុន្តែបុគ្គលដែលនឹងក្លាយទៅជាកូនសុំ មិនអាចជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ [29] ។

កូនសុំអាចជាអនីតិជន ឬ នីតិជន ដោយមិនកម្រិតអាយុឡើយ លើកលែងតែបុគ្គលដែលជាកូនសុំមានអាយុច្រើនជាងឪពុកម្តាយចិញ្ចឹម ឬ ជាបុព្វញាតិរបស់ឪពុកម្តាយចិញ្ចឹម។

##### ក.២. ស្ថានភាព

តុលាការអាចបង្កើតសុំកូនធម្មតាបាន លុះត្រាតែមានការបង្ហាញឆន្ទៈពិតប្រាកដរបស់ភាគីក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។ បើតុលាការយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ គោលបំណងមិនត្រឹមត្រូវផ្សេងទៀត សុំកូននឹងមិនអាចបង្កើតបានឡើយ។

បើបុគ្គលដែលជាកូនសុំ ជាអនីតិជន នោះតុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍អនីតិជននោះ ដោយមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ហើយអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវដាក់ពាក្យសុំទៅតុលាការជាមួយអ្នកសុំ។ បើឪពុកម្តាយរបស់អនីតិជននោះបានលែងលះគ្នា តុលាការត្រូវសួរយោបល់របស់ឪពុក ឬម្តាយដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យ។

[29] មាត្រា១០២០ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

បើបុគ្គលជាកូនសុំ ជាអនីតិជនមានអាយុដល់ ១៥ឆ្នាំ គឺចាំបាច់ត្រូវមានការយល់ព្រមពីអនីតិជននោះ។ ប៉ុន្តែបើទោះបីជាបុគ្គលដែលជាកូនសុំ ជាអនីតិជនមិនទាន់ដល់អាយុ ១៥ឆ្នាំក៏ដោយ តែបុគ្គលដែលជាកូនសុំនោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន គឺតុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យ [30] ។

បើបុគ្គលដែលជាកូនសុំ ជានីតិជន បុគ្គលនោះមានសិទ្ធិដាក់ពាក្យសុំកូនធម្មតាដោយខ្លួនឯង ហើយតុលាការនឹងចេញដីកាសម្រេចឱ្យបង្កើតទំនាក់ទំនងញាតិលោហិតជាមួយអ្នកសុំ ដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម។

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនដាក់ពាក្យសុំបង្កើតសុំកូន ដោយយកអនីតិជនដែលនៅក្រោមការមើលថែរបស់ខ្លួនមកធ្វើជាកូនសុំ ឬ ករណីដែលអាណាព្យាបាលទូទៅអាចដាក់ពាក្យសុំបង្កើតសុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវក្នុងការគ្រប់គ្រងថែរក្សា និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ។

### ខ. លក្ខខណ្ឌចំពោះអ្នកសុំ

#### ខ.១. អាយុ

បុគ្គលដែលក្លាយទៅជាឪពុកម្តាយចិញ្ចឹមត្រូវតែមានអាយុ ២៥ (ម្ភៃប្រាំ)ឆ្នាំឡើងទៅ ហើយមិនត្រូវជាបច្ឆាញាតិ និងត្រូវមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាកូនសុំ [31] ។

មានន័យថា អាយុរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមត្រូវបានកម្រិត ដោយឱ្យមានអាយុចាប់ពី ២៥ឆ្នាំឡើងទៅ ។

#### ខ.២. ស្ថានភាព

បុគ្គលដែលនឹងក្លាយជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមអាចជាបុគ្គលដែលមានសហព័ទ្ធហើយ ឬក៏បុគ្គលដែលមិនទាន់មានសហព័ទ្ធក៏បាន។

ចំពោះបុគ្គលលដែលមានសហព័ទ្ធ គឺចាំបាច់ត្រូវមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ទើបអាចដាក់ពាក្យសុំបាន។

ចំពោះកូនសុំជានីតិជន ករណីដែលមានសហព័ទ្ធតែម្ខាងជាអ្នកដាក់ពាក្យសុំកូនធម្មតា នោះកូនសុំមានអានុភាពចំពោះតែអ្នកដែលបានដាក់ពាក្យសុំតែប៉ុណ្ណោះ។

---

[30] មាត្រា២០២៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[31] មាត្រា១០២០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ចំពោះកូនសុំជាអនីតិជន បុគ្គលដែលមានសហព័ទ្ធ គឺត្រូវដាក់ពាក្យសុំដោយសហការគ្នា [32] ។ ប៉ុន្តែបើក្នុងករណីការយកកូនរបស់សហព័ទ្ធមកធ្វើជាកូន ឬ បើសហព័ទ្ធមិនអាចបង្ហាញឆន្ទៈបាន ដោយហេតុដូចករណីមានជម្ងឺផ្នែកស្មារតី ជាអាទិ៍ នោះការដាក់ពាក្យសុំបង្កើតសុំកូនធម្មតាអាចធ្វើបានបើទោះបីជាមិនមានការបង្ហាញឆន្ទៈរបស់សហព័ទ្ធម្ខាងទៀតក៏ដោយ [33] ។

### ១.២.១.២. លក្ខខណ្ឌទម្រង់

លក្ខខណ្ឌទម្រង់ ជានីតិវិធីក្នុងការដាក់ពាក្យសុំទៅតុលាការក្នុងការសុំកូន និងការទទួលដីកាសម្រេចពីតុលាការក្នុងការអនុញ្ញាតឱ្យសុំកូន។

#### ក. ការដាក់ពាក្យសុំ

បុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយ ត្រូវដាក់ពាក្យសុំបង្កើតសុំកូនធម្មតាទៅតុលាការ ។

ការតម្រូវឱ្យឆ្លងកាត់តុលាការ វាជាភាពចាំបាច់ ព្រោះកម្មវត្ថុនៃសុំកូនធម្មតា អាចជានីតិជន ឬ អនីតិជន ហើយការកំណត់បែបនេះ ដើម្បីឱ្យមានការស្រាវជ្រាវ និងវិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍របស់កុមារ ។

#### ខ. អ្នកមានសិទ្ធិដាក់ពាក្យសុំ

ក្នុងករណីដែលកូនសុំជានីតិជន បុគ្គលដែលក្លាយជាឪពុកម្តាយចិញ្ចឹម ត្រូវដាក់ពាក្យសុំរួមគ្នាជាមួយបុគ្គលដែលនឹងក្លាយជាកូនសុំ [31] ។

បើបុគ្គលដែលជាកូនសុំ ជាបុគ្គលដែលមានសហព័ទ្ធ តើចាំបាច់មានការយល់ព្រមពីសហព័ទ្ធនៃបុគ្គលដែលនឹងក្លាយជាកូនសុំនោះដែរឬទេ?

ត្រង់ចំណុចនេះ គឺមិនចាំបាច់មានការយល់ព្រមពីសហព័ទ្ធនៃបុគ្គលដែលជាកូនសុំនោះទេ ព្រោះសុំកូនធម្មតា បង្កើតឡើងដោយឆន្ទៈរបស់ភាគីផ្ទាល់។

ក្នុងករណីដែលកូនសុំជាអនីតិជន បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ត្រូវដាក់ពាក្យសុំរួមជាមួយអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំ ក្នុងនាមជាអ្នកមានអំណាចមេបា [34] ។

---

[32] មាត្រា១០២១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[33] មាត្រា១០២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[34] មាត្រា១០២០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

បើកូនសុំជាអនីតិជនដែលមានអាយុដល់ ១៥ឆ្នាំ គឺការដាក់ពាក្យសុំត្រូវមានការយល់ព្រមពីអនីតិជននោះ។ មានន័យថា បើអនីតិជននោះបដិសេធ ស្មុំកូននឹងមិនអាចបង្កើតបានឡើយ [35] ។

#### គ. ទម្រង់នៃពាក្យសុំ

ទម្រង់នៃពាក្យសុំស្មុំកូនធម្មតា គឺដូចគ្នានឹងទម្រង់នៃពាក្យសុំស្មុំកូនពេញលេញដែរ។

#### ឃ. ទីកន្លែងនៃការដាក់ពាក្យសុំ

ពាក្យសុំត្រូវដាក់នៅតុលាការខាងលំនៅឋានរបស់បុគ្គលដែលនឹងក្លាយជាកូនសុំ [36] ។

#### ង. ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ

ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំកូនធម្មតា គឺដូចនឹងពន្ធដាក់ពាក្យស្មុំកូនពេញលេញដែរ។

### ១.២.២. អានុភាពនៃស្មុំកូនធម្មតា

#### ១.២.២.១. ការបង្កើតញាតិភាពរវាងឪពុកម្ដាយចិញ្ចឹម

ក្រោយបង្កើតស្មុំកូនធម្មតា អានុភាពនៃញាតិភាពនឹងបង្កើតឡើងរវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំ ដែលកូនសុំនោះមានឋានៈដូចនឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម ហើយសិទ្ធិ និងកាតព្វកិច្ចនឹងត្រូវបានបង្កើតឡើង។ តាមរយៈនេះ កូនសុំអាចប្រើប្រាស់នាមត្រកូលតាមឪពុកម្ដាយចិញ្ចឹម ឬ បើមិនដូច្នេះទេ អាចប្រើប្រាស់នាមត្រកូលដើមរបស់ឪពុកម្ដាយបង្កើតក៏បាន [37] ។

ក្នុងករណីដែលកូនសុំជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹម។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធមកធ្វើជាកូន កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្ដាយចិញ្ចឹម និងសហព័ទ្ធនោះ [38]។

#### ១.២.២.២. ការបន្តញាតិភាពរវាងឪពុកម្ដាយបង្កើត

ដូចបានបញ្ជាក់ខាងលើ ស្មុំកូនធម្មតា មិនផ្ដាច់ទំនាក់ទំនងញាតិភាពរវាងឪពុកម្ដាយបង្កើត និងកូនសុំនោះទេ។ ក្នុងករណីនេះ បើញាតិភាពរវាងឪពុកម្ដាយបង្កើតនៅតែបន្ត ដូច្នេះសិទ្ធិ និង

[35] មាត្រា១០២៤ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[36] ឧបសម្ព័ន្ធទី៤ ចំណុចទី៩ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង។
[37] មាត្រា ១០២៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[38] មាត្រា១០២៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

កាតព្វកិច្ចក៏នៅតែមានចំពោះកូនសុំ និងឪពុកម្ដាយបង្កើត ដោយភាគីទាំងពីរអាចធ្វើសន្តតិកម្មចំពោះគ្នាទៅវិញទៅមក ហើយសិទ្ធិទាមទារអាហារកិច្ចក៏មានចំពោះគ្នាទៅវិញទៅមកផងដែរ [39] ។

បើចំណងរវាងឪពុកម្ដាយបង្កើតនៅតែមាន ដូច្នេះកូនសុំនោះនឹងមានទំនាក់ទំនងជាមួយឪពុកម្ដាយចិញ្ចឹមផង និងឪពុកម្ដាយបង្កើតផង ដែលជាហេតុនាំឱ្យសិទ្ធិ និងកាតព្វកិច្ចក៏នៅតែមានដូចគ្នា។ ប៉ុន្តែបើកូនសុំនោះជាអនីតិជន ច្បាប់បានកំណត់យកឪពុកម្ដាយចិញ្ចឹម ជាអ្នកមានអំណាចមេបាលើកូនសុំនោះ [38] ។

**សំគាល់៖** ចំពោះអានុភាពនៃសុំកូនពេញលេញ ដែលមានវិការៈនៅអំឡុងពេលដាក់ពាក្យសុំ បើសិនជាតុលាការ បានចេញដីកាសម្រេចឱ្យបង្កើតសុំកូនពេញលេញ ហើយដីកានោះបានចូលជាស្ថាពរ ក៏អានុភាពនៃសុំកូនត្រូវបានបង្កើតឡើងដដែល។

## ១.២.៣. ការបញ្ចប់ទំនាក់ទំនងសុំកូនធម្មតា

សុំកូនធម្មតា អាចបញ្ចប់តាមរយៈការកាត់កាល់។ ក្នុងករណីនេះ ការកាត់កាល់មានពីរទម្រង់ គឺការកាត់កាល់តាមការព្រមព្រៀង និងបណ្ដឹងទាមទារឱ្យកាត់កាល់។

### ១.២.៣.១. ការកាត់កាល់តាមការព្រមព្រៀង

ការកាត់កាល់ដោយការព្រព្រៀង គឺជាការព្រមព្រៀងបញ្ចប់ទំនាក់ទំនងរវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំ។ ការកាត់កាល់ត្រូវធ្វើឡើងតាមផ្លូវតុលាការ តាមរយៈការដាក់ពាក្យសុំកាត់ផ្ដាច់ទំនាក់ទំនងសុំកូនធម្មតា [40] ។ ការកាត់កាល់ដោយការព្រមព្រៀងមិនចាំបាច់មានមូលហេតុនោះទេ ឱ្យតែភាគីដែលជាឪពុកម្ដាយចិញ្ចឹម និងកូនសុំ បានព្រមព្រៀងគ្នាជាការស្រេច។

ករណីដែលកូនសុំជាអនីតិជនត្រូវមានអ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងនោះបុគ្គលដែលត្រូវបានក្លាយជាអ្នកមានអំណាចមេបា គឺឪពុកម្ដាយបង្កើតនៃកូនសុំនោះ។

ប៉ុន្តែបើកូនសុំជាអនីតិជនដែលមានអាយុដល់១៥ឆ្នាំ ហើយអាចបង្ហាញឆន្ទៈបាន នោះត្រូវមានការយល់ព្រមពីកូនសុំដែលជាអនីតិជននោះ។

ការកាត់កាល់ដោយការព្រមព្រៀង ជាសមត្ថកិច្ចរបស់តុលាការនៃលំនៅឋានរបស់កូនសុំ[41] ។

---

[39] មាត្រា១០២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[40] មាត្រា១០២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[41] ឧបសម្ព័ន្ធទី៤ ចំណុចទី១០ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង។

### ១.២.៣.២. ការកាត់កាល់តាមបណ្ដឹង

ការកាត់កាល់តាមបណ្ដឹង គឺជាការសុំផ្ដាច់ទំនាក់ទំនងញាតិរវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំ ដែលធ្វើឡើងដោយភាគីណាម្ខាងនៃស្មុំកូន។

បើបុគ្គលដែលជាកូនសុំជាអនីតិជន នោះឪពុកម្ដាយចិញ្ចឹមមិនអាចធ្វើការកាត់កាល់កូនសុំនោះបានទេ ផ្ទុយមកវិញ បុគ្គលដែលជាកូនសុំនោះអាចកាត់កាល់ឪពុកម្ដាយចិញ្ចឹមនោះបាន [42] ។

ការកាត់កាល់នេះ ជាការកាត់កាល់ដោយបង្ខំចំពោះភាគីម្ខាងទៀត ដែលគ្មានបំណងចង់កាត់កាល់នោះទេ ដូច្នេះ ដើម្បីឱ្យការកាត់កាល់ស្មុំកូនធម្មតាអាចប្រព្រឹត្តទៅបាន ចាំបាច់ទាល់តែមានមូលហេតុដូចជា៖

- បើត្រូវបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត។
- បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព
- បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្ដាលឱ្យមានការពិបាកក្នុងការបន្តស្មុំកូន។

ការកាត់កាល់តាមបណ្ដឹងត្រូវអនុលោមតាមច្បាប់ស្ដីពីនីតិវិធីនៃបណ្ដឹងឋានៈបុគ្គល [43] ។

### ១.២.៣.៣. អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា

ក្រោយការកាត់កាល់ អានុភាពទាំងឡាយនៃស្មុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគតដោយការកាត់កាល់ ហើយក្រោយការកាត់កាល់កូនសុំអាចទទួលបានមកវិញនូវនាមត្រកូលមុនស្មុំកូនក៏បាន ឬ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន [44] ។

---

[42] មាត្រា១០៣១ កថាខណ្ឌទី២ និងទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[43] មាត្រា៣ ចំណុច ឈ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១។

[44] មាត្រា១០៣២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# ផ្នែកទី២៖ សុំកូនអន្តរប្រទេស

## ២.១. និយមន័យ

សុំកូនអន្តរប្រទេស គឺជាការសុំទារក ឬ កុមារកំព្រាដែលមានញ្ជាតិខ្មែរ ដែលមានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្ដីប្រពន្ធដែលរស់នៅក្នុងប្រទេសផ្សេងទៀត ដើម្បីសុំយកទៅចិញ្ចឹមជាកូន ហើយនឹងត្រូវបានទទួលស្គាល់ដោយច្បាប់របស់ប្រទេសនោះ។

សុំកូនអន្តរប្រទេសអាចអនុញ្ញាតបានបន្ទាប់ពីអាជ្ញាធរកម្ពុជាបានប្រឹងប្រែងឱ្យអស់ពីលទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើតវិញ ឬ ក៏រកលក្ខណៈសម្បត្តិសុំកូនក្នុងស្រុកជាមុនរួចហើយ។

សុំកូនអន្តរប្រទេសត្រូវបានគ្រប់គ្រងដោយច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ហើយដែលប្រកាសជាប្រញាប់ផង។ ច្បាប់នេះត្រូវបានតាក់តែងឡើង ដោយពឹងផ្អែកទៅលើគោលការណ៍នៃកតិកាសញ្ញា និងអនុសញ្ញាជាតិទាក់ទងនឹងកុមារ ព្រមទាំងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ និងច្បាប់ពាក់ព័ន្ធមួយចំនួនទៀតជាជំនួយ។

## ២.២. គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស

គោលការណ៍នៃការសុំកូន គឺតែងតែគិតពីផលប្រយោជន៍របស់កុមារ ដែលត្រូវក្លាយជាកម្មវត្ថុនៃសុំកូន។ គោលការណ៍ទូទៅមួយចំនួន ទាក់ទងនឹងការសុំកុមារទៅរស់នៅឯបរទេស ដែលក្នុងនោះបានកំណត់ដូចតទៅ៖ [45]

១. កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្ដីស្រលាញ់ និងការយោគយល់ ដើម្បីឱ្យមានការអភិវឌ្ឍពេញលេញ និងយ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន។សុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្ដល់ការឧបត្ថម្ភគាំទ្រ ដើម្បីឱ្យកុមាររស់នៅក្នុងគ្រួសារកំណើត និងក្រោយពីបានធ្វើការពិចារណា អំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. សុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែជាសុំកូនពេញលេញ ដែលបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និងកូនសុំជាអចិន្ត្រៃយ៍ និងដែលផ្ដល់ដល់កុមារនូវឋានៈ សិទ្ធិ និងកាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹមនោះ។

---

45 មាត្រា៥ នៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

៣. កុមារទាំងអស់ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើង អំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាព ឬ ស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬ របស់ឪពុកម្តាយ ឬ របស់ឪពុក ឬ របស់ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។

៤. រាល់កាលសម្រេច និងសកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេស ត្រូវគិតគូរឱ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ។

៥. តុលាការ និងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការសុំកូនអន្តរប្រទេសត្រូវធានាថានៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលលមានសមត្ថភាពអាចដឹងខុសដឹងត្រូវបានពិគ្រោះយោបល់ និងពន្យល់ណែនាំឱ្យបានត្រឹមត្រូវអំពីអានុភាពនានាដែលកើតចេញពីសុំកូននេះដោយគិតគូរដល់សេចក្តីប្រាថ្នា និងមតិរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ។

៦. ហាមការធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេស។ អាជីវកម្ម ឬ សកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសមានៈ

- អំពើប្រព្រឹត្តក្នុងគោលបំណងចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឱ្យបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើតដើម្បីប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស។
- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងឪពុក ឬ ម្តាយដែលចង់បោះបង់កូនកើតមកហើយ ឬ ដែលនឹងកើត និង
- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់បានកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ។

៧. អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេស មិនបណ្តាលឱ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និងត្រូវបង្ការមិនឱ្យមានការចាប់ពង្រត់ ការលក់ និងការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស។ មានតែប្រាក់ចំណាយសោហ៊ុយ និងវិភាគទាន ដែលកំណត់ដោយបញ្ញត្តិនៃច្បាប់នេះ ដែលត្រូវបង់។

## ២.៣. លក្ខខណ្ឌនៃការបង្កើតសុំកូនអន្តរប្រទេស

កាលណាយើងនិយាយពីលក្ខខណ្ឌ វាក៏មិនខុសពីសុំកូនក្នុងស្រុកនោះដែរ។ លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ត្រូវបានកំណត់យ៉ាងច្បាប់នៅក្នុងច្បាប់ស្តីអំពីសុំកូនអន្តរប្រទេស ដែលក្នុងនោះមានបញ្ញត្តិអំពី លក្ខខណ្ឌសារធាតុ និងលក្ខខណ្ឌទម្រង់។

### ២.៣.១. លក្ខខណ្ឌគ្រឹះ ឬ លក្ខខណ្ឌសារធាតុ

#### ២.៣.១.១. ចំពោះអ្នកសុំ

##### ក. អាយុ

អ្នកសុំ ជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី ៣០(សាមសិប) ឆ្នាំ និងមានអាយុលើសកូនសុំយ៉ាងតិច ២២(ម្ភៃពីរ) ឆ្នាំ និងយ៉ាងច្រើនបំផុត ៤៥(សែសិបប្រាំ) ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន[46]។

មានន័យថា អ្នកសុំដាច់ខាតត្រូវតែមានសហព័ទ្ធ ហើយមានអាយុចាប់ពី ៣០(សាមសិប) ឆ្នាំ ដល់ ៤៥(សែសិបប្រាំ) ឆ្នាំ គិតត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យសុំកូន។

##### ខ. ស្ថានភាព

ដើម្បីឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឱ្យបាន លុះត្រាតែៈ

ក. អ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬ

ខ. អ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត ឬ

គ. អ្នកសុំ សុំកូនដែលត្រូវការថែទាំពិសេស ឬ ស្ថានភាពផ្សេងទៀត ដែលបម្រើឧត្តមប្រយោជន៍របស់កុមារ។

ក្នុងករណីអ្នកសុំមានប្តី ឬប្រពន្ធ ការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ទ្ធណាម្ខាង សុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀត។

ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និងច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និងអនុញ្ញាតនូវបុត្តភាពនៃសុំកូនពេញលេញ។

ប្រទេសនៃសញ្ជាតិ ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។

អ្នកសុំត្រូវមានលក្ខណសម្បត្តិ និងលក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របទៅតាមច្បាប់នៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន។

---

46 មាត្រា២១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬ កំពុងត្រូវបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមារយាទ ឬ ការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈឹមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬ ក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ។

អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្រប និងការគាំទ្រចាំបាច់ដល់កូនសុំ។

អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកសុំកូនគ្មានកូន ឬ មានកូនតែម្នាក់នៅក្នុងបន្ទុក។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន [47] ។

## ២.៣.១.២. ចំពោះកូនសុំ

### ក. អាយុ

កុមារដែលមានអាយុក្រោម៨(ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអាចអនុញ្ញាតបានដល់អាយុក្រោម១៨(ដប់ប្រាំបី) ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម១៨(ដប់ប្រាំបី) ឆ្នាំ។

ក្នុងករណីសុំកូនដោយសាច់ញាតិ សុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម១៨(ដប់ប្រាំបី) ឆ្នាំ [48] ។

### ខ . ស្ថានភាព

កុមារដែលអាចជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបាន លុះត្រាតែកុមារនោះស្ថិតក្នុងស្ថានភាពដូចជា៖

### ខ.១. កុមារដែលមានអត្តសញ្ញាណ

ករណីកុមារមានអត្តសញ្ញាណ កុមារដែលអាចជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស លុះត្រាតែ៖

- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ
- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀតដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬ
- កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែលស្ថិតនៅក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត ឬ

---

[47] មាត្រា២១ កថាខណ្ឌទី២ ដល់ទី៩ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[48] មាត្រា១០ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

- កុមារនោះត្រូវបានប្រកាសថាអាចសុំជាកូនចិញ្ចឹមបាន [49]

### ខ.២. កុមារដែលពុំមានអត្តសញ្ញាណ

ករណីមានកុមារត្រូវបានរកឃើញ និងបញ្ជូនមកមណ្ឌលកុមារកំព្រា ហើយរកមិនឃើញឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានមណ្ឌលកុមារកំព្រា ត្រូវជូនដំណឹងទៅមណ្ឌលទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត អំពីវត្តមានរបស់កុមារ ដែលបានចូលមកស្នាក់នៅក្នុងមណ្ឌល យ៉ាងយូរបំផុតរយៈពេល ៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីពេលកុមារមកដល់មណ្ឌល។ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជីស្តីពីកុមារដែលត្រូវបានរាយការណ៍ថាត្រូវបានគេបោះបង់ចោល។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្តាយ ឬឪពុក ឬ ម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនមុន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈទៅតាមលទ្ធភាពដូចជាទូរទស្សន៍ វិទ្យុ ឬ សារព័ត៌មាន និងរូបភាពរបស់កុមារនោះ។ ជនណាដែលអះអាងថាខ្លួនជាឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ជននោះបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទងជាសាច់ញាតិ ឬអាណាព្យាបាលសម្រាប់អនីតិជនជាមួយកុមារស្របទៅតាមបទបញ្ញត្តិជាធរមាន។

បន្ទាប់ពីការផ្សព្វផ្សាយដំណឹងរយៈពេល**៥ (ប្រាំ) ខែ** នៅតែរកមិនឃើញឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការខិតខំស្រាវជ្រាវនេះ ហើយត្រូវធ្វើមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបោះបង់ចោល។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ រហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត គឺជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន [50] ។

[49] មាត្រា១០ កថាខណ្ឌទី៣ ទី៤ និងទី៥ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩។
[50] មាត្រា១១ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

## ខ.៣. កុមារកំព្រាដែលមានអ្នកមានអំណាចមេបាក្រលំបាក

ប្រសិនបើអ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកខ្លាំង បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកនោះ ត្រូវបញ្ចូលឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច [51] ។

### ២.៣.១.៣. ឪពុកម្តាយបង្កើត ឬអាណាព្យាបាល

### ក. ការយល់ព្រមរបស់ឪពុកម្តាយបង្កើត

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចខាងក្រោមនេះ៖

ក. ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និងម្តាយ ការយល់ព្រមត្រូវផ្តល់ដោយឪពុក និងម្តាយរបស់កុមារនោះ។

ខ. ក្នុងករណីដែលឪពុក ឬ ម្តាយណាមួយរបស់កុមារបានស្លាប់ ឬ ស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុក ឬម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់។

គ. ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬ ស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ [52] ។

ការយល់ព្រមខាងលើត្រូវផ្តល់ឱ្យដោយសេរី និងច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ ការសន្យាផ្តល់ប្រាក់រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយឡើយ និងដោយបានដឹងច្បាស់អំពីផលវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស[53] ។

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិនមុននឹងផ្តល់ការយល់ព្រម។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ ដល់អ្នកដែលត្រូវផ្តល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រម ការបញ្ចប់នូវបុត្តភាពព្រមទាំងការបញ្ចប់

---

[51] មាត្រា១២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[52] មាត្រា១៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[53] មាត្រា១៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

សិទ្ធិ និងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងត្រូវប្រាប់អំពីបែបបទ និងរយៈពេលបញ្ឈប់ការយល់ព្រម។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍របស់ខ្លួនជាមួយឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។

ទោះក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរនៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងលំនៅឋានរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។

មេឃុំ ឬចៅសង្កាត់ និងភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធានាថា រាល់ការយល់ព្រមរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវតែជាការយល់ព្រមដែលមិនមានវិការៈ។

មេឃុំ ឬចៅសង្កាត់ ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមនេះ ក្រោយពីបានពិនិត្យថា ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងបានប្រាប់យ៉ាងត្រឹមត្រូវអំពីអានុភាពនៃការយល់ព្រមនេះ [54] ។

### ខ. ការបញ្ឈប់ការយល់ព្រមលើសុំកូន

ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មុនពេលសេចក្តីសម្រេចរបស់តុលាការស្តីពីការសុំកូនចូលជាស្ថាពរ។ ការបញ្ឈប់ការយល់ព្រមរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ នៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន។ មេឃុំ ឬចៅសង្កាត់ខាងលំនៅឋានរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ និងត្រូវប្រគល់កំណត់ហេតុចម្លងដែលមានសេចក្តីបញ្ជាក់នៅលើកំណត់ហេតុនោះ ទៅឱ្យឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ [55] ។

[54] មាត្រា១៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។
[55] មាត្រា១៧ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

### គ. ការដកហូតអំណាចមេបាពីឪពុកម្តាយបង្កើត

ករណីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ បដិសេធការយល់ព្រម ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាច ប្តឹងសុំឱ្យតុលាការប្រកាសដកហូតអំណាចមេបាពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬបញ្ឈប់ការយល់ព្រមនេះ ធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់កុមារ ឬ បណ្តាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារ។

ពាក្យបណ្តឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល**៦០(ហុកសិប) ថ្ងៃ** នៃថ្ងៃធ្វើការ ក្រោយពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ បដិសេធ ឬបញ្ឈប់ការយល់ព្រមរបស់ខ្លួន [56] ។

## ២.៣.២. លក្ខខណ្ឌទម្រង់

### ២.៣.២.១. ការដាក់ពាក្យ

អ្នកសុំ ត្រូវដាក់ពាក្យសុំកូន ទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា [57] ។

មានន័យថា បុគ្គលដែលមានបំណងសុំកុមារកម្ពុជាយកទៅចិញ្ចឹម គឺត្រូវដាក់ពាក្យទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដែលមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា។

ពាក្យសុំ ត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្តល់យោបល់ និងបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេល**១៥ (ដប់ប្រាំ) ថ្ងៃ** នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំ។ ក្នុងរយៈពេលយ៉ាងយូរបំផុត**១៥(ដប់ប្រាំ) ថ្ងៃ** នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬតាមរយៈទី

[56] មាត្រា១៩ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[57] មាត្រា២៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

ភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ ដោយបញ្ជាក់ថា ខ្លួនបានទទួលពាក្យសុំកូន [58] ។

### ២.៣.២.២. ទម្រង់នៃពាក្យសុំ

ទម្រង់នៃពាក្យសុំ ដែលអ្នកសុំត្រូវបំពេញមានដូចជា៖

- ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំ ដែលក្នុងនោះរួមមានឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន។

- ព័ត៌មានទាក់ទងនឹងលក្ខណសម្បត្តិផ្សេងៗរបស់កុមារ ដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន។

- មានភស្តុតាងដែលទទួលបានពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយ កូនសុំនោះត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល។

ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។

ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬភាសាបារាំង ដែលមានការបញ្ជាក់ត្រឹមត្រូវ [59] ។

### ២.៣.២.៣. នីតិវិធីនៃការសុំ

ដំណើរនៃនីតិវិធីសុំកូនអន្តរប្រទេស មាន ២ គឺ ដំណើរនៃនីតិវិធីរដ្ឋបាល និងដំណើរនៃនីតិវិធីតុលាការ។

#### ក. នីតិវិធីរដ្ឋបាល

រដ្ឋបាលសុំកូនអន្តរប្រទេស មានតួនាទីក្នុងការគ្រប់គ្រងសំណុំឯកសារ ពិនិត្យពាក្យសុំ ផ្គូរផ្គងលក្ខណសម្បត្តិ និងសោហ៊ុយ។

#### ក.១. ការគ្រប់គ្រងសំណុំឯកសារ

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមាន ព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំ

[58] មាត្រា២៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[59] មាត្រា២៣ កថាខណ្ឌទី១ ចំណុចទី២ ដល់ទី៥ កថាខណ្ឌទី២ និងទី៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

ជាកូនចិញ្ចឹម សាវតាជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពរបស់កុមារ និងប្រវត្តិសុខភាពគ្រួសាររបស់កុមារ និងសេចក្តីត្រូវការជាពិសេសណាមួយរបស់កុមារ។

ក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវបានធ្វើរួចហើយ។

រដ្ឋបាលសុំកូនអន្តរប្រទេសក៏ត្រូវធានាផងដែរថា រាល់ការយល់ព្រមចាំបាច់ទាំងឡាយដែលបានធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ។

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាល់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និង/ឬការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ។

### ក.២. ការពិនិត្យពាក្យសុំ

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល **៦០(ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតសុំកូន។ ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ហើយ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវបញ្ជាក់ថា អ្នកសុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នេះហើយ។

ក្នុងករណីដែលសំណុំលិខិតដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស មិនទាន់គ្រប់គ្រាន់ ឬមិនទាន់ត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬមិនទាន់ត្រឹមត្រូវ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល **៦០(ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ** បន្ទាប់ពីបានទទួលឯកសារដែលនៅខ្វះ ឬកែតម្រូវរួច។

ក្នុងករណីអ្នកសុំខកខានមិនបានផ្តល់ឯកសារដែលនៅខ្វះ ឬមិនទាន់ត្រឹមត្រូវក្នុងរយៈពេល **៦០(ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ** គិតពីថ្ងៃរដ្ឋបាលសុំកូនអន្តរប្រទេសបានជូនដំណឹងអំពីឯកសារដែលមិនទាន់គ្រប់គ្រាន់ ឬមិនទាន់ត្រឹមត្រូវ នោះពាក្យសុំកូនអន្តរប្រទេសត្រូវទុកជាមោឃៈ។

ក្នុងករណីបដិសេធពាក្យសុំ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវមានបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ [60] ។

### ក.៣. ការផ្គូផ្គងលក្ខណសម្បត្តិ

ក្នុងករណីសំណុំមានលិខិតមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ហើយអ្នកសុំបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់នេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំនុំឯកសាររបស់កុមារទាំងឡាយដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន និងត្រូវផ្គូផ្គងអំពីលក្ខណសម្បត្តិរបស់អ្នកសុំណាដែលត្រូវគ្នាល្អបំផុតនឹងលក្ខណសម្បត្តិរបស់កុមារ។

ក្នុងការផ្គូផ្គងដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាឱ្យបានសមស្របទៅលើអត្ថប្រយោជន៍នៃការបន្តឱ្យមានការបីបាច់ ថែរក្សាកុមារ ដូចពេលកន្លងមក ព្រមទាំងពិចារណាទៅលើសាវតារសង្គម ជាតិពន្ធុ សាសនា និងវប្បធម៌របស់កុមារ [61] ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលត្រូវបានផ្គូផ្គង រួមទាំងភស្តុតាងដែលបញ្ជាក់ថា រាល់ការយល់ព្រមចាំបាច់នានា ត្រូវបានទទួលរួចហើយ និងមូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារជាមួយអ្នកសុំនោះទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីពិនិត្យនិងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពីអត្តសញ្ញាណឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារឡើយ លើកលែងតែករណីសុំកូនដោយសាច់ញាតិ [62] ។

### ក.៣.១. ការតបទៅអ្នកសុំ

អ្នកសុំត្រូវឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមសុំកុមារ ដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្គូផ្គងឱ្យតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល។
ក្នុងករណីអ្នកសុំមិនបានឆ្លើយតបមករដ្ឋបាលសុំកូនអន្តរប្រទេសក្នុងរយៈពេល **៦០(ហុកសិប) ថ្ងៃ** នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្ញើសំណុំឯកសាររបស់កុមាររដ្ឋបាលសុំកូនអន្តរប្រទេសអាចចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ហើយរដ្ឋបាលសុំកូនអន្តរ

[60] មាត្រា២៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។
[61] មាត្រា២៧ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។
[62] មាត្រា២៨ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

ប្រទេសអាចផ្តួផ្តងកុមារនោះឱ្យទៅអ្នកសុំផ្សេងទៀតបាន។ ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនបានបង្វិលឱ្យវិញឡើយ។

ក្នុងករណីអ្នកសុំបានឆ្លើយតបថាមិនទទួលយកុមារដែលបានផ្តួផ្តងឱ្យខ្លួននៅលើកទីមួយទេ អ្នកសុំនោះអាចស្នើសុំឱ្យរដ្ឋបាលសុំកូនអន្តរប្រទេសផ្តួផ្តងកុមារជាលើកទីពីរបាន។ ការផ្តួផ្តងនេះមិនត្រូវអនុញ្ញាតឱ្យធ្វើជាលើកទី៣ឡើយ។

ចំពោះអ្នកសុំដែលមិនបានឆ្លើយតបតាមរយៈពេលដែលបានកំណត់ទេ អ្នកសុំនោះអាចដាក់ពាក្យសុំកូនសាជាថ្មី ។ ក្នុងការសម្រេចអំពីការសុំឱ្យមានការផ្តួផ្តងសាជាថ្មី ឬការទទួលពាក្យសុំកូនសាជាថ្មី រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬ ឆ្លើយតបថា មិនមានបំណងសុំកុមារដែលបានផ្តួផ្តងពីលើកមុននាពេលកន្លងមក [63] ។

### ក.៣.២. ការជួប

បន្ទាប់ពីអ្នកសុំ បានបញ្ជាក់ការយល់ព្រមរបស់ខ្លួនស្របតាមបទប្បញ្ញត្តិក្នុងមាត្រា ២៩នៃច្បាប់នេះ ហើយអាជ្ញាធរកណ្តាលនៃប្រទេសទទួល បានយល់ព្រមលើការសម្រេចនេះ រដ្ឋបាលសុំកូនអន្តរប្រទេសតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួលត្រូវរៀបចំឱ្យមានការជួបគ្នារវាងអ្នកសុំ និងកុមារដែលត្រូវបានផ្តួផ្តងរួចហើយ។

ការជួបគ្នានេះត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទមួយសមស្របសម្រាប់អ្នកសុំ និងរដ្ឋបាលសុំកូនអន្តរប្រទេស និងត្រូវមានវត្តមានមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង។ ការជួបគ្នានេះ ត្រូវធ្វើក្នុងរយៈពេល **៦០(ហុកសិប) ថ្ងៃ** នៃថ្ងៃធ្វើការ បន្ទាប់ពីការបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ។

មុនការជួបគ្នារវាងអ្នកសុំ និងកុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើសម្ភាសន៍អ្នកសុំ និងធានាថា អ្នកសុំ និងកុមារត្រូវបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មាន ការផ្លាស់ប្តូររូបថត និងវិធានការចាំបាច់ផ្សេងៗទៀត ដើម្បីការជួបគ្នានេះ។

ករណីមានសហព័ទ្ធបើសហព័ទ្ធណាម្ខាងមិនអាចមកបាន សហព័ទ្ធនោះត្រូវធ្វើលិខិតប្រគល់សិទ្ធិឱ្យទៅសហព័ទ្ធម្ខាងទៀត ធ្វើជាអ្នកតំណាងរបស់ខ្លួន ដើម្បីធ្វើសកម្មភាពក្នុងការបញ្ជូននោះ។ លិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល។

[63] មាត្រា២៩ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

ក្នុងករណីអ្នកសុំមិនមកក្នុងរយៈពេលតាមការកំណត់ ដោយគ្មានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន [64] ។

### គ.៣.៣.យោបល់កុមារ

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឱ្យបានដឹងអំពីអានុភាពដែលកើតចេញពីសុំកូន ហើយត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ។ រដ្ឋបាលសុំកូន ក្នុងនោះមានជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណាដោយផ្អែកទៅតាមវ័យ និងកម្រិតយល់ដឹងរបស់កុមារ។ សំអាងស្តីពីការយល់ព្រមរបស់កុមារត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍ និងការជួបគ្នាខាងលើនេះ [65] ។

### គ.៣.៤. ការសម្រេចលើការសុំ

ក្នុងករណីរដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថា អ្នកសុំ និងកុមារបំពេញបាននូវលក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយសុំកូននេះពិតជាបានឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល **៧(ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ** បន្ទាប់ពីការជួបគ្នារវាងអ្នកសុំ និងកុមារ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវដាក់សំណុំលិខិតទាំងនេះ ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការពិនិត្យ និងផ្តល់អនិសាសន៍លើដំណើរការសុំកូន [66] ។

ក្រោយពីទទួលអនុសាសន៍លើដំណើរការសុំកូនពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដាក់ពាក្យសុំកូនដែលបានផ្តផ្គងរួច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញដោយភ្ជាប់ជាមួយនូវឯកសាររបស់កុមារ និងអ្នកសុំ ព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងយៈ

[64] មាត្រា៣០ កថាខណ្ឌទី១ ដល់ទី៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[65] មាត្រា៣០ កថាខណ្ឌទី៦ និងទី៧ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[66] មាត្រា៣២ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

ពេល **៧(ប្រាំពីរ) ថ្ងៃ** នៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទទទួលពាក្យសុំ។ ឯកសារចាំបាច់ទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និងមានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស។

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល **៦០(ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីទទួលបានអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន [67] ។

### ក.៤. សោហ៊ុយចំពោះរដ្ឋបាលសុំកូនអន្តរប្រទេស

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា សម្រាប់ជួយឧបត្ថម្ភជម្រើសនានានៃការថែទាំជំនួស និងការជួយឧបត្ថម្ភទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និងកម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ក្រៅពីនេះមិនត្រូវយកប្រាក់សោហ៊ុយសុំកូនពីអ្នកសុំ ឬទីភ្នាក់ងាររបស់អ្នកសុំកូន។

មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូន បង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬទៅតាមសោហ៊ុយសុំកូនមួយដែលនឹងត្រូវបញ្ជូនទៅមណ្ឌលកុមារកំព្រាណាមួយ ឬមិនអនុញ្ញាតឱ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូន ធ្វើការផ្តល់សោហ៊ុយ អំណោយ ឬការទូទាត់ទោះបីក្នុងរូបភាពណាក៏ដោយ ទៅឱ្យមណ្ឌលកុមារកំព្រាដែលកុមារកំព្រានៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬទៅឱ្យបុគ្គលិក នាយក ឬសមាជិក នៃគណៈគ្រប់គ្រងទោះដោយផ្ទាល់ ឬដោយប្រយោលក្តី [68] ។

## ខ. នីតិវិធីតុលាការ

សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស។

### ខ.១. ការពិនិត្យសំណុំឯកសារ

តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថាៈ

ក. លក្ខណវិនិច្ឆ័យ ឬលក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ។

ខ. ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងផ្តល់ការយល់ព្រម។

គ. ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារនៃច្បាប់។

---

[67] មាត្រា៣៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[68] មាត្រា២៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

ឃ. មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ង. អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល យល់ព្រមលើការទុកដាក់កុមារ។

ច. កុមារនឹងត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសទទួល។

ឆ. សុំកូនអន្តរប្រទេសនេះពិតជាឧត្តមប្រយោជន៍របស់កុមារ [69] ។

## ខ.២. នីតិវិធីនៃការប្តឹងជំទាស់

### ខ.២.១. អ្នកមានសិទ្ធិ

បុគ្គលដែលមានសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ចំពោះដីកាសម្រេចនោះបាន [70] ។

### ខ.២.២. រយៈពេល

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល **១៥(ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលខ្លួនទទួលបានការជូនដំណឹងអំពីដីកាសម្រេច**។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីការសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងកំឡុងពេល **១៥(ដប់ប្រាំ)ថ្ងៃ** នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេច។

អំឡុងពេល **១៥(ដប់ប្រាំ) ថ្ងៃ** នៃថ្ងៃធ្វើការ ដោយមិនអាចពន្យារបានឡើយ។

ដីកាម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ [71] ។

### ខ.២.៣. សមត្ថកិច្ចយុត្តាធិការលើបណ្តឹងជំទាស់

បុគ្គលដែលមានសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ចំពោះដីកាសម្រេចនោះបាន។

[69] មាត្រា៣៧ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[70] មាត្រា៤០ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[71] មាត្រា៤០ កថាខណ្ឌទី២ ទី៣ ទី៤ និងទី៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្ដឹងជំទាស់នោះមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល **៣០(សាមសិប) ថ្ងៃ**នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងជំទាស់ [72] ។

### ខ.៣. សោហ៊ុយក្នុងនីតិវិធីតុលាការ

អ្នកសុំត្រូវបង់ប្រាក់ចំនួន **១ ០០០ ០០០(មួយលាន) រៀល** ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យសុំ ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្ដីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពខាងនីតិវិធីផ្សេងៗទៀតដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តុលាការត្រូវបង្គាប់ឱ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពី **១ ០០០ ០០០(មួយលាន) រៀល** តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និងបង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញបានទេ[73]។

### ២.៣.៣. ដំណើរការក្រោយនីតិវិធីសុំ

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីសុំកូន វិធានការដែលអាជ្ញាធរមានសមត្ថកិច្ចបានចាត់ការ និងការវិវត្តនៃការសុំកូននៅគ្រប់ដំណាក់កាលរបស់នីតិវិធីសុំកូនឱ្យបានទៀងទាត់ ទៅអ្នកសុំតាមអាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាត។

ក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អំពីដីកាសម្រេចនេះ។

នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ ដោយអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេ ស្ដីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចេញលិខិតបញ្ជាក់អនុលោមមួយ [74] ។

#### ២.៣.៣.១. ការប្រគល់កុមារ

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំពិធីប្រគល់កុមារ និងលិខិតស្ដីពីការប្រគល់កូនជាផ្លូវការទៅឱ្យអ្នកសុំ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថ

[72] មាត្រា៤០ កថាខណ្ឌទី២ និងទី៥ នៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។
[73] មាត្រា៣៥ នៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។
[74] មាត្រា៤៣ និង៤៤ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

កិច្ច ក្នុងការរៀបចំ និងផ្តល់នូវលិខិតឆ្លងដែន ទិដ្ឋាការ និងឯកសារចាំបាច់នានា ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។

ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួល ត្រូវអមដំណើរដោយអ្នកសុំ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធានាថាការផ្ទេរកុមារទៅកាន់ប្រទេសទទួល ប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរដល់សេចក្តីត្រូវការនានារបស់កុមារ [75] ។

## ២.៣.៣.២. ការតាមដានស្ថានភាពកុមារ

ក្រោយពីកុមារបានទទួលការអនុញ្ញាតឱ្យធ្វើជាកូន ឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារមករដ្ឋបាលសុំកូនអន្តរប្រទេសរៀងរាល់ **០៦(ប្រាំមួយ) ខែ** ម្តង ក្នុងរយៈពេល**៣(បី) ឆ្នាំ** បន្ទាប់មកត្រូវផ្តល់របាយការណ៍ **១ឆ្នាំម្តង** រហូតដល់មានអាយុ **១៨ឆ្នាំ**។ ឪពុកម្តាយចិញ្ចឹមត្រូវផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្តល់ ឬតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ឬ ប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប [76] ។

## ២.៣.៣.៣. ការតំកល់សំណុំឯកសារ

រដ្ឋបាលសុំកូនអន្តរប្រទេស និងសាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាទុកសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល **៦០(ហុកសិប) ឆ្នាំ** គិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ។

សំណុំឯកសារ និងកំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ទោះជារក្សាទុកនៅតុលាការ រដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និងអ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាការសម្ងាត់។ ក៏ប៉ុន្តែសំណុំឯកសារ និងកំណត់ហេតុ ឬព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារ និងកំណត់ហេតុទាំងនោះអាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណី

[75] មាត្រា៨៤ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។
[76] មាត្រា៨៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

មានត្រូវកាកទាក់ទងនឹងករណី ឬនីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬកាលៈទេសៈពិសេសដទៃទៀត [77] ។

### ២.៣.៣.៤. សិទ្ធិទទួលដឹងពីកំណើតខ្លួន

ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ។ កូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អំពីផលវិបាកនៃការដឹងអត្តសញ្ញាណរបស់ខ្លួន អាចត្រូវបានអនុញ្ញាតឱ្យមើលសំណុំលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះជាឧត្តមប្រយោជន៍របស់កូនសុំ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និងកំណត់ហេតុទាក់ទងនឹងអត្តសញ្ញាណខ្លួន។ រដ្ឋបាលសុំកូនអន្តរប្រទេសធានាថា កូនសុំទទួលបានការពិគ្រោះយោបល់សមស្របមុននឹងមើលព័ត៌មាននៅក្នុងសំណុំលិខិតរបស់ខ្លួន [78] ។

### ២.៣.៤. អានុភាពនៃសុំកូនអន្តរប្រទេស

សុំកូនអន្តរប្រទេសត្រូវតែជាសុំកូនពេញលេញ។ សុំកូនអន្តរប្រទេសមានអានុភាពបង្កើតទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយ និងកូនជាអចិន្ត្រៃយ៍ ដោយផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និងកាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ហើយវាបញ្ចប់ញាតិភាពរវាងកុមារ និងឪពុកម្តាយបង្កើតរបស់ខ្លួន។

អានុភាពផ្សេងទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬប្រសិនបើគ្មានច្បាប់រួមមួយទេ ត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ [79]។

### ២.៣.៥. ការបញ្ចប់ទំនាក់ទំនងសុំកូនអន្តរប្រទេស

តាមច្បាប់ស្តីពីសុំកូនអន្តរប្រទេសការបញ្ចប់ទំនាក់ទំនងសុំកូន មិនមានចែងនោះទេ។

---

[77] មាត្រា៤៦ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[78] មាត្រា៤៦ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

[79] មាត្រា៤១ និង៤២ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

ប៉ុន្តែដោយអានុភាពនៃសុំកូនអន្តរប្រទេស ត្រូវតែជាសុំកូនពេញលេញ ដូច្នេះដើម្បីការពារកុមារដែលជាកម្មវត្ថុនៃសុំកូន យើងគួរតែអាចបកស្រាយប្រដូច ឬ អនុវត្តតាមការបញ្ចប់ទំនាក់ទំនងសុំកូនពេញលេញដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ២.៣.៦. ទណ្ឌកម្ម

ច្បាប់ស្តីពីការសុំកូនអន្តរប្រទេស ត្រូវបានបង្កើតឡើងមិនត្រឹមតែកំណត់អំពីគោលការណ៍លក្ខខណ្ឌនីតិវិធី ទម្រង់បែបបទ និងអានុភាពនៃសុំកូនអន្តរប្រទេសនោះទេ ច្បាប់នេះក៏មានកំណត់អំពីការផ្តន្ទាទោសដល់បទល្មើសដែលពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ហើយការផ្តន្ទាទោសនេះទៀតសោតនឹងអនុវត្តទៅតាមបញ្ញត្តិច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ជាគោលកាណ៍នៅគ្រប់ករណី នៃបទល្មើសទាំងឡាយនឹងទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌ ឬ ទណ្ឌកម្មរដ្ឋប្បវេណី ឬ អាចទទួលទណ្ឌកម្មព្រហ្មទណ្ឌផង និងសំណងរដ្ឋប្បវេណីផង ឬ ការប្រកាសនូវទោសផ្សេងៗទៀតត អាស្រ័យទៅតាមស្ថានភាពទម្ងន់ទោសរបស់ជនល្មើស។

- ទណ្ឌកម្មព្រហ្មទណ្ឌ ជាទោសដាក់ពន្ធនាគារ
- ទណ្ឌកម្មរដ្ឋប្បវេណី ជាទោសពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ ដោយរួមទាំងការប្រកាសនូវទោសបន្ថែមទៀត៖
    - ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេលយ៉ាងច្រើន ៥ឆ្នាំ។
    - ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេលយ៉ាងច្រើន ២ឆ្នាំ។
    - ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងទំព័រសារព័ត៌មាន។
    - ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ថ្ងៃ យ៉ាងច្រើន។

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចព្យួរ ឬ ដកហូតការទទួលស្គាល់ ឬ បដិសេធការទទួលស្គាល់ ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឱ្យឃើញថាទីភ្នាក់ងារសុំកូនអន្តរប្រទេស ជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចតទៅ៖

១. អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឱ្យឪពុកម្តាយ ឬ ឪពុក ឬ ម្តាយបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើត ដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស។

២. អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្ដីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត។

៣. អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្ដីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ។

៤. អំពើក្លែងបន្លំ ឬ សមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬ ឪពុកបង្កើត ឬ ម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។

៥.អំពើរៀបចុះឱ្យមានការយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបង្ខិតបង្ខំ ការគំរាមកំហែង ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្ដល់ ឬ សន្យាផ្ដល់ប្រាក់ រង្វាន់ សំណាង ឬ ផលប្រយោជន៍ណាមួយ។

៦. ការបញ្ចេញសំណុំឯកសារ និងកំណត់ហេតុទាំងអស់ ឬ មួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬ តុលាការមានសមត្ថកិច្ច។

៧. ការបង្គាប់ ឬ ការទទួលដោយផ្ទាល់ ឬ ដោយប្រយោល នូវថ្នូរប្រាក់កាស ទំនិញ ឬ សេវាដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន។

៨.ការផ្ដល់ប្រាក់កាស ទំនិញ ឬ សេវាទៅឱ្យមន្ត្រី ឬ អ្នកតំណាងណាមួយនៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្ដាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ឬ មន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យផ្ដល់នូវសិទ្ធិជាអាទិភាពនៅក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ។

៩. ការផ្សាយពាណិជ្ជកម្ម ឬ ការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬ រូបថតរបស់កុមារណាមួយដែលជាកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយឱ្យដាក់ពាក្យសុំកូន។

១០. ការតែងតាំង ឬ ចាត់តាំងអ្នកតំណាងមួយដោយមិនមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

១១. ការចូលរួមក្នុងការរៀបចំការផ្គូផ្គង ឬ ការទាក់ទងគ្នារវាងអ្នកសុំ និងឪពុកម្ដាយបង្កើត ឬ ឪពុកបង្កើត ឬ ម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារក្នុងគោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ។

១២. ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនអនុវត្ត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១ ០០០ ០០០(មួយលាន) រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល ។ការដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ប្រាក់ពិន័យអន្តរការណ៍នេះត្រូវបង់ចូលនៅក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ។

ក្នុងករណីទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងទៅតុលាការ។

បទល្មើសពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា [80] ។

[80] មាត្រា៥៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។

# ជំពូកទី២
# ការទទួលស្គាល់

ការទទួលស្គាល់ គឺជាមធ្យោបាយមួយសម្រាប់ឱ្យឪពុកដែលមិនត្រូវបានសន្មតថាជាឪពុកតាមមាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណី ធ្វើការទទួលស្គាល់កូន ដើម្បីបានចុះក្នុងសំបុត្រកំណើត។ តាមរយៈក្រមរដ្ឋប្បវេណី បានចែកការទទួលស្គាល់ជា២ ៖ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត និងការទទួលស្គាល់ដោយបង្ខំ។

## ផ្នែកទី១៖ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ការទទួលស្គាល់ដោយស្ម័គ្រចិត្ត គឺជាមធ្យោបាយក្នុងការបង្ហាញឆន្ទៈ របស់បុគ្គលម្នាក់ដែលតាំងនាមជាឪពុក ធ្វើការទទួលស្គាល់បុគ្គលម្នាក់ទៀត ហៅថាកូន។

ទម្រង់នេះ អាចធ្វើបានតែឪពុក ចំពោះកូនតែប៉ុណ្ណោះ។

ឪពុករបស់កូន អាចទទួលស្គាល់កូនបាន។ ប៉ុន្តែ ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ [81] ។

តាមស្មារតីនៃមាត្រានេះ គឺឪពុករបស់កូនមានសិទ្ធិពេញលេញក្នុងការទទួលស្គាល់កូនរបស់ខ្លួន ប៉ុន្តែបើកូននោះមានឪពុកមួយស្របច្បាប់រួចហើយ ច្បាប់មិនអនុញ្ញាតឱ្យមានការទទួលស្គាល់នោះទេ។ មានន័យថា ទោះបីជាឪពុកបង្កើតក៏ដោយ ក៏ច្បាប់មិនអនុញ្ញាតឱ្យធ្វើការទទួលស្គាល់នោះឡើយ។

ឧទាហរណ៍៖ ករណី ក និងខ ជាប្តីប្រពន្ធ មានកូនម្នាក់ឈ្មោះ គ ដោយបានចុះសំបុត្រកំណើតថា ក ជាឪពុក និងខ ជាម្តាយ។ បន្ទាប់មកក៏មានការសង្ស័យថា ឬ មានភាពជាក់ច្បាស់ថាកូននោះជាកូនរបស់ ខ ជាមួយនឹង ឃ។ ទោះបីជាមានភស្តុតាងបញ្ជាក់ថា ឃ ជាឪពុកក៏ដោយ ក៏ ឃ មិនអាចធ្វើការទទួលស្គាល់ គ ដែលជាកូនបានដែរ។

ប៉ុន្តែ អាចបាន បើមានបណ្តឹងបដិសេធបិតុភាពជាមុនសិន ហើយបណ្តឹងបដិសេធបិតុភាពអាចធ្វើឡើងដោយ៖

គ ដាក់ពាក្យបណ្តឹងបដិសេធបិតុភាពចំពោះ ក

ខ ដាក់ពាក្យបណ្តឹងបដិសេធបិតុភាពចំពោះ ក

ឃ មិនអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពចំពោះ ក បានទេ។

[81] មាត្រា៩៩៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ១.១. សមត្ថភាពក្នុងការទទួលស្គាល់កូន

ដើម្បីទទួលស្គាល់ ទោះបីជាឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ពុំបាច់មានការយល់ព្រម ពីអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ [82] ។

មាត្រានេះមានន័យថា ទោះបីជាឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ (បុគ្គលដែលខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព) ក៏ឪពុកនោះអាចទទួលស្គាល់កូននោះដោយស្ម័គ្រចិត្តបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់នោះទេ ប៉ុន្តែលុះណាតែបុគ្គលដែលចង់បង្ហាញឆន្ទៈទទួលស្គាល់នោះ មានសមត្ថភាពខាងឆន្ទៈ ឬអាចមានតិចតួច ព្រោះថា ទោះបីជាបុគ្គលនោះច្បាប់បានកំណត់ថាជាបុគ្គលដែលខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ដោយ ក៏សមត្ថភាពខាងឆន្ទៈជាអប្បបរមា អាចនឹងមាន ដូច្នេះទើបច្បាប់កំណត់យកការបង្ហាញឆន្ទៈក្នុងការទទួលស្គាល់ គឺជាការចាំបាច់។

### ១.២. ការទទួលស្គាល់របស់ឪពុក

ការទទួលស្គាល់ គឺផ្តោតសំខាន់ទៅលើការបង្ហាញឆន្ទៈរបស់ឪពុកក៏ពិតមែន ប៉ុន្តែក៏គួរតែមានការចូលរួមបង្ហាញឆន្ទៈរបស់កូនផងដែរ ។ ដូច្នេះ ច្បាប់ក៏បានកំណត់ករណីមួយចំនួន ដែលត្រូវមានការយល់ព្រម ដូចជា៖

#### ១.២.១. កូនជាអនីតិជន

ឪពុកអាចទទួលស្គាល់កូនដែលជាអនីតិជនបាន [83] ។

មានន័យថា ឪពុកអាចធ្វើការទទួស្គាល់កូនដែលជាអនីតិជនបាន ដោយមិនចាំបាច់មានការយល់ព្រមពីនរណាម្នាក់ឡើយ ទោះបីជាកូន ឬ ពីអ្នកតំណាងដែលច្បាប់បានកំណត់ក៏ដោយ។ ព្រោះថា អនីតិជន មិនអាចបង្ហាញឆន្ទៈយល់ព្រមបានឡើយ ហើយអ្នកតំណាងក៏មិនអាចបង្ហាញឆន្ទៈជំនួសអនីតិជនបានដែរ ព្រោះវាជាទំនាក់ទនងបុគ្គល ហើយការទទួលស្គាល់ គឺធ្វើឡើងដើម្បីផលប្រយោជន៍របស់កូន។

#### ១.២.២. ទារកក្នុងគភ៌

ទោះជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ឪពុកអាចទទួលស្គាល់កូននោះបាន ដោយទទួលការយល់ព្រមពីម្តាយ [84] ។

---

[82] មាត្រា៩៩៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[83] មាត្រា៩៩៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[84] មាត្រា៩៩៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ទាល់តែមានការយល់ព្រមពីម្ដាយនៃកូន ទើបអាចធ្វើការទទួលស្គាល់ ព្រោះថា មានតែម្ដាយប៉ុណ្ណោះដែលដឹងថា ឪពុករបស់ទារកនៅក្នុងគភ៌ជានរណា ម៉្យាងទៀតទារកនៅក្នុងគភ៌ក៏ពុំមានឈ្មោះ ហើយការកំណត់ជាក់លាក់អំពីក្មេងនោះពុំអាចធ្វើទៅបាន ដូច្នេះមានតែម្ដាយប៉ុណ្ណោះដែលអាចបញ្ជាក់អំពីឪពុករបស់កូននោះបាន។

### ១.២.៣. កូនជានីតិជន

ឪពុកដែលមានបំណងចង់ទទួលស្គាល់កូនដែលជានីតិជន មិនអាចទទួលស្គាល់បានឡើយ បើគ្មានការយល់ព្រមពីកូននោះ [85] ។

ឪពុកអាចទទួលស្គាល់កូនដែលជានីតិជនបាន លុះត្រាតែមានការយល់ព្រមពីកូននោះ ព្រោះថាបុគ្គលដែលដល់នីតិភាព អាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបាន ហើយការយល់ព្រមរបស់កូនវាជាភាពចាំបាច់ណាស់ ព្រោះថាពេលខ្លះបុគ្គលដែលជានីតិជននោះ កាលពីនៅជាអនីតិជន ត្រូវបានឪពុកធ្វើបាប ឬ បោះបង់ចោល ដល់ឥឡូវក៏ធ្វើការទទួលស្គាល់ដើម្បីកេញយកផលប្រយោជន៍កូន ឬ ចង់ឱ្យកូនជួយផ្គត់ផ្គង់ជីវភាពរបស់ខ្លួន។

### ១.២.៤. កូនដែលទទួលមរណភាព

ឪពុកអាចទទួលស្គាល់កូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់។ ក្នុងករណីនេះ បើបច្ឆាញាតិផ្ទាល់នោះជាអនីតិជន ត្រូវទទួលការយល់ព្រមពីជននោះ [86] ។

ក្នុងករណីដែលកូនបានទទួលមរណភាពក្នុងអំឡុងពេលដែលមិនទាន់មានការទទួលស្គាល់ ជាគោលការណ៍មិនអនុញ្ញាតឱ្យមានការទទួលស្គាល់ទេ ព្រោះថាភាគីម្ខាងនៃបិតុភាពនោះបានទទួលមរណភាព ដូច្នេះ គ្មានផលប្រយោជន៍អ្វីក្នុងការបង្កើតបិតុភាពនោះទេ ។ ប៉ុន្តែ ក្នុងករណីដែលកូនដែលបានទទួលមរណភាពនោះមានកូន មានន័យថា ឪពុករបស់កូននោះមានចៅ មានផលប្រយោជន៍ជាក់ស្ដែងក្នុងការបង្កើតបិតុភាព ដែលនាំឱ្យមានការបង្កើតទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ជាមួយចៅ ។ កូនដែលទទួលមរណភាពមិនអាចបង្ហាញការយល់ព្រមបាន ដូច្នេះគឺយកការយល់ព្រមរបស់បច្ឆាញាតិរបស់កូននោះ។

**សំគាល់៖** កូនជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ៖ ក្នុងករណីនេះ ក្រមរដ្ឋប្បវេណី គឺមិនបានបញ្ញត្តិនោះទេ។

---

[85] មាត្រា៩៩៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[86] មាត្រា៩៩៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ១.៣. ទម្រង់នៃការទទួលស្គាល់

ការទទួលស្គាល់នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន។ ការទទួលស្គាល់ក៏អាចធ្វើតាមមតកសាសន៍ក៏បានដែរ [87] ។

ការទទួលស្គាល់អាចធ្វើឡើងតាម២ទម្រង់ គឺ ការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន និងតាមមតកសាសាន៍។

#### ១.៣.១. ការទទួលស្គាល់ដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន

ក្នុងករណីកូនបានចុះកំណើតរួចហើយ ដោយមានចុះតែឈ្មោះម្ដាយ ដោយចំហចោលឈ្មោះឪពុក ក្នុងករណីឪពុកបានទទួលស្គាល់កូន ឪពុកត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះឈ្មោះឪពុកនោះនៅក្នុងសៀវភៅកំណើតនោះ។

#### ១.៣.២. ការទទួលស្គាល់តាមមតកសាសន៍

ការទទួលស្គាល់កូនដោយស្ម័គ្រចិត្តត្រូវធ្វើឡើងដោយលិខិតយថាភូត ក៏ប៉ុន្តែ ដោយសារតែនៅកម្ពុជា ប្រព័ន្ធនៃលិខិតយថាភភូតនៅពុំទាន់ត្រូវបានប្រើយ៉ាងទូលំទូលាយនៅឡើយ ទើបក្រមរដ្ឋប្បវេណីបញ្ចូលឱ្យមានការទទួលស្គាល់តាមមតកសាសន៍ដែលជាលិខិតឯកជន។ ករណីនេះ ការទទួលស្គាល់តាមរយៈមតកកសាសន៍ គឺត្រូវធ្វើឡើងដោយអ្នកប្រតិបត្តិមតកសាសន៍ ដោយត្រូវធ្វើការចុះកំណើតឱ្យកូនដែលបានទទួលស្គាល់នោះ។ ក្នុងករណីដែលកូនបានចុះកំណើតរួចហើយ ដោយមានឈ្មោះតែម្ដាយ អ្នកប្រតិបត្តិមតកសាសន៍ត្រូវអនុវត្តតាមមាត្រា៩៩៧ នៃក្រមរដ្ឋប្បវេណី ប៉ុន្តែ បើកូននោះមិនទាន់បានចុះកំណើត អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំចុះកំណើតដោយអនុលោមទៅតាមមាត្រា ៩៩៨ នៃក្រមរដ្ឋប្បវេណី ដោយឱ្យបុគ្គលណាម្នាក់បានសុំចុះកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខា ឬ ផ្តិតមេដៃ នៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវចាត់ទុកថាបានទទួលស្គាល់កូននោះ នៅពេលដែលបានសុំចុះកំណើត។ មានន័យថាប្រសិនបើបុរសណាម្នាក់បានអនុវត្តនូវនីតិវិធីតាមលំដាប់លំដោយដូចដែលបានចែងក្នុងមាត្រានេះ ក្នុងឋានៈជាឪពុករបស់កូន ត្រូវចាត់ទុកថា បុរសនោះបានទទួលស្គាល់កូន ដោយពុំចាំបាច់ជូនដំណឹងអំពីការទទួលស្គាល់ជាថ្មីម្តងទៀតទេ។

[87] មាត្រា៩៩៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ផ្នែកទី២៖ ការទទួលស្គាល់ដោយបង្ខំ

ការទទួលស្គាល់ដោយបង្ខំ គឺជារបបមួយដែលអនុញ្ញាតឱ្យកូនដាក់ពាក្យបណ្តឹងចំពោះឪពុកដែលមិនព្រមទទួលស្គាល់កូននោះ ដោយឱ្យមានការទទួលស្គាល់តាមរយៈសាលក្រម។

ការទទួលស្គាល់ដោយបង្ខំ ដែលឪពុកមិនព្រមទទួលស្គាល់កូន កូនមិនអាចធ្វើការទទួលស្គាល់ឪពុកបានទេ ប៉ុន្តែកូនអាចទាមទារឱ្យឪពុកទទួលស្គាល់ខ្លួនបានតាមរយៈបណ្តឹងទាមទារឱ្យទទួលស្គាល់។

បណ្តឹងទាមទារឱ្យទទួលស្គាល់ ត្រូវអនុលោមតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល [88] ។

### ២.១. បណ្តឹងដែលធ្វើឡើងដោយកូន

កូនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន [89] ។

បណ្តឹងទាមទារឱ្យទទួលស្គាល់ គឺជាបណ្តឹងដែលធ្វើឡើងដោយកូនចំពោះឪពុក។ ប៉ុន្តែ បើកូននោះមិនបានយល់ព្រម នៅពេលដែលឪពុកចង់ទទួលស្គាល់កូន កូនពុំអាចទាមទារឱ្យទទួលស្គាល់បានឡើយ ព្រោះថា ការបដិសេធក្នុងការផ្តល់ការយល់ព្រម ត្រូវបានចាត់ទុកថាជាការបោះបង់ចោលសិទ្ធិក្នុងការទទួលបានការទទួលស្គាល់។

### ២.២.បណ្តឹងដែលធ្វើឡើងដោយបច្ឆាញាតិផ្ទាល់របស់កូន(កូនបានទទួលមរណភាព)

ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ហើយកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ ក្នុងអំឡុងពេល **១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងថាជាឪពុក** [90] ។

### ២.៣. បណ្តឹងដែលធ្វើឡើងដោយកូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះ ដែលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ

ក្នុងករណីដែលកូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុក អំឡុងពេល **១ (មួយ) ឆ្នាំ** ត្រូវគណនា គិតចាប់

[88] មាត្រា៣ ចំណុច ង និងមាត្រា២៦ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១។

[89] មាត្រា១០០១ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[90] មាត្រា១០០១ កថាខណ្ឌទី២ និងទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ពីពេលដែលកូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ [91] ។

កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន នៅក្នុងអំឡុងពេល **១ (មួយ) ឆ្នាំ** គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក ប្រសិនបើបានដឹងថាជាឪពុក នៅក្រោយមរណភាពរបស់ឪពុក [92] ។

## ២.៤. បណ្ដឹងដែលធ្វើឡើងដោយកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន

ក្នុងករណី កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់ជំនួសជនទាំងនោះបាន [93] ។ ម្យ៉ាងទៀត កូន ឬ បច្ឆាញាតិនោះជាអនីតិជន ក៏ជននោះអាចធ្វើបណ្ដឹងទាមទារឱ្យទទួលស្គាល់ដោយខ្លួនឯងបានដែរ ប្រសិនបើអនីតិជននោះមានសមត្ថភាពខាងឆន្ទៈ [94] ។

## ២.៥. បណ្ដឹងដែលធ្វើឡើងដោយកូនជាជននៅក្រោមអាណាព្យាបាលទូទៅ

ប្រសិនបើកូនជាជននៅក្រោមអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅជាអ្នកធ្វើបណ្ដឹងជំនួស [95] ។ យ៉ាងណាមិញ ជននៅក្រោមអាណាព្យាបាលទូទៅក៏អាចធ្វើបណ្ដឹងដោយខ្លួនឯងបានដែរ ឱ្យតែជននោះមានសមត្ថភាពខាងឆន្ទៈ [94] ។

ការទទួលស្គាល់កូន ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូននោះ។ ប៉ុន្តែការទទួលស្គាល់ ពុំអាចបំពានសិទ្ធិដែលតតិយជនបានធ្វើលទ្ធកម្មរួចហើយឡើយ [96] ។ ជាលទ្ធផលនៃអានុភាពប្រតិសកម្ម ឪពុកដែលធ្វើការទទួលស្គាល់ត្រូវបានចាត់ទុកថាបានជាកូនបំណុលក្នុងការចិញ្ចឹមបីបាច់កូនតាំងពីកំណើតរបស់កូន ហើយកូនត្រូវបានចាត់ទុកថាជាសន្តតិជនរបស់ឪពុកដែលធ្វើការទទួលស្គាល់ តាំងពីកំណើតរបស់កូន ដោយការទទួលស្គាល់នោះ មិនអាចបំពានផលប្រយោជន៍តតិយជនបាននោះទេ។

---

[91] មាត្រា២៧ និង១០០១ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[92] មាត្រា១០០១ កថាខណ្ឌទី៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[93] មាត្រា១០០១ កថាខណ្ឌទី៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[94] មាត្រា៨ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១។

[95] មាត្រា៩ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១។

[96] មាត្រា៩៩៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

តើក្រោយពីធ្វើការទទួលស្គាល់ ឪពុកនឹងក្លាយជាអ្នកមានអំណាចមេបាលើកូននោះដែរឬទេ?

ទោះបីជា មានការទទួលស្គាល់ពីឪពុកក៏ដោយ បើក្នុងករណីដែលម្តាយមិនទាន់បានរៀបអាពាហ៍ពិពាហ៍អ្នកមានអំណាចមេបាលើកូន គឺម្តាយដែលបានបង្កើតកូននោះ [97] ។ មានន័យថា បើតាមមាត្រា ៩៨៧ នៃក្រមរដ្ឋប្បវេណី ស្ត្រីដែលសម្រាលកូន គឺជាម្តាយរបស់កូន ហេតុនេះ វត្តមានរបស់ម្តាយមានភាពច្បាស់លាស់។ ដូចច្នេះ ប្រសិនបើស្ត្រីមិនទាន់បានរៀបអាពាហ៍ពិពាហ៍ ផ្តល់កំណើតដល់កូន ស្ត្រីនោះក្លាយជាម្តាយដែលមានអំណាចមេបាលើកូននោះ។

ប៉ុន្តែ ឪពុក អាចធ្វើប្រើប្រាស់អំណាចមេបា ចំពោះកូនដែលខ្លួនបានទទួលស្គាល់បាន តែក្នុងករណីដែលការពិភាក្សារបស់ឪពុកម្តាយ បានកំណត់យកឪពុកនោះ ជាអ្នកមានអំណាចមេបា [98] ។ មានន័យថា ចំពោះកូនដែលត្រូវបានទទួលស្គាល់ ឪពុកអាចក្លាយជាអ្នកមានអំណាចមេបាក្រោយពេលមានការពិភាក្សារវាងឪពុក និងម្តាយ។
តែបើម្តាយមិនយល់ព្រម តុលាការជាអ្នកសម្រេចថា អ្នកណាម្នាក់មានអំណាចមេបា តាមការទាមទាររបស់ឪពុក ឬ ម្តាយ [99] ។

**សំគាល់៖**

បើឪពុក និងម្តាយ មិនបានរៀបអាពាហ៍ពិពាហ៍ទេ ទោះបីជាឪពុកក្លាយជាអ្នកដែលមានអំណាចមេបាក៏ដោយ ឬ ម្តាយជាអ្នកមានអំណាចមេបាក៏ដោយ ក៏វាមិនមែនជាអំណាចមេបាដោយសហការគ្នាដែរ ដោយវានៅតែជាអំណាចមេបាទោលដដែល។

បើក្រោយពេលដែលឪពុកបានទទួលស្គាល់កូនហើយ ហើយឪពុក និងម្តាយ បានរៀបអាពាហ៍ពិពាហ៍ ឪពុកម្តាយត្រូវអនុវត្តអំណាចមេបាដោយសហការ [100] ។

ម្យ៉ាងទៀតបន្ទាប់ពីមានការទទួលស្គាល់ ឪពុកដែលមិនបានរស់នៅជាមួយកូន អាចពិភាក្សាជាមួយម្តាយ អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទងជាមួយកូន និងការទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន [101] ។ ប៉ុន្តែបើការពិភាក្សាពុំបានសម្រេច ឬ បើពុំបានធ្វើការពិភាក្សានោះទេ នោះតុលាការត្រូវធ្វើការកំណត់អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទងជាមួយ

[97] មាត្រា១០៣៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[98] មាត្រា១០៣៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[99] មាត្រា១០៣៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[100] មាត្រា១០៣៨ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[101] មាត្រា១០៤០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

កូន និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬម្ដាយ [102] ។

## ផ្នែកទី៣៖ បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

ឪពុក ដែលបានទទួលស្គាល់កូនហើយ ពុំអាចលុបចោលការទទួលស្គាល់នោះបានឡើយ។ ដូច្នេះ ប្រសិនបើឪពុកបានទទួលស្គាល់កូន ដោយការភាន់ច្រឡំ ការឆបោក ការគំរាមកំហែង ឪពុកនោះមិនអាចលុបចោលការទទួលស្គាល់បានឡើយ។ នេះក៏ព្រោះតែនៅពេលដែលធ្វើការទទួលស្គាល់ គឺជាឪពុករបស់កូនដែលត្រូវបានទទួលស្គាល់ នោះទំនាក់ទំនងឪពុកម្ដាយ និងកូនដែលត្រូវបានបង្កើតឡើងម្ដងហើយ មិនគួរត្រូវបានលុបចោលទេ។ ផ្ទុយមកវិញ ប្រសិនបើគេដឹងថាជនដែលធ្វើការទទួលស្គាល់នោះមិនមែនជាឪពុករបស់កូនដែលត្រូវបានទទួលស្គាល់ទេ នោះអានុភាពនៃការទទួលស្គាល់អាចត្រូវបានបដិសេធដោយពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព [103]។

### ៣.១. បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព (ការបដិសេធបិតុភាព)

បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាព គឺជានីតិវិធីក្នុងការទាមទារទៅតុលាការឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ក្នុងករណីដែលបិតុភាព ឬ មាតុភាពត្រូវបានបង្កើតឡើងដោយផ្ទុយនឹងការពិតជាក់ស្ដែង។ មានន័យថា ក្នុងករណីដែលមានការចុះឈ្មោះបុគ្គលណាម្នាក់ ថាជាឪពុក ឬជាម្ដាយដែលការពិតបុគ្គលដែលបានចុះក្នុងបញ្ជីកំណើតកូន ថាជាឪពុក ឬជាម្ដាយនោះ មិនមែនជាឪពុក ឬជាម្ដាយពិតប្រាកដនៃកូននោះទេ។

តាមមាត្រា៩៧ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ ក៏បានបញ្ញត្តិអំពីការស្វែងរកបិតុភាព ឬមាតុភាព។ ប៉ុន្តែពុំបានចែងអំពីនីតិវិធីបដិសេធមាតុភាព ឬ បិតុភាពដែលផ្ទុយនឹងការពិតទេ។

កូនមានសិទ្ធិទាមទារឱ្យមាននូវបុត្តភាពពិតប្រាកដ អត្ថិភាពនៃបុត្តភាពដែលផ្ទុយនឹងការពិតគឺជាការបំពាសិទ្ធិ ហើយដោយសារតែមានករណីដែលនត្ថិភាពនៃទំនាក់ទំនងលោហិតរវាងឪពុក និងកូន បានស្ដែងចេញមក ក្រោយពេលដែលមានការទទួលស្គាល់ដោយស្ម័គ្រចិត្តរួចហើយ ដូច្នេះទើបមានភាពចាំបាច់ខ្លាំងណាស់ក្នុងការបដិសេធនូវបុត្តភាពដែលផ្ទុយនឹងការពិតនេះ។

[102] មាត្រា១០៤០ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[103] មាត្រា១០០២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ៣.១.១. អ្នកមានសិទ្ធិធ្វើបណ្តឹង

បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពភាពនៃបុត្តភាព អាចធ្វើឡើងដោយៈ

- កូន អាចដាក់ពាក្យបណ្តឹងទៅតុលាការ ឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាពឬ មាតុភាព ចំពោះជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ ឬ ជនដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាគ្មានហេតុដែលបានសម្រាលក៏ដោយ [104] ។

មានន័យថា ក្នុងករណីដែលបិតុភាពត្រូវបានសន្មត វិធីដែលអាចបដិសេធបាន គឺបណ្តឹងបដិសេធបិតុភាព ក្នុងគោលបំណងដើម្បីឱ្យកូនអាចធ្វើការទាមទារឱ្យមានការបញ្ជាក់អំពីនត្ថិភាពនៃបិតុភាព ឬ មាតុភាព ចំពោះករណីដែលគ្មានអត្ថិភាពនៃមូលដ្ឋាននៃបុត្តភាពតាមផ្លូវច្បាប់ ដែលអាចជាៈ

- ➢ បុរសម្នាក់ដែលនៅជាមួយម្តាយរបស់កូន និងមិនមែនជាឪពុករបស់កូន បានដាក់បាក្យសុំចុះសៀវភៅកំណើតកូននៅការិយាល័យអត្រានុកូលដ្ឋាន ក្នុងនាមជាអ្នករស់នៅជាមួយ ហើយក៏ត្រូវបានចុះក្នុងសៀវភៅ ថាជាឪពុករបស់កូននោះ។
- ➢ ការទទួលស្គាល់ដោយក្លែងក្លាយ ដែលបុរសម្នាក់បានទទួលស្គាល់កូនម្នាក់ ទោះបីជាគ្មានទំនាក់ទំនងលោហិតនឹងគ្នាក៏ដោយ។
- ➢ ស្ត្រីម្នាក់សុំចុះសៀវភៅកំណើតកូនដោយក្លែងក្លាយ ដោយអះអាងថា គាត់ជាអ្នកបាន សម្រាលកូននោះ ដែលតាមពិតទៅគាត់មិនបានសម្រាលកូននោះទេ តែជាកូនដែលស្ត្រីផ្សេងទៀតសម្រាល។

- ជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាពជាមួយកូនបាន [105] ។
- ជនដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាមិនបានសម្រាលកូននោះក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃមាតុភាពជាមួយកូនបាន[106]។

មានន័យថា បញ្ញត្តិនេះបានអនុញ្ញាតឱ្យបុគ្គលដែលក្លាយជាម្តាយដោយសារអង្គហេតុក្លែងក្លាយអំពីកំណើយកូន អាចធ្វើការទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃមាតុភាពបាន។

[104] មាត្រា១០០២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[105] មាត្រា១០០២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[106] មាត្រា១០០២ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

- ប្រសិនបើកូនជាអនីតិជន ឪពុក ឬ ម្ដាយ ដែលមិនមែនជាភាគីម្ខាងទៀតនៃបណ្ដឹង ត្រូវធ្វើជាតំណាងឱ្យកូន។ បើគ្មានឪពុកម្ដាយ បើឪពុកម្ដាយមិនអាចធ្វើជាតំណាងបាន ឬ បើបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនបៃបុត្តភាពត្រូវបានធ្វើឡើងចំពោះឪពុកម្ដាយទាំងសងខាង ជាភាគីម្ខាងទៀតនៃបណ្ដឹង តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេស [107] ។

### ៣.១.២. អំឡុងពេលនៃការធ្វើបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ពុំអាចដាក់បានឡើយ ប្រសិនបើបិតុភាព ឬ មាតុភាពតាមផ្លូវច្បាប់ កើតឡើងដោយចេតនា ឬ កំហុសធ្ងន់ធ្ងររបស់ជនដែលត្រូវបានចុះជាឪពុក ឬ ម្ដាយ នៅក្នុងសៀវភៅ ឬ បើអំឡុងពេល **២០ (ម្ភៃ) ឆ្នាំ** បានកន្លងផុត គិតចាប់ពីថ្ងៃកំណើតរបស់កូន ឬ ថ្ងៃដែលអានុភាពនៃការទទួលស្គាល់ បានកើតឡើង [108] ។

តាមស្មារតីនៃមាត្រានេះ វាជាស្ថានភាពមួយធ្ងន់ធ្ងរណាស់សម្រាប់កូន នៅពេលដែលបុត្តភាពក្លាយជានត្ថិភាព ក្រោយពេលកូននោះបានជឿជាក់អស់រយៈពេលជាយូរមកហើយថា បិតុភាព ឬ មាតុភាព ក្លែងក្លាយនោះជាការពិត។ ដោយហេតុនេះបានជាពាក់ព័ន្ធជាមួយនឹងបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាពដែលធ្វើឡើងដោយឪពុកម្ដាយ លទ្ធភាពដែលអាចប្ដឹងបាននោះត្រូវកម្រិតឱ្យតឹងរ៉ឹងបំផុត ។

ឧទាហរណ៍៖ ឪពុកម្ដាយចិញ្ចឹម បានចុះក្នុងសៀវភៅកំណើត ដោយដាក់ថា ជាឪពុកម្ដាយបង្កើតរបស់កូនចិញ្ចឹម ឬ ក្នុងករណីដែលជននោះបានដឹងថា កូនមោះមិនមែនជាកូនរបស់ខ្លួន ប៉ុន្តែបុគ្គលនោះនៅតែចុះក្នុងសៀវភៅកំណើតថា ខ្លួនជាឪពុកម្ដាយ។

ក្នុងករណីដែលបិតុភាព ឬ មាតុភាពតាមផ្លូវច្បាប់កើតឡើងពីកំហុសធ្ងន់ធ្ងររបស់ជនដែលត្រូវបានចុះជាឪពុក ឬ ម្ដាយក្នុងសៀវភៅកំណើត មិនអាចធ្វើបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាពបានទេ។

## ២.២. អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

ការបញ្ជាក់នត្ថិភាពនៃបុត្តភាព ត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ [94] ។

---

[107] មាត្រា១០០២ កថាខណ្ឌទី៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[108] មាត្រា១០០២ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ឧទាហរណ៍៖ ប្រសិនបើឪពុកទទួលស្គាល់កូនអាយុ ១០ឆ្នាំ ម្នាក់ បិតុភាពរវាងឪពុក និងកូននោះ ត្រូវចាត់ទុកថា មានចាប់តាំងពីពេលកំណើតរបស់កូនមក ។ ទោះបីជាឪពុកទទួលមរណភាពមុនពេលមានការទទួលស្គាល់ក៏ដោយ ក៏ជាលទ្ធផលនៃអានុភាពប្រតិសកម្មនៃការទទួលស្គាល់ ហើយកូននោះត្រូវក្លាយជាសន្តតិជនរបស់ឪពុកដែលបានទទួលមរណភាពនោះ។ ម្យ៉ាងទៀត ក្នុងករណីដែលមានបុគ្គលណាម្នាក់បានផ្គត់ផ្គង់កូននោះ នៅក្នុងអំឡុងពេលមានការទទួលស្គាល់ដោយឪពុក ទោះបីជាបុគ្គលនោះគ្មានករណីកិច្ចសោះដូច្នេះក៏ដោយ បញ្ហានៃការទាមទារឱ្យសងមកវិញនូវសេចក្តីសម្រេចដោយឥតហេតុនឹងកើតឡើង ចំពោះទ្រព្យសម្បត្តិដែលបានប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់ ដោយសារឪពុកដែលបានទទួលស្គាល់កូន ត្រូវផ្គត់ផ្គង់កូននោះ ក្នុងឯមឡុងពេលនោះ។ ករណីដែលកូនត្រូវបានទទួលស្គាល់នៅក្រោយការបែងចែកមត៌ក ហើយមត៌កនោះត្រូវបានលក់ទៅឱ្យតតិយជន កូននោះមិនអាចទាមទារឱ្យតតិយជននោះប្រគល់មត៌កដែលបានលក់ទៅហើយ មកឱ្យខ្លួនបាននោះទេ។

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ការសិក្សាប្រធានបទនេះ ពិតជាមានអត្ថប្រយោជន៍ណាស់ ព្រោះការសិក្សានេះបានផ្តល់ពុទ្ធិផ្នែកច្បាប់ ក៏ដូចជារំលេចឱ្យឃើញពីបញ្ហាតូចៗជាច្រើន ដែលផុសចេញតាមរយៈការវិភាគពាក្យពេចន៍ ឱ្យស្របតាមខ្លឹមសារដែលអ្នកតាក់តែងច្បាប់ចង់បាន។ ប្រធានបទសុំកូន និងការទទួលស្គាល់ មានគោលគំនិតសំខាន់ណាស់ ព្រោះជាយុត្តិសាស្ត្រក្នុងការស្វែងរកគ្រួសារមួយដែលមានលក្ខណៈពេញលេញ ដោយឱ្យកុមារដែលជាកម្មវត្ថុ អាចទទួលបានការមើលថែ អប់រំ ការស្រឡាញ់ថ្នាក់ថ្នម និងទទួលបានភាពកក់ក្តៅ ពីសំណាក់អ្នកដែលជាឪពុកម្តាយ ឬអាណាព្យាបាល។

ស្របតាមគោលគំនិតនៃខ្លឹមសារក្នុងស្នាដៃស្រាវជ្រាវ បើភាគីទាំងពីរនៃសុំកូន មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា គេអនុវត្តតាមបញ្ញត្តិស្តីពីសុំកូនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។ ប៉ុន្តែបើភាគីអ្នកសុំជាជនជាតិខ្មែរ រស់នៅបរទេស ឬជាជនបរទេស មានបំណងសុំកុមារដែលមានសញ្ជាតិខ្មែរយកទៅចិញ្ចឹមនៅឯប្រទេសសាមី ឬប្រទេសមួយផ្សេងទៀត គេត្រូវអនុវត្តច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩។ សុំកូនដែលមានចែងក្នុងក្រម និងសុំកូនអន្តរប្រទេស បើយើងប្រៀបធៀប យើងបានឃើញបញ្ហាមួយចំនួន ដែលយើងជាអ្នកសិក្សាគប្បីសិក្សាឱ្យបានច្រើន និងឱ្យកាន់តែស៊ីជម្រៅលើផលវិបាកដែលអាចនឹងកើតមាន ក្នុងអំឡុងពេលអនុវត្តនីតិវិធី និងក្រោយពេលបញ្ចប់នីតិវិធី (ដោយគិតចាប់តាំងពីដើមទីដំបូងនៃការដាក់ចិត្ត ដាក់កាយ ថាចង់សុំកូនចិញ្ចឹម រហូតដល់ការទទួលបានសិទ្ធិយកកូនសុំនោះ មកគ្រប់គ្រង ចិញ្ចឹម។

តាមការសិក្សាបញ្ញត្តិយ៉ាងលម្អិតស្តីពីសុំកូនអន្តរប្រទេស យើងឃើញថាមានលក្ខណៈល្អប្រសើរ ក្នុងការចែងនីតិវិធីច្បាស់លាស់។ ប៉ុន្តែបើយើងក្រឡេកមើលបញ្ញត្តិស្តីពីសុំកូនក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ វិញយើងឃើញថា សុំកូនអន្តរប្រទេសគប្បីត្រូវការអំឡុងពេលសាកល្បងចិញ្ចឹម ដែលរឿងនេះជានីតិវិធីមួយក្នុងការសំដែងឱ្យដឹងពីភាពចុះសម្រុងគ្នាជាមុនសិនរវាងបុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹម ដើម្បីផ្តល់ការងាយស្រួលឱ្យតុលាការធ្វើការសម្រេចសេចក្តី ពីព្រោះថាចំណុចសំខាន់បំផុតដែលយើងចង់បាន គឺអត្តចរិតរបស់អ្នកដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹម។

យោងតាមច្បាប់សិក្សាកន្លងមក នីតិនិពន្ធសរសេរចែងពីអត្តចរិតរបស់ឪពុកម្តាយចិញ្ចឹម និងរបស់កូនសុំមកចិញ្ចឹម ជាកត្តាចំបងក្នុងរឿងសុំកូន។ អត្តចរិតរបស់បុគ្គលគ្រប់រូបមិនអាចលេចឡើងតាមរូបភាពនៃការជួបសំណេះសំណាលជាមួយកុមារ ដែលជាចំណុចដែលមានចែងក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេសនោះទេ។ យ៉ាងណាមិញ បើអ្នកសុំ ធ្លាប់មានជីវប្រវត្តិមិនល្អ ឬអត្តចរិតមិន

ល្អ តែក្រោយមកបុគ្គលនោះមានការភ្ញាក់រឭក មិនប្រព្រឹត្តអំពើអាក្រក់ជាលើកទី២ទេ ពេលនោះគេគប្បីបង្កើតឱ្យមានអំឡុងពេលសាកល្បងចិញ្ចឹម។ ការចិញ្ចឹមសាលល្បងនេះ គួរកំនត់ពេលមួយសមស្របយ៉ាងហោចណាស់ ៦(ប្រាំមួយ)ខែ ដូចអ្វីដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែរ។

ជាចុងបញ្ចប់ ក្នុងនាមយើងទាងអស់គ្នាជាពលរដ្ឋខ្មែរ ត្រូវចូលរួមលុបបំបាត់ ឬបញ្ចៀសឱ្យខាងតែបាននូវអំពើជួញដូរកុមារ ធ្វើបាបកុមារ តាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ ជាពិសេសសុំកុំឱ្យការសុំកូនពាក់ព័ន្ធនឹងប្រធានបទនេះ ក្លាយជាការមិនបានគោរព និងអនុវត្តតាមច្បាប់ ដែលកំពុងមានជាធរមានរួចហើយ។ បុគ្គលដែលពាក់ព័ន្ធនឹងបញ្ហាសុំកូនទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តនីតិវិធីនីមួយៗឱ្យបានល្អ ម៉ត់ចត់ ជាពិសេសការត្រួតពិនិត្យសំណុំឯកសារអ្នកសុំឱ្យបានល្អិតល្អន់ និងពិនិត្យពិច័យឱ្យគ្រប់ជ្រុងជ្រោយ មុននឹងឈានទៅរកការសម្រេចចិត្តមួយដែលល្អ ត្រឹមត្រូវ និងយុត្តិធម៌។

# ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- វចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត
- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
- ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
- អនុសញ្ញាស្ដីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩
- ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១
- ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង ឆ្នាំ២០១១
- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ដែលរៀបចំដោយ គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០
- សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១២
- ច្បាប់ស្ដីពីសញ្ជាតិ ឆ្នាំ១៩៩៦
- ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាទីក្រុងឡាអេស្ដីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ឆ្នាំ២០០៧
- ច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩
- កម្រងមេរៀននៃវិភាគទានច្បាប់ ឆ្នាំ២០១៥

# ឧបសម្ព័ន្ធ១

**ក្រុមរដ្ឋប្បវេណី ឆ្នាំ២០០៧**

ខែ បានកន្លងផុត គិតចាប់ពីពេលដែលខ្លួនបានក្លាយជានីតិជន ។

៤-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ បានកន្លងផុត បើកូនជាជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

**មាត្រា ៩៩២.-** អានុភាពប្រតិសកម្មនៃបណ្តឹងបដិសេធបិតុភាព

ការបដិសេធបិតុភាព ត្រូវបង្កើតអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូន ។

## កថាភាគទី ៣
## ការទទួលស្គាល់

**មាត្រា ៩៩៣.-** ការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ឪពុករបស់កូន អាចទទួលស្គាល់កូនបាន ។ ប៉ុន្តែ ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ ។

**មាត្រា ៩៩៤.-** សមត្ថភាពក្នុងការទទួលស្គាល់

ដើម្បីទទួលស្គាល់ ទោះបីជាឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ពុំចាំបាច់មានការយល់ព្រម ពីអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ ។

**មាត្រា ៩៩៥.-** ការទទួលស្គាល់របស់ឪពុក

១-ឪពុកអាចទទួលស្គាល់កូនដែលជាអនីតិជនបាន ។

២-ទោះជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ឪពុកអាចទទួលស្គាល់កូននោះបាន ដោយទទួលការយល់ព្រមពីម្តាយ ។

**មាត្រា ៩៩៦.-** ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព

១-ឪពុកដែលមានបំណងចង់ទទួលស្គាល់កូនដែលជានីតិជន មិនអាចទទួលស្គាល់

បានឡើយ បើគ្មានការយល់ព្រមពីកូននោះ ។

២-ឪពុកអាចទទួលស្គាល់កូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់ ។ ក្នុងករណីនេះ បើបច្ឆាញាតិផ្ទាល់នោះជានីតិជន ត្រូវទទួលការយល់ព្រមពីជននោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៩៩៧ (ទម្រង់នៃការទទួលស្គាល់) ខាងក្រោមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ ។

**មាត្រា ៩៩៧.-** ទម្រង់នៃការទទួលស្គាល់

១-ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ។ ការទទួលស្គាល់ ក៏អាចធ្វើតាមមតកសាសន៍ក៏បានដែរ ។

២-ការយល់ព្រមរបស់ម្ដាយ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៩៥ (ការទទួលស្គាល់របស់ឪពុក) ខាងលើនេះ អាចធ្វើបាន ដោយចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ ។

**មាត្រា ៩៩៨.-** អានុភាពនៃការចុះកំណើតនៅក្នុងសៀវភៅកំណើតនិងការទទួលស្គាល់

បើបុគ្គលណាម្នាក់បានសុំចុះកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខា ឬ ផ្ដិតមេដៃ នៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវចាត់ទុកថា បានទទួលស្គាល់កូននោះ នៅពេលដែលបានសុំចុះកំណើត ។

**មាត្រា ៩៩៩.-** អានុភាពប្រតិសកម្មនៃការទទួលស្គាល់

ការទទួលស្គាល់កូន ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ ការទទួលស្គាល់ ពុំអាចបំពានសិទ្ធិដែលតតិយជនបានធ្វើលទ្ធកម្មរួចហើយឡើយ ។

**មាត្រា ១០០០.-** ការហាមឃាត់មិនឱ្យដកការទទួលស្គាល់ចេញ

ឪពុកដែលបានទទួលស្គាល់កូនហើយ ពុំអាចលុបចោលការទទួលស្គាល់នោះបាន

ឡើយ ។

**មាត្រា ១០០១.-** បណ្តឹងទាមទារឱ្យទទួលស្គាល់

១-កូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ។ ប៉ុន្តែ កូនដែលមិនបានយល់ព្រម តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩៩៦ (ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព) នៃក្រមនេះ ពុំអាចទាមទារឱ្យទទួលស្គាល់បានឡើយ ។

២-ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ។

៣-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាឪពុក ។

៤-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុក អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគណនា គិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៥-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក ប្រសិនបើបានដឹងថាជាឪពុក នៅក្រោយមរណភាពរបស់ឪពុក ។

៦-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ ជំនួសជនទាំងនោះបាន ។

## កថាភាគទី ៤
## បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

**មាត្រា ១០០២.-** បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

១-កូន អាចដាក់ពាក្យបណ្តឹងទៅតុលាការ ឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាព ឬ មាតុភាព ចំពោះជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ ឬ ជនដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាគ្មានហេតុដែលបានសម្រាលក៏ដោយ ។

២-ជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាពជាមួយកូនបាន ។

៣-ជនដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាមិនបានសម្រាលកូននោះក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃមាតុភាពជាមួយកូនបាន ។

៤-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ពុំអាចដាក់បានឡើយ ប្រសិនបើបិតុភាព ឬ មាតុភាពតាមផ្លូវច្បាប់ កើតឡើងដោយចេតនា ឬ កំហុសធ្ងន់ធ្ងររបស់ជនដែលត្រូវបានចុះជាឪពុក ឬ ម្តាយ នៅក្នុងសៀវភៅ ឬ បើអំឡុងពេល ២០ (ម្ភៃ) ឆ្នាំ បានកន្លងផុត គិតចាប់ពីថ្ងៃកំណើតរបស់កូន ឬ ថ្ងៃដែលអានុភាពនៃការទទួលស្គាល់ បានកើតឡើង ។

៥-ប្រសិនបើកូនជាអនីតិជន ឪពុក ឬ ម្តាយ ដែលមិនមែនជាភាគីម្ខាងទៀតនៃបណ្តឹង ត្រូវធ្វើជាតំណាងឱ្យកូន ។ បើគ្មានឪពុកម្តាយ បើឪពុកម្តាយមិនអាចធ្វើជាតំណាងបាន ឬ បើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាពត្រូវបានធ្វើឡើងចំពោះឪពុកម្តាយទាំងសងខាង ជាភាគីម្ខាងទៀតនៃបណ្តឹង តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេស ។

**មាត្រា ១០០៣.-** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីនត្តិភាពនៃបុត្តភាព

ការបញ្ជាក់នត្តិភាពនៃបុត្តភាព ត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

## កថាភាគទី ៥

## បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

**មាត្រា ១០០៤.-** បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីកូន

១-កូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះស្ត្រីដែលបានបង្កើតខ្លួនបាន ។

២-ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

៣-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាម្តាយ ។

៤-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលបានដឹងថាជាម្តាយ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគណនា ដោយគិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៥-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ម្តាយ ប្រសិនបើបានដឹងថាជាម្តាយ នៅក្រោយមរណភាពរបស់ម្តាយ ។

៦-បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់អត្ថិភាពនៃមាតុភាព ជំនួសជនទាំងនោះបាន ។

**មាត្រា ១០០៥.–** បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីម្ដាយ

១-ម្ដាយ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះកូនដែលខ្លួនបានបង្កើតបាន ។

២-ម្ដាយ អាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់ ។

៣-ម្ដាយ ត្រូវដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលខ្លួនបានដឹងថាជាកូន ។

៤-ម្ដាយ អាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់កូន ប្រសិនបើបានដឹងថាជាកូន នៅក្រោយមរណភាពរបស់កូន ។

៥-ប្រសិនបើម្ដាយជាជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌ ទី ៣ និង ទី ៤ ខាងលើនេះ បានកន្លងផុត អំឡុងពេលនៃកថាខណ្ឌទី ៣ និង ទី ៤ ខាងលើនេះ ត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៦-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូន ដែលជាភាគីម្ខាងនៃបណ្ដឹងជានីតិជន បើគ្មានការយល់ព្រមពីកូន ឬ បច្ឆាញាតិផ្ទាល់នោះទេ ម្ដាយមិនអាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បានឡើយ ។

៧-ទោះបីជាក្នុងករណីដែលអង្គហេតុនៃការបង្កើតកូន ត្រូវបានបញ្ជាក់ក៏ដោយ ប្រសិនបើការបញ្ជាក់មាតុភាព ផ្ទុយនឹងផលប្រយោជន៍របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ តុលាការអាចលើកចោលបណ្ដឹងរបស់ម្ដាយបាន ។

**មាត្រា ១០០៦.-** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្តិភាពនៃមាតុភាព

ការបញ្ជាក់អំពីអត្តិភាពនៃមាតុភាពត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

## ផ្នែកទី ២

## សុំកូន

### កថាភាគទី ១

### សុំកូនពេញលេញ

**មាត្រា ១០០៧.-** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបាន ។

**មាត្រា ១០០៨.-** សុំកូនដោយសហការរវាងប្តីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្តាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

**មាត្រា ១០០៩.-** អាយុរបស់ឪពុកម្តាយចិញ្ចឹម

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមាន

អាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ១០១០.-** អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

**មាត្រា ១០១១.-** ការយល់ព្រមរបស់ឪពុកម្តាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្តាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ១០១២.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្តាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០១៣.-** អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

**មាត្រា ១០១៤.-** ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមក

អនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្ដាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្ដាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) នៃក្រមនេះ ។

**មាត្រា ១០១៥.-** អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និងករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្ដាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។

**មាត្រា ១០១៦.-** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាគីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្ដាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-បើមានការធ្វើបាបដោយឪពុកម្ដាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ-បើឪពុកម្ដាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០១៧.-** អានុភាពនៃការកាត់កាល់ស៊ុំកូនពេញលេញ

ញាតិភាពរវាងកូនស៊ុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយស៊ុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

**មាត្រា ១០១៨.-** ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃស៊ុំកូនពេញលេញ

ប្រសិនបើបានបង្កើតស៊ុំកូនពេញលេញ បញ្ជីកំណើតរបស់កូនស៊ុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្តីពីស៊ុំកូនឡើយ ។

**មាត្រា ១០១៩.-** សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនស៊ុំពេញលេញ

កូនស៊ុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្តីពីស៊ុំកូនបាន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទ-ប្បញ្ញត្តិរបស់តុលាការ ។

## **កថាភាគទី ២**
## **ស៊ុំកូនធម្មតា**

**មាត្រា ១០២០.-** ពាក្យសុំនៃស៊ុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនស៊ុំ ទៅតុលាការ ឱ្យបង្កើតស៊ុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនស៊ុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនស៊ុំ ជាអនីតិជន អ្នកមានអំណាច

មេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

**មាត្រា ១០២១.-** ករណីដែលបុគ្គលដែលនឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹម មានសហព័ទ្ធ

បើបុគ្គលដែលមានសហព័ទ្ធ សុំកូនដែលជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលយកកូនរបស់សហព័ទ្ធ មកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២២.-** ការយល់ព្រមរបស់សហព័ទ្ធ

ចំពោះបុគ្គលដែលមានសហព័ទ្ធ ដើម្បីដាក់ពាក្យសុំនៃសុំកូនធម្មតា ត្រូវទទួលការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២៣.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនធម្មតា

១-តុលាការ អាចឱ្យបង្កើតសុំកូនបាន លុះត្រាតែករណីដែលអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និង កូន ។

២-តុលាការមិនត្រូវឱ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត ។

**មាត្រា ១០២៤.-** ករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន

១-បើបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជន

នោះ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន បើឳពុកម្ដាយបង្កើតរបស់បុគ្គលនោះបានលែងលះហើយ តុលាការត្រូវសួរយោបល់របស់ឳពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើអនីតិជនបានដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតស្មុំកូន ត្រូវទទួលការយល់ព្រមពីអនីតិជននោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០២៥.-** ស្មុំកូន រវាងអ្នកអាណាព្យាបាល និង ជននៅក្រោមអាណាព្យាបាល

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យសុំឱ្យបង្កើតស្មុំកូន ដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួន មកធ្វើជាកូនសុំ ឬ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ដាក់ពាក្យសុំឱ្យបង្កើតស្មុំកូន ដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួន មកធ្វើជាកូនសុំ តុលាការអាចឱ្យបង្កើតស្មុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតួនាទីរបស់អ្នកអាណាព្យាបាលបានចប់ តែមិនទាន់បានបញ្ចប់ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រង ។

**មាត្រា ១០២៦.-** អានុភាពនៃស្មុំកូនធម្មតា ចំពោះបុគ្គភាព

១-ទោះបីជាមានការបង្កើតស្មុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និង ឳពុកម្ដាយបង្កើត ត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឳពុកម្ដាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ។

២-កូនសុំ និង ឳពុកម្ដាយបង្កើត មានសិទ្ធិទាមទារ និង ករណីយកិច្ចផ្គត់ផ្គង់

អាហារកាតព្វកិច្ច ។

**មាត្រា ១០២៧.–** អានុភាពនៃសុំកូន ក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម ជាអាទិ៍

១-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១០១៥ (អានុភាពនៃសុំកូនពេញលេញ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសុំកូនធម្មតា ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-ក្នុងករណីដែលកូនសុំ ជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធ មកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្តាយចិញ្ចឹម និង សហព័ទ្ធនោះ ។

**មាត្រា ១០២៨.–** ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា

១-ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យកាត់កាល់សុំកូនបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ ។

២-ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ដោយឪពុកម្តាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ។ ប៉ុន្តែ បើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ហើយ ត្រូវទទួលការយល់ព្រមពីកូនសុំនោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើឪពុកម្តាយបង្កើតរបស់កូនសុំ បានលែងលះគ្នាហើយ ឪពុកម្តាយបង្កើតរបស់កូនសុំនោះ ត្រូវពិភាក្សា និង កំណត់ថា ឪពុក ឬ ម្តាយបង្កើត ជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា នៅក្រោយពេលកាត់កាល់ ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូន ។

**មាត្រា ១០២៩.-** ការកាត់កាល់រវាងប្ដីប្រពន្ធដែលបានសុំកូនដោយសហការ និង កូនសុំជាអនីតិជន

ក្នុងករណីដែលប្ដីប្រពន្ធដែលបានសុំកូនដោយសហការគ្នា ជាឪពុកម្ដាយចិញ្ចឹម ដើម្បីកាត់កាល់កូនសុំជាអនីតិជន ប្ដីប្រពន្ធត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស៊ុំកូនធម្មតា) ខាងលើនេះ ជាមួយគ្នា ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះប្ដីប្រពន្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈរបស់ខ្លួន ។

**មាត្រា ១០៣០.-** ការវិនិច្ឆ័យអំពីការកាត់កាល់ស៊ុំកូនធម្មតា

បើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស៊ុំកូនធម្មតា) ខាងលើនេះ តុលាការអាចសម្រេចឱ្យកាត់កាល់ស៊ុំកូនបាន លុះត្រាតែបានបញ្ជាក់ថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។

**មាត្រា ១០៣១.-** មូលហេតុនៃការកាត់កាល់

១-ភាគីម្ខាងនៃស៊ុំកូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យកាត់កាល់បាន លុះត្រាតែក្នុងករណីខាងក្រោមនេះ :

ក-បើត្រូវបានបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត ។

ខ-បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព ។

គ-បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្ដាលឱ្យមានការពិបាកក្នុងការបន្តស៊ុំកូន ។

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្ដាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជាអនីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស្មុំកូនធម្មតា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនសុំដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្ដាយចិញ្ចឹម ។

**មាត្រា ១០៣២.-** អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា

១-អានុភាពទាំងឡាយនៃស្មុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនស្មុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន ។

**មាត្រា ១០៣៣.-** ការចុះបញ្ជីនៃស្មុំកូនធម្មតា និង បញ្ជីកំណើត

ប្រសិនបើបានបង្កើតស្មុំកូនធម្មតា ត្រូវសរសេរការបង្កើតស្មុំកូនធម្មតា នៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

# ជំពូកទី ៥

# អំណាចមេបា

## ផ្នែកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១០៣៤.-** អត្ថន័យនៃអំណាចមេបា

អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយ

# ឧបសម្ព័ន្ធ២

## ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ១៩៨៩

**មាត្រា ៩៣.-** ក្រោយពេលដែលឪពុក ឬ ម្តាយបានប្តឹងចុះកំណើតកូន ឪពុក ឬ ម្តាយណាដែលមិនទាន់ទទួលស្គាល់ឪពុក ឬម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

**មាត្រា ៩៤.-** កូនឥតខាន់ស្លាដែលឪពុកម្តាយបានទទួលស្គាល់នឹងទៅជាកូនមានខាន់ស្លាបាន បើក្រោយពីកំណើតរបស់កូននោះ ឪពុកម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នានឹងពេលចុះអាពាហ៍ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

## ផ្នែកទី ៣

## អំពីការស្វែងរកបិតុភាព ឬ មាតុភាព នៃកូនឥតខាន់ស្លា

**មាត្រា ៩៥.-** បើគ្មានលិខិតធ្វើទទួលស្គាល់ ដោយស្ម័គ្រចិត្តនូវកូនឥតខាន់ស្លាទេ នោះតុលាការប្រជាជនអាចតម្រូវឱ្យឪពុក ឬ ម្តាយទទួលស្គាល់កូននោះបាន ។

**មាត្រា ៩៦.-** កូនឥតខាន់ស្លាដែលឪពុក ឬ ម្តាយមិនបានទទួលស្គាល់ មានសិទ្ធិប្តឹងសុំឱ្យតុលាការប្រជាជនរកឪពុក ឬ រកម្តាយឱ្យខ្លួនបាន ។

**មាត្រា ៩៧.-** បណ្តឹងសុំឱ្យតុលាការប្រជាជន តម្រូវឱ្យឪពុក ឬ ម្តាយទទួលស្គាល់នោះ អាចធ្វើឡើងក្នុងរយៈពេល ២ ឆ្នាំ គិតពីថ្ងៃដែលកូននោះមាននីតិភាព ។

នីតិភាពត្រូវកំណត់ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅ ។

ក្នុងពេលដែលកូនឥតខាន់ស្លា នៅក្នុងអនីតិភាពនៅឡើយ អ្នកអាណាព្យាបាលរបស់កូននោះមានសិទ្ធិប្តឹងជួស សុំឱ្យតុលាការប្រជាជន រកមាតុភាពឱ្យកូននោះ ។

**មាត្រា ៩៨.-** តុលាការប្រជាជន អាចតម្រូវឱ្យនារីជាម្តាយទទួលស្គាល់កូនឥតខាន់ស្លាបាន បើមានភស្តុតាងបញ្ជាក់ថា :

ក- នារីនោះបានបង្កើតកូនប្រាកដមែន

ខ- អត្តសញ្ញាណរបស់កូនដែលនារីនោះបានបង្កើត និង អត្តសញ្ញាណរបស់កូន ដែលប្តឹងទាមទាររកមាតុភាព នោះមិនខុសប្លែកពីគ្នា ។

ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ ។

**មាត្រា ៩៩.-** តុលាការប្រជាជន អាចតំរូវឱ្យបុរសជាឪពុកទទួលស្គាល់កូនឥតខាន់ស្លាបាន :

១-បើបុរសនោះបាននាំពង្រត់ ឬ បានចាប់រំលោភសេពសន្ថវៈនារីជាម្តាយដោយរំលោភ ហើយបើសម័យនាំពង្រត់ ឬ ចាប់រំលោភសេពសន្ថវៈនោះ ត្រូវគ្នានឹងសម័យដែលនារីនោះមានគភ៌ ។

២-បើបុរសនោះបានខ្លួននារី ដោយឧបាយកលបោកបញ្ឆោតដោយការរំលោភអំណាច ឬ ដោយការសន្យាថា នឹងរៀបអាពាហ៍ពិពាហ៍ជាមួយនារីនោះ ។

៣-បើមានភស្តុតាងជាលាយលក្ខណ៍អក្សរពីបុរសនោះ បង្ហាញឱ្យឃើញច្បាស់ថា បុរសនោះពិតជាឪពុករបស់កូននោះ ។

៤- បើបុរស នឹង នារីជាឪពុកម្តាយ និង ជាម្តាយរបស់កូននោះ បានរួមរស់ និងគ្នាជាអនីតិសង្វាសជាក់ស្តែងក្នុងសម័យនីត្យានុកូលដែលនារីនោះមានគភ៌ ។

៥- បើបុរសនោះបានផ្គត់ផ្គង់ ឬ បានចូលរួមក្នុងការបីបាច់រក្សា និង ការអប់រំកូននោះក្នុងឋានៈខ្លួនជាឪពុក ។

**មាត្រា ១០០**- ពាក្យដែលប្តឹងរកបិតុភាពមិនអាចនឹងទទួលបាន :

១- បើមានភស្តុតាងថា នារីជាម្តាយមានទំនាក់ទំនងកាមគុណនឹងប្រុសដទៃទៀត ក្នុងសម័យនីត្យានុកូលដែលនារីនោះមានគភ៌ ។

២- បើក្នុងសម័យនីត្យានុកូលដែលនារី មានគភ៌បុរសដែលត្រូវប្រកាន់ថា ជាឪពុករបស់កូននោះ គ្មានលទ្ធភាពរួមដំណេកជាមួយនារីជាម្តាយនោះ ដោយរស់នៅឆ្ងាយពីគ្នា ឬ ដោយមកពីមានគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា ៨៦ ។

**មាត្រា ១០១**- ក្នុងពេលដែលកូនឥតខាន់ស្លា នៅក្នុងអនីតិភាពនៅឡើយ ម្តាយ ឬ អ្នកអាណាព្យាបាលនៃកូននោះអាចប្តឹងសុំឱ្យរកបិតុភាពបាន ។

ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ ។

**មាត្រា ១០២**- សាលក្រមដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា មានអនុភាពដូចគ្នានឹងលិខិតដែលទទួលស្គាល់កូនដោយស្ម័គ្រចិត្តដែរ ។

**មាត្រា ១០៣**- កូនឥតខាន់ស្លា ត្រូវយកត្រកូលរបស់ឪពុក ឬ ម្តាយដែលទទួលស្គាល់ខ្លួន ។ ប្រសិនបើឪពុក និង ម្តាយទាំងពីរនាក់ទទួលកូននោះ ត្រូវយកត្រកូលរបស់ឪពុក ។

ប្រសិនបើតុលាការប្រជាជន តម្រូវឱ្យឪពុក ឬ ម្តាយទទួលស្គាល់កូននោះ ត្រូវយកត្រកូលរបស់អ្នក ដែលតុលាការតម្រូវឱ្យទទួលស្គាល់ ។

ប្រសិនបើតុលាការប្រជាជនតម្រូវឱ្យឪពុក និង ម្តាយទាំងពីរនាក់ទទួលស្គាល់ កូននោះត្រូវយកត្រកូលរបស់ឪពុក ។

**មាត្រា ១០៤**- កូនឥតខាន់ស្លា ដែលត្រូវបានទទួលស្គាល់មានករណីយកិច្ច និង មានសិទ្ធិដូចគ្នានឹងកូនមានខាន់ស្លាដែរ ។

**មាត្រា ១០៥**~ តុលាការប្រជាជន ត្រូវបង្គាប់ឱ្យឪពុក ឬ ម្តាយផ្តល់អាហារកិច្ចឱ្យកូនជាដរាប តាមសមាមាត្រនៃធនធានរបស់ឪពុក ឬ ម្តាយនោះ ។

អាហារកិច្ចនេះ ត្រូវផ្តល់ឱ្យកូនតាមការកំណត់នៃសាលក្រម រហូតដល់កូននោះ មាននីតិភាព ។

ឪពុក ឬ ម្តាយអាចត្រូវឱ្យរួចពីកាតព្វកិច្ចនេះបាន បើខ្លួនព្រមទទួលយកកូននោះទៅចិញ្ចឹមបីបាច់រក្សា ។

**មាត្រា ១០៦**~ សាលក្រមដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា អាចនឹងបង្ខំឱ្យឪពុកសងសោហ៊ុយសំរាលកូន និង ប្រាក់ចំណាយចិញ្ចឹមបីបាច់រក្សាកូនតាំងពីថ្ងៃដែលកូននោះកើតមក ទៅម្តាយនៃកូននោះបាន ។

**មាត្រា ១០៧**~ កំណត់ដៃមួយច្បាប់នៃសាលក្រមស្ថាពរដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា ត្រូវផ្ញើទៅមន្ត្រីអត្រានុកូលដ្ឋាន នៃទីកន្លែងដែលកូននោះកើត ដើម្បីនិទ្ទេសអំពីបុគ្គភាពនេះ នៅរឹមទំព័រនៃសំបុត្រកំណើត ។

## ផ្នែកទី ៤

## អំពីសុំកូន

**មាត្រា ១០៨**~ សុំកូន គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀត ហៅថា កូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នា ដូចជាបុគ្គភាពមានខាន់ស្លា ។

**មាត្រា ១០៩**~ ឪពុក ឬ ម្តាយចិញ្ចឹម ត្រូវមានអាយុលើសពី ២៥ ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនចិញ្ចឹមយ៉ាងតិច ២០ ឆ្នាំ ។ ឪពុក ឬ ម្តាយចិញ្ចឹមអាចជាពលរដ្ឋកម្ពុជា ឬ ជនបរទេស ។

**មាត្រា ១១០**~ គេអាចសុំកូនបានត្រឹម ២ នាក់ប៉ុណ្ណោះ ។ ប្រសិនបើកូនដែលសុំមកនោះ មានមួយណាស្លាប់ គេអាចសុំកូនមួយនាក់ទៀតបាន ។

-កូនចិញ្ចឹម ត្រូវមានអាយុតិចជាង ៨ ឆ្នាំ ។

**មាត្រា ១១១**~ សហព័ន្ធណាមួយអាចនឹងសុំកូនយកមកចិញ្ចឹមបាន លុះត្រាតែមានការយល់ព្រមពីសហព័ន្ធរបស់ខ្លួន ។

ក្នុងករណីនេះ កូនចិញ្ចឹមត្រូវទុកជាកូនចិញ្ចឹមរបស់សហព័ន្ធទាំងពីរនាក់ ។

**មាត្រា ១១២**~ ដើម្បីឱ្យការសុំកូនសំរេចទៅបានត្រូវមានការព្រមព្រៀងពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលនៃកូនដែលសុំនោះ ។

បើជាទារកដែលគេបោះបង់ចោល ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំ ឬ សង្កាត់ ។

**មាត្រា ១១៣**~ កិច្ចសន្យាសុំកូន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយបញ្ជាក់ដោយគណៈកម្មាធិការប្រជាជន ឃុំ ឬ សង្កាត់ខាងលំនៅនៃអ្នកសុំ ឬ ខាងលំនៅនៃកូនចិញ្ចឹម ។ សេចក្ដីនៃកិច្ចសន្យាសុំកូននោះ ត្រូវចុះក្នុងបញ្ជីអាត្រានុកូលដ្ឋាន ។

តុលាការប្រជាជន អាចបដិសេធកិច្ចសន្យាខាងលើនេះបាន តាមពាក្យប្ដឹងសុំរបស់កូនចិញ្ចឹម របស់ជនទាំងឡាយ ឬ របស់អង្គការផ្សេងៗ ដែលធ្វើឡើងដើម្បីផលប្រយោជន៍របស់កូនចិញ្ចឹមនោះ ។

**មាត្រា ១១៤**~ កូនចិញ្ចឹមត្រូវយកនាមត្រកូលនៃអ្នកសុំហើយមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើត ។

## ផ្នែកទី ៥

## អំពីទំនាក់ទំនងរវាងឪពុក ម្ដាយ និង កូន

**មាត្រា ១១៥**~ ឪពុកម្ដាយមានករណីយកិច្ចត្រូវស្រឡាញ់កូន ចិញ្ចឹមបីបាច់រក្សាកូន និង យកចិត្តទុកដាក់អប់រំកូន គឺបណ្ដុះគំនិតកូនអោយស្រឡាញ់ការរៀនសូត្រ ស្នេហាមាតុភូមិ មានស្មារតី សាមគ្គីអន្តរជាតិ ស្រឡាញ់ពលកម្ម គោរពទ្រព្យសម្បត្តិរដ្ឋ គោរពសិទ្ធិ និង ទ្រព្យសម្បត្តិ របស់អ្នកដទៃ ។

កូនមានករណីយកិច្ចត្រូវស្រឡាញ់ និង គោរពឪពុកម្ដាយ ថែទាំរក្សា ឪពុក ម្ដាយ និង ផ្គត់ផ្គង់ សេចក្ដីត្រូវការរបស់ឪពុក ម្ដាយ ។

**មាត្រា ១១៦**~ ឪពុក ម្ដាយ មិនត្រូវធ្វើបាបកូនរបស់ខ្លួន កូនប្រសា កូនចិញ្ចឹម ឬ កូនរបស់ប្ដី ឬ របស់ប្រពន្ធមុនឡើយ ។

**មាត្រា ១១៧**~ កូនប្រសា និង កូនស្រីមានសិទ្ធិ និង ករណីយកិច្ចដូចគ្នាក្នុងគ្រួសារ ។

**មាត្រា ១១៨**~ កូនមាននីតិភាព ដែលរស់នៅជាមួយ ឪពុកម្ដាយ មានសេរីភាពក្នុងការជ្រើសរើសមុខរបររបស់ខ្លួន មានសេរីភាពក្នុងការចូលរួមសកម្មភាពនយោបាយ និង សកម្មភាពសង្គម មានសេរីភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ម្យ៉ាងវិញទៀត ក៏ត្រូវមានករណីយកិច្ចត្រូវមើលខុសត្រូវ ដោះស្រាយជីវភាពរួម របស់គ្រួសារ ។

## ផ្នែកទី ៦

## អំពីការដកហូតអំណាចមេបា

**មាត្រា ១១៩**~ អាចនឹងដកហូតអំណាចមេបា ហើយប្រគល់ទៅអង្គការណាមួយ ឬញាតិលោហិតណាមួយ ចំពោះ ឪពុក ម្ដាយ ដែល មានកំហុសដូចខាងក្រោម :

- ឪពុក ម្ដាយ មានការខ្វះខាតក្នុងការអប់រំ
- ឪពុក ម្ដាយ ប្រើអំណាចដោយរំលោភទៅលើកូនដោយប្រើឧបាយផ្សេងៗ ដើម្បីបង្ខំកូនឱ្យប្រព្រឹត្តបទល្មើស ឬ អំពើណាមួយប៉ះពាល់ដល់សង្គម ។

- ឪពុក ម្ដាយ ប្រព្រឹត្តផ្ទុយពីសីលធម៌បណ្ដាលឱ្យមានឥទ្ធិពលអាក្រក់ដល់កូន ។

មាត្រា ១២០- តុលាការប្រជាជន អាចវិនិច្ឆ័យសំរេចដកហូតអំណាចមេបាពីឪពុកម្ដាយ ដែលមានកំហុសបាន លុះត្រាតែមានពាក្យប្ដឹងសុំរបស់អង្គការរដ្ឋ អង្គការមហាជន រដ្ឋអាជ្ញាអមតុលាការប្រជាជន ឬ ញាតិលោហិតណាមួយនៃឪពុកម្ដាយនោះ ។

មាត្រា ១២១- ការហូតអំណាចមេបា បណ្ដាលឱ្យឪពុកម្ដាយ លែងមានសិទ្ធិ ដែលខ្លួនធ្លាប់មានពីមុនចំពោះ កូនរបស់ខ្លួន ប៉ុន្តែនៅមានកាតព្វកិច្ចចិញ្ចឹមបីបាច់ទៀត រហូតដល់កូននេះចូលនីតិភាព ។ ក្នុងករណីនេះ តុលាការប្រជាជនត្រូវកំណត់ជីវិតអាហារកិច្ច ដែលឪពុកម្ដាយត្រូវផ្ដល់ទៅឱ្យ អង្គការ ឬ ញាតិលោហិតដែលទទួលបន្ទុកចិញ្ចឹមកូននោះ ។

មាត្រា ១២២- ដើម្បីផលប្រយោជន៍របស់កូន ច្បាប់អនុញ្ញាតឱ្យតុលាការប្រជាជនប្រគល់ ទៅឪពុកម្ដាយ ដែលត្រូវបានដកហូតអំណាចមេបានូវអំណាចមេបានេះឡើងវិញប្រសិនបើឪពុកម្ដាយនោះបានកែប្រែគំនិត មារយាទរបស់ខ្លួនបានល្អឡើងវិញគួរឱ្យទទួលបន្ទុកអប់រំកូនបានលើកលែងតែចំពោះកូនចិញ្ចឹម ។

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័ត នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៨៩ ក្នុងសម័យប្រជុំសាមញ្ញលើកទី ១៧ នីតិកាលទី ១ ។

ភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩

ជ. រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា : ជា ស៊ីម

# ឧបសម្ព័ន្ធ៣

**ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង**

**ឆ្នាំ២០១១**

**តារាងឧបសម្ព័ន្ធ**

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ១ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី២ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការប្រកាសអត្ថាធិនភាពចំពោះអនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា២១ (ល័ក្ខខ័ណ្ឌនៃអត្ថាធីនភាព) | តុលាការនៃលំនៅឋានរបស់អនីតិជន |
| | ២ ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ និងការលុបចោលនូវការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់ជនដែលត្រូវបានដាក់ពាក្យសុំឱ្យចាប់ផ្តើមអាណាព្យាបាលទូទៅ |
| | ៣ ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅដោយយោងតាមបញ្ញត្តិនៃមាត្រា២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ |
| | ៤ ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ និងការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា២៨ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) | តុលាការនៃលំនៅឋានរបស់ជនដែលត្រូវបានដាក់ពាក្យសុំឱ្យចាប់ផ្តើមហិតូបត្ថម្ភ |
| | ៥ ការចាត់ចែងទាក់ទងនឹងហិតូបត្ថម្ភ ដែលបានកំណត់នៅក្នុងចំណុច ៣ មាត្រា៣០ (សិទ្ធិលុបចោលសកម្មភាព) | តុលាការនៃលំនៅឋានរបស់ជននៅក្រោមហិតូបត្ថម្ភ |
| | ៦ ការលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ដោយយោងតាមបញ្ញត្តិនៃមាត្រា៣១ (ការលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ) | តុលាការនៃលំនៅឋានរបស់ជននៅក្រោមហិតូបត្ថម្ភ |
| | ៧ ការចាត់ចែងទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន ដោយយោងតាមបញ្ញត្តិនៃមាត្រា៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) | តុលាការនៃលំនៅឋានចុងក្រោយរបស់បុគ្គលដែលអវត្តមាន |
| | ៨ ការចាត់ចែងទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន ដោយយោងតាមបញ្ញត្តិពីមាត្រា៣៨ (ការលុបចោលការបង្គាប់ឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) ដល់មាត្រា៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការដែលចេញដីកាសម្រេចដោយផ្អែកលើមាត្រា៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) |
| | ៩ ការប្រកាសអំពីការបាត់ខ្លួន ដោយយោងតាមបញ្ញត្តិនៃមាត្រា៤១ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន) | តុលាការនៃលំនៅឋានចុងក្រោយរបស់បុគ្គលដែលអវត្តមាន |
| | ១០ ការលុបចោលការប្រកាសអំពីការបាត់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា៤៤ (ការចាត់ចែងពេលបុគ្គលដែលបាត់ខ្លួនត្រឡប់មកវិញ) | តុលាការដែលប្រកាសអំពីការបាត់ខ្លួន ដោយផ្អែកលើមាត្រា៤១ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសការបាត់ខ្លួន) |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ១ | ១១ ការជ្រើសតាំងអភិបាលបណ្តោះអាសន្ន ដោយយោងតាមបញ្ញត្តិនៃមាត្រា៦០ (អភិបាលបណ្តោះអាសន្ន) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១២ ការជ្រើសតាំងអ្នកតំណាងពិសេស ដោយយោងតាមបញ្ញត្តិនៃមាត្រា៦១ (អ្នកតំណាងពិសេស) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៣ ការបង្គាប់ឱ្យរំលាយនីតិបុគ្គល ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា៦៥ (បណ្តឹងទាមទារការរំលាយ) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៤ ការជ្រើសតាំងអ្នកជម្រះបញ្ជី ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា៦៨ (ការកាន់តំណែងនៃអ្នកជម្រះបញ្ជី) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៥ ការដកហូតតំណែងរបស់អ្នកជម្រះបញ្ជី ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា៦៩ (ការដកហូតតំណែងរបស់អ្នកជម្រះបញ្ជី) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៦ ការអនុញ្ញាតឱ្យសង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៧៤ (ការសងក្នុងអំឡុងពេលដើម្បីបង្ហាញសិទ្ធិលើបំណុល) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៧ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៧៦ (ការសងសិទ្ធិលើបំណុល) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៨ ការជ្រើសតាំងអ្នករក្សាទុក ដោយយោងតាមបញ្ញត្តិនៃមាត្រា៨១ (ការរក្សាទុកឯកសារ) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៩ ការជ្រើសតាំងអធិការ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៨៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ២០ ការជំនុំជម្រះឱ្យផ្លាស់ប្តូរ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៤ មាត្រា៨៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ២១ ការអនុញ្ញាតឱ្យកោះប្រជុំមហាសន្និបាត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា៩៣ (មហាសន្និបាតវិសាមញ្ញ) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ២២ ការបំពេញបង្គ្រប់លក្ខន្តិកៈរបស់នីតិបុគ្គលមូលនិធិ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១២ (ការបំពេញបង្គ្រប់លក្ខន្តិកៈ) | តុលាការនៃលំនៅឋានរបស់អ្នកបង្កើតនីតិបុគ្គលពេលទទួលមរណភាព |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



Ksl

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ២ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៣ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃមាត្រា១៨៥ (កម្មសិទ្ធិនៃបាតទន្លេ ឬស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី) | តុលាការដែលបានកំណត់នៅក្នុងមាត្រា១៨៥ (កម្មសិទ្ធិនៃបាតទន្លេ ឬស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី) |
| ៣ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៤ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការអនុញ្ញាតឱ្យអនុវត្តសិទ្ធិឧបាទេសកម្ម ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៤២៣ (ល័ក្ខខ័ណ្ឌដើម្បីអនុវត្តសិទ្ធិឧបាទេសកម្ម) | តុលាការនៃលំនៅឋានរបស់កូនបំណុល |
| | ២ ការអនុញ្ញាតឱ្យលក់ដេញថ្លៃនូវវត្ថុដែលជាកម្មវត្ថុនៃការសង ដោយយោងតាមបញ្ញត្តិនៃមាត្រា៤៥៨ (សិទ្ធិលក់ដោយខ្លួនឯង) | តុលាការនៃកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច |
| ៤ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៧ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការសម្រេចសេចក្តីជំនួសការយល់ព្រមចំពោះអាពាហ៍ពិពាហ៍របស់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា៩៤៣ (ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជន |
| | ២ ការចាត់ចែងទាក់ទងនឹងចំណែកបន្ទុកនៃសោហ៊ុយដែលកើតឡើងពីអាពាហ៍ពិពាហ៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៧១ (ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍) | តុលាការនៃលំនៅឋានរបស់ភាគីម្ខាងទៀត |
| | ៣ ការសម្រេចសេចក្តីអំពីការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៤ មាត្រា៩៧៤ (ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ |
| | ៤ ការអនុញ្ញាតឱ្យចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៩៧៦ (ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ) | តុលាការនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ |
| | ៥ ពាក្យសុំលែងលះដោយការព្រមព្រៀង ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៧៩ (ការលែងលះដោយការព្រមព្រៀង) | តុលាការនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ |
| | ៦ ការបែងចែកទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៨០ (ការបែងចែកទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ |
| | ៧ ពាក្យសុំឱ្យបង្កើតសុំកូនពេញលេញ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០០៧ (ទម្រង់នៃការបង្កើតសុំកូនពេញលេញ) | តុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៨ ការទាមទារឱ្យបង្ហាញនូវសំណុំរឿងអំពីស្មុំកូនពេញលេញ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០១៩ (សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ) | តុលាការដែលរក្សាទុកនូវសំណុំរឿងអំពីស្មុំកូនពេញលេញ |
| | ៩ ពាក្យសុំឱ្យបង្កើតស្មុំកូនធម្មតា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០២០ (ពាក្យសុំនៃស្មុំកូនធម្មតា) | តុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយទៅជាកូនសុំ |
| | ១០ ពាក្យសុំឱ្យកាត់កាល់ស្មុំកូនដោយការព្រមព្រៀង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១០២៨ (ពាក្យសុំឱ្យកាត់កាល់ស្មុំកូនធម្មតា) | តុលាការនៃលំនៅឋានរបស់កូន |
| | ១១ ការកំណត់អ្នកមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា១០៣៨ (ទំនាក់ទំនងរវាងការទទួលស្គាល់ និងអំណាចមេបា) | តុលាការនៃលំនៅឋានរបស់កូន |
| | ១២ ការផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៣៩ (ការផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់កូន |
| | ១៣ ការសម្រេចសេចក្តីអំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទង និងចំណែកបន្ទុកនៃសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៤ និងកថាខណ្ឌទី៥ មាត្រា១០៤០ (សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន) | តុលាការនៃលំនៅឋានរបស់កូន |
| | ១៤ ការសម្រេចសេចក្តីជំនួសការពិភាក្សា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៤១ (សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន) | តុលាការនៃលំនៅឋានរបស់អ្នកមានអំណាចមេបា |
| | ១៥ ការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៤៨ (ការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកមានអំណាចមេបា |
| | ១៦ ការលុបចោលនូវការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៤៩ (ការលុបចោលនូវការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកដែលបានទទួលការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា |
| | ១៧ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១០៥០ (ការលាឈប់ និងបដិទានរបស់អ្នកមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានអំណាចមេបា |
| | ១៨ ការអនុញ្ញាតឱ្យទទួលបដិទាននូវអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៥០ (ការលាឈប់ និងបដិទានរបស់អ្នកមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យទទួលបដិទាននូវអំណាចមេបា |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ១៩ ការប្រកាសការផ្លាស់ប្តូរអ្នកមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៥១ (ការផ្លាស់ប្តូរអ្នកមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់កូន |
| | ២០ ការជ្រើសតាំង និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) | តុលាការនៃលំនៅឋានរបស់កូន |
| | ២១ ការចាត់ចែងទាក់ទងនឹងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិជាអាទិ៍) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី៤ មាត្រា១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) | តុលាការដែលចេញដីកាសម្រេច ដោយផ្អែកលើកថាខណ្ឌទី២ ឬកថាខណ្ឌទី៣ មាត្រា១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) |
| | ២២ ការព្យួរ ឬការដកហូតសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៦១ (ការប្រកាសការព្យួរ ឬការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អ្នកមានអំណាចមេបា |
| | ២៣ ការលុបចោលការប្រកាសការព្យួរ ឬការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៦២ (ការលុបចោលការប្រកាសការព្យួរ និងការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អ្នកដែលបានទទួលការប្រកាសការព្យួរ ឬការដកហូតសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ |
| | ២៤ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១០៦៣ (ការលាឈប់ និងបដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ |
| | ២៥ ការអនុញ្ញាតឱ្យទទួលបដិទាននូវសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៦៣ (ការលាឈប់ និងបដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យទទួលបដិទាននូវសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ |
| | ២៦ ការជ្រើសតាំងអ្នកតំណាងពិសេស ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៦៥ (ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និងកូនមានភាពផ្ទុយគ្នា) | តុលាការនៃលំនៅឋានរបស់កូន |
| | ២៧ ការចាត់ចែងទាក់ទងនឹងអ្នកជំនួសអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ នៃមាត្រា១០៣៨(ទំនាក់ទំនងរវាងការទទួលស្គាល់ និងអំណាចមេបា) មាត្រា១០៣៩(ការផ្លាស់ប្តូរអ្នកមានអំណាចមេបា) កថាខណ្ឌទី៤ និងកថាខណ្ឌទី៥ នៃមាត្រា១០៤០ (សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយដែលមិន | តុលាការដែលមានសមត្ថកិច្ចដែលបានកំណត់នៅក្នុងចំណុចនីមួយៗ ចាប់ពីចំណុច១១ ដល់ចំណុច២៦ |

ព្រះបរមរាជវាំង
ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL *

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
| --- | --- | --- |
| ៤ | រស់នៅជាមួយកូន) កថាខណ្ឌទី២ នៃមាត្រា១០៤១ (សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន) មាត្រា១០៤៨ (ការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា) មាត្រា១០៤៩ (ការលុបចោលនូវការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា) កថាខណ្ឌទី១ នៃមាត្រា១០៥០ (ការលាឈប់ និងបដិទានរបស់អ្នកមានអំណាចមេបា) កថាខណ្ឌទី២ នៃមាត្រា១០៥១ (ការផ្លាស់ប្តូរអ្នកមានអំណាចមេបា) កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) កថាខណ្ឌទី៤ នៃមាត្រា១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) មាត្រា១០៦១ (ការប្រកាសការព្យួរ ឬការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) មាត្រា១០៦២ (ការលុបចោលការប្រកាសការព្យួរ និងការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) កថាខណ្ឌទី១ នៃមាត្រា១០៦៣ (ការលាឈប់ និងបដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) កថាខណ្ឌទី២ នៃមាត្រា១០៦៣ (ការលាឈប់ និងបដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ឬមាត្រា ១០៦៥ (ករណី ដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និងកូនមានភាពផ្ទុយគ្នា) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា ១០៦៦ (អ្នកជំនួសអំណាចមេបា) | |
| | ២៨ ការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និងមូលដ្ឋាននៃការជ្រើសតាំង) ឬកថាខណ្ឌទី២ មាត្រា១០៧៥ (អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ និងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ២៩ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៧១ (ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣០ ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិ នៃមាត្រា១០៧៣ (ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៣១ ការចាត់ចែងទាក់ទងនឹងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៧១ (ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា១០៧៣ (ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) ឬមាត្រា១០៨៨ (កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា១០៧៨ (បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣២ ការពន្យារអំឡុងពេលធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា១០៨១ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និងការធ្វើបញ្ជីសារពើភ័ណ្ឌ) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣៣ ការអនុញ្ញាតឱ្យចាត់ចែងអចលនវត្ថុដែលប្រើជាលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៨៥ (ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣៤ ការជ្រើសតាំងអ្នកតំណាងពិសេស ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៦៥(ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និងកូនមានភាពផ្ទុយគ្នា) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា១០៨៦ (សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអនីតិជននៅក្រោមអាណាព្យាបាល មានភាពផ្ទុយគ្នា) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣៥ ការផ្តល់កម្រៃចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៨៨ (កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣៦ ការគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ ឬការចាត់ចែងផ្សេងទៀតដែលទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៨៩ (ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣៧ ការជ្រើសតាំង និងការផ្លាស់ប្តូរអ្នកអនុវត្តគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៣៨ ការចាត់ចែងទាក់ទងនឹងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិជាអាទិ៍) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី៤ មាត្រា១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) | តុលាការដែលចេញដីកាសម្រេច ដោយផ្អែកលើកថាខណ្ឌទី២ ឬកថាខណ្ឌទី៣ នៃមាត្រា១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) |
| | ៣៩ ការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១០៩៥ (ល័ក្ខខ័ណ្ឌនៃការរួចពីអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៤០ ការពន្យាអំឡុងពេលសម្រាប់ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រង ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា១០៩៧ (ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ វត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៤១ ការចាត់ចែងទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជនដែលអនុវត្តអំណាចមេបាជំនួស ចំពោះកូនរបស់អនីតិជននៅក្រោមអាណាព្យាបាល ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ នៃមាត្រា១០៨១ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និងការធ្វើបញ្ជីសារពើភ័ណ្ឌ) មាត្រា១០៨៥ (ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) មាត្រា១០៨៦ (សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអនីតិជននៅក្រោមអាណាព្យាបាលមានភាពផ្ទុយគ្នា) មាត្រា១០៨៨ (កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) កថាខណ្ឌទី២ នៃមាត្រា១០៨៩ (ការត្រួតពិនិត្យតួនាទីរបស់អាណាព្យាបាលសម្រាប់អនីតិជន) កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) កថាខណ្ឌទី៤ នៃមាត្រា១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) កថាខណ្ឌទី១ នៃមាត្រា១០៩៥ (ល័ក្ខខ័ណ្ឌនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន) ឬវាក្យខណ្ឌទី២ កថាខណ្ឌទី១ នៃមាត្រា១០៩៧ (ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ វត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន) ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី២ មាត្រា១១០៣(ការអនុវត្តអំណាចមេបាជំនួសអនីតិជននៅក្រោមអាណាព្យាបាល) | តុលាការដែលមានសមត្ថកិច្ចដែលបានកំណត់នៅក្នុងចំណុចនីមួយៗ ចាប់ពីចំណុច ៣២ ដល់ចំណុច៤០ |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៤២ ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ឬអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា១១០៥ (ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ) ឬមាត្រា១១១០ (អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៣ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៤ ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៥ ការចាត់ចែងពាក់ព័ន្ធនឹងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) មាត្រា១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) មាត្រា១១២១ (ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) ឬមាត្រា១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា១១១៣ (បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៦ ការពន្យារអំឡុងពេលសម្រាប់ការធ្វើបញ្ជីសារពើភណ្ឌ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា១១១៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និងការធ្វើបញ្ជីសារពើភណ្ឌ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៧ ការពន្យារអំឡុងពេលសម្រាប់ការធ្វើបញ្ជីសារពើភណ្ឌ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា១១១៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និងការធ្វើបញ្ជីសារពើភណ្ឌ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយបញ្ញត្តិនៃមាត្រា១១១៨ (ការយកមកអនុវត្តដូចគ្នា ចំពោះករណីដែលជននៅក្រោមអាណាព្យាបាលទូទៅ បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៨ ការអនុញ្ញាតឱ្យចាត់ចែងអចលនវត្ថុដែលប្រើជាលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១២១ (ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL *

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៤៩ ការជ្រើសតាំងអ្នកតំណាងពិសេស ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៦៥ (ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និងកូនមានភាពផ្ទុយគ្នា) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា១១២២ (សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលទូទៅ និងជននៅក្រោមអាណាព្យាបាលទូទៅមានភាពផ្ទុយគ្នា) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៥០ ការផ្តល់កម្រៃចំពោះអ្នកអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៥១ ការរាយការណ៍អំពីតួនាទីនៃអាណាព្យាបាលទូទៅ ការដាក់បញ្ជីសារពើភ័ណ្ឌ ការស្រាវជ្រាវអំពីជីវភាព ការថែទាំព្យាបាល ឬស្ថានភាពទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ការចាត់ចែងដែលទាក់ទងនឹងជីវភាព ការថែទាំព្យាបាល ឬការគ្រប់គ្រងទ្រព្យសម្បត្តិ ឬការចាត់ចែងផ្សេងទៀតដែលទាក់ទងនឹងអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១២៥ (ការត្រួតពិនិត្យតួនាទីអ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៥២ ការជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា១១៣០ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យជននៅក្រោមអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៥៣ ការចាត់ចែងទាក់ទងនឹងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិជាអាទិ៍) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី៤ មាត្រា១១៣០ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអ្នកនៅក្រោមអាណាព្យាបាលទូទៅ) | តុលាការដែលចេញដីកាសម្រេចដោយផ្អែកលើកថាខណ្ឌទី២ ឬកថាខណ្ឌទី៣ នៃមាត្រា១១៣០ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអ្នកនៅក្រោមអាណាព្យាបាលទូទៅ) |
| | ៥៤ ការពន្យារអំឡុងពេលសម្រាប់ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រង ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា១១៣១ (ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៥៥ ការចាត់ចែងទាក់ទងនឹងហិតូបត្ថម្ភកៈ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២និងកថាខណ្ឌទី៣ នៃមាត្រា១១០៥ (ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ) មាត្រា១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) មាត្រា១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី២ មាត្រា១១៣៧ (ការជ្រើសតាំងហិតូបត្ថម្ភកៈ) | តុលាការនៃលំនៅឋានរបស់ហិតូបត្ថម្ភកៈ |
| | ៥៦ ការជ្រើសតាំងហិតូបត្ថម្ភកៈជាបណ្តោះអាសន្ន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ ឬកថាខណ្ឌទី៤ មាត្រា១១៣៧ (ការជ្រើសតាំងហិតូបត្ថម្ភកៈ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមហិតូបត្ថម្ភ |
| | ៥៧ ការជ្រើសតាំងអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១១៣៨ (អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមហិតូបត្ថម្ភ |
| | ៥៨ ការចាត់ចែងទាក់ទងនឹងអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) មាត្រា១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) ឬមាត្រា១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី២ មាត្រា១១៣៨ (អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមហិតូបត្ថម្ភ |
| | ៥៩ ការចាត់ចែងទាក់ទងនឹងហិតូបត្ថម្ភកៈ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) ឬមាត្រា១១២៥ (ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលទូទៅ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី៣ មាត្រា១១៣៩ (តួនាទីរបស់ហិតូបត្ថម្ភកៈ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមហិតូបត្ថម្ភ |
| | ៦០ ការចាត់ចែងទាក់ទងនឹងអាហារកាតព្វកិច្ច ដោយយោងតាមបញ្ញត្តិពីមាត្រា១១៤០ (ទំហំ និងលំដាប់នៃជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច) ដល់ មាត្រា១១៤៣ (ការផ្លាស់ប្តូរ ឬលុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ច) | តុលាការនៃលំនៅឋានរបស់ភាគីម្ខាងទៀត |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៨ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការកំណត់អ្នកទទួលបន្តនូវសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ មាត្រា១១៤៧ (ការទទួលបន្តនូវមត៌ក) ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី៣ នៃកថាខណ្ឌដដែលនោះ | តុលាការនៃលំនៅឋានរបស់មតកជន ឬកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២ ការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន និងការលុបចោលនូវការផ្តាច់មត៌កនោះ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) មាត្រា១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) និងមាត្រា១១៥៤ (ការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន) | តុលាការនៃលំនៅឋានរបស់មតកជន ឬកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៣ ការបញ្ជាក់មតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម ឬលំនៅឋានរបស់ម្ចាស់បណ្តាំ |
| | ៤ ការលុបចោលអច្ច័យទាន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៩៣ (ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៥ ការពិនិត្យបញ្ជាក់លិខិតមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២១៣ (ការពិនិត្យបញ្ជាក់ និងការបើកលិខិតមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៦ ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា១២១៨ (ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៧ ការផ្តល់កម្រៃចំពោះអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិ នៃកថាខណ្ឌទី២ មាត្រា១២២៦ (កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៨ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកប្រតិបត្តិមតកសាសន៍ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា១២២៧ (ការលាឈប់ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៩ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១២៣១ (ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១០ ការអនុញ្ញាតឱ្យបោះបង់ភាគបម្រុង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៤៦ (ការបោះបង់ភាគបម្រុង) | តុលាការនៃលំនៅឋានរបស់មតកជន |
| | ១១ ការពន្យារអំឡុងពេលនៃការយល់ព្រម ឬការបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា ១២[illegible] (អំឡុងពេលនៃការយល់ព្រម ឬការបោះបង់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
| --- | --- | --- |
| ៥ | ១២ ការទទួលពាក្យសុំលុបចោលការយល់ព្រមដោយមានកម្រិត ឬការបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា ១២៥២(ការលុបចោលការយល់ព្រម ឬការបោះបង់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៣ ការទទួលពាក្យសុំយល់ព្រមសន្តតិកម្មដោយមានកម្រិត ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៥៧ (វិធីនៃការយល់ព្រមដោយកម្រិត) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៤ ការទទួលពាក្យសុំបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៦០ (ការបោះបង់សន្តតិកម្ម) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៥ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៦៤ (អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៦ ការចាត់ចែងដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី ៣ មាត្រា ១២៦៤ (អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៧ ការបែងចែកមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ១២៧០ (ការបែងចែកដោយតុលាការ) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៨ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៩ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា១២៨៦ (ការប្តូរមត៌កជាប្រាក់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២០ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៨៩ (ករណីដែលមានសន្តតិជនច្រើននាក់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២១ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២២ ការអនុញ្ញាតឱ្យចាត់ចែងទាក់ទងនឹងការគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៩២ (សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៣ ការផ្តល់កម្រៃចំពោះអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៩៣ (កម្រៃសម្រាប់អ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ២៤ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ឬកថាខណ្ឌទី១ មាត្រា១២៨៦ (ការប្តូរមត៌កជាប្រាក់) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី២ មាត្រា១២៩៦ (ការជូនដំណឹងជាសាធារណៈ និងការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៥ ការចាត់ចែងទាក់ទងនឹងការគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៦ ការចាត់ចែងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៩៩ (ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

# ឧបសម្ព័ន្ធ៤

## ច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# សុំកូនអន្តរប្រទេស

Www.KhmerFamous.Com

# ព្រះរាជក្រម

នស/រកម/១២០៩/០២៨

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ [illegible]ទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ស្មុំកូនអន្តរប្រទេស

ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង
LE MINISTÈRE DU PALAIS ROYAL

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ពីគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទ និង អានុភាពនៃសុំកូនអន្តរប្រទេស ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងធានានូវឧត្តមប្រយោជន៍ និង ការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពលើការសុំកុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្តីប្រពន្ធ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀត ដើម្បីយកទៅចិញ្ចឹមជាកូន ដែលទទួលស្គាល់ដោយច្បាប់នៅប្រទេសនោះ ។

**មាត្រា ៤.-**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ការថែទាំជំនួស** សំដៅដល់ការថែទាំ ដែលផ្តល់ទៅឱ្យកុមារកំព្រា និង កុមារងាយរងគ្រោះ ដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតនៃកុមារទាំងនោះ ។
- **កុមារដែលត្រូវការនូវការថែទាំពិសេស** សំដៅដល់កុមារពិការផ្នែករាងកាយសម្បទាធ្ងន់ធ្ងរ ឬ ពិការផ្នែកស្មារតី ឬ កុមារដែលមានជំងឺរ៉ាំរ៉ៃ ។
- **កុមារដែលត្រូវបោះបង់ចោល** សំដៅដល់កុមារដែលអាជ្ញាធរមានសមត្ថកិច្ចរកឃើញ ឬ ត្រូវបានសាធារណជនរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច និង ជាកុមារដែលមិនស្គាល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ជាកុមារដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបោះបង់ចោល និង រកមិនឃើញអ្នកទាំងនោះ យ៉ាងតិច ៥ (ប្រាំ) ខែជាប់គ្នា ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**- ជនម្នាក់** សំដៅដល់ជនដែលគ្មានសហព័ទ្ធស្របច្បាប់ ។

**- ទីភ្នាក់ងារសុំកូនអន្តរប្រទេស** សំដៅដល់ទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលកូនសុំ ដើម្បីធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

**- ចុន្តភាព** សំដៅដល់ក្រសែញាតិ ដែលទាក់ទងពីឪពុកម្តាយទៅកូនបង្កើតរបស់ខ្លួន ។

**- ប្រទេសលំនៅឋានអចិន្ត្រៃយ៍** សំដៅដល់ប្រទេសដែលជនណាមួយកំពុងរស់នៅដោយមានបំណងយកប្រទេសនោះធ្វើជាលំនៅឋានអចិន្ត្រៃយ៍ ។ ជននោះត្រូវបានទទួលស្គាល់ដោយច្បាប់នៃប្រទេសដែលខ្លួនរស់នៅ ថាមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសនោះ ។

**- មណ្ឌលកុមារកំព្រា** សំដៅដល់មណ្ឌលរបស់រដ្ឋ ឬ របស់អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ចិញ្ចឹមថែទាំ និង ផ្តល់នូវតម្រូវការជាមូលដ្ឋានគ្រប់យ៉ាងក្នុងការអភិវឌ្ឍរបស់កុមារដែលគ្មានឪពុកម្តាយ ឬ គ្មានឪពុក ឬ គ្មានម្តាយ ឬ កុមារ ដែលត្រូវបោះបង់ចោល ឬ កុមារដែលឪពុកម្តាយ ឬ អ្នកអាណាព្យាបាលពុំមានលទ្ធភាពផ្តល់ការថែទាំគ្រប់គ្រាន់ ។

**- ប្តីប្រពន្ធ** សំដៅដល់បុរសម្នាក់ និង ស្ត្រីម្នាក់ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ។

**- សុំកូនដោយសាច់ញាតិ** សំដៅដល់ការសុំកូនដោយអ្នកសុំនូវកុមារដែលត្រូវជាចៅរបស់ខ្លួន ចៅទួតរបស់ខ្លួន ក្មួយរបស់ខ្លួន ឬ កុមារដែលត្រូវជាកូន ចៅ ចៅទួត ឬ ក្មួយរបស់សហព័ទ្ធរបស់ខ្លួន ។

**- សុំកូនពេញលេញ** សំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ ជាឪពុកម្តាយ និង កូនរវាងឪពុកម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម និង កូនសុំ និង បញ្ចប់សិទ្ធិ និង កាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលស្របច្បាប់ពីមុនរបស់ខ្លួន ។

**- អ្នកសុំ** សំដៅដល់ប្តីប្រពន្ធដែលកំពុងស្វះស្វែងសុំកុមារយកទៅចិញ្ចឹម ។

**- ឪពុកម្តាយចិញ្ចឹម** សំដៅដល់ប្តីប្រពន្ធដែលបានទទួលសិទ្ធិជាផ្លូវការពី

តុលាការមានសមត្ថកិច្ច ឱ្យធ្វើជាឪពុកម្តាយថ្មីនៃកូនសុំស្របតាមបទប្បញ្ញត្តិដូចមានចែង ក្នុងច្បាប់នេះ ។

## ជំពូកទី ២
## គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស

**មាត្រា ៥.-**

សុំកូនអន្តរប្រទេសត្រូវអនុវត្តតាមគោលការណ៍ដូចតទៅ :

១- កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និង ការយោគយល់ ដើម្បីឱ្យមានការអភិវឌ្ឍពេញលេញ និង យ៉ាងសុខដុម នូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។ សុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធ-ភាពផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឱ្យកុមាររស់នៅក្នុងគ្រួសារកំណើត និង ក្រោយពីបានធ្វើការពិចារណា អំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- សុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែជាសុំកូនពេញលេញ ដែលបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និង កូនសុំជាអចិន្ត្រៃយ៍ និង ដែលផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ ។

៣- កុមារទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌដូចមានចែងក្នុង មាត្រា ១០ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើងអំពី ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាព ឬ ស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬ របស់ឪពុកម្តាយ ឬ របស់ឪពុក ឬ របស់ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិ-ជនរបស់កុមារ ។

៤- រាល់ការសម្រេច និង សកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេស ត្រូវគិតគូរឱ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ ។

៥- តុលាការ និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការសុំកូន អន្តរប្រទេសត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលមានសមត្ថភាព អាចយល់ដឹងសត្រូវ ត្រូវបានពិគ្រោះយោបល់ និង ពន្យល់ណែនាំឱ្យបានត្រឹមត្រូវអំពីអានុភាព

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

135
Kol

នានា ដែលកើតចេញពីសុំកូននេះដោយគិតគូរដល់សេចក្តីប្រាថ្នា និង មតិរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ ។

៦- ហាមការធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេស ។ អាជីវកម្ម ឬ សកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសមាន :

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឱ្យបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើតដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត និង

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

៧- អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេស មិនបណ្តាលឱ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និង ត្រូវបង្ការមិនឱ្យមានការចាប់ពង្រត់ ការលក់ និង ការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស ។ មានតែប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាន ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវបង់ ។

## ជំពូកទី ៣

## អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

**មាត្រា ៦.–**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ។

**មាត្រា ៧.-**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមានតួនាទី និង ភារកិច្ចដូចតទៅ :

១- រៀបចំ និង ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និង នីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស ។

២-ធ្វើសហប្រតិបត្តិការ និង ធ្វើការសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នា ទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និង ទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង ជាមួយអាជ្ញាធរកណ្តាល និង អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសទទួល ។

៣- ចាត់វិធានការសមស្របដើម្បីបង្ការ និង ទប់ស្កាត់ ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬ ផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ។

៤- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។

៥- ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់ ។

៦- ធ្វើអធិការកិច្ចលើកិច្ចការពាក់ព័ន្ធសុំកូនអន្តរប្រទេស ។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ ។

៧- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨.-**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានរដ្ឋបាលសុំកូនអន្តរប្រទេសជាសេនាធិការ ។

មន្ត្រីបម្រើការក្នុងរដ្ឋបាលសុំកូនអន្តរប្រទេសរួមមាន អ្នកធ្វើការងារផ្នែកសង្គមកិច្ច អ្នកចិត្តសាស្ត្រ និង អ្នកជំនាញខាងច្បាប់បានទទួលការបណ្តុះបណ្តាលពិសេស ស្តីពីសុំកូន

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ៩.-**

រដ្ឋបាលសុំកូនអន្តរប្រទេស មានតួនាទី និង ភារកិច្ចដូចតទៅ :

១-រៀបចំ ថែរក្សាបញ្ជីសម្គាល់ និង សំណុំឯកសាររបស់កុមារដែលមានលក្ខណៈសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

២-វាយតម្លៃស្ថានភាពកុមារទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីសម្គាល់ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និង ធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ ។

៣-ប្រឹងប្រែងរកដំណោះស្រាយឱ្យអស់លទ្ធភាពក្នុងប្រទេស ក្នុងការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬ នៅជាមួយអ្នកអាណាព្យាបាល មុននឹងដំណើរការសុំកូនអន្តរប្រទេស ។

៤-ទទួលពិនិត្យ និង ចាត់ការពាក្យសុំកូនអន្តរប្រទេស និង ឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់អ្នកសុំ ។

៥-ផ្គូផ្គងអ្នកសុំជាមួយកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស និង ផ្តល់មតិយោបល់លើករណីសុំកូនអន្តរប្រទេស ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៦-ផ្តល់ដំណឹងទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល អំពីនីតិវិធីសុំកូន និង ការវិវឌ្ឍនៃករណីសុំកូន ។

៧-សម្របសម្រួលការប្រគល់កុមារទៅឱ្យអ្នកសុំ និង រៀបចំឯកសារ ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ ។

៨-ផ្តល់ ឬ សម្របសម្រួលការផ្តល់សេវាក្រោយសុំកូនសមស្របដល់កុមារ ... និង គ្រួសារបង្កើតតាមការចាំបាច់ ។

៩-ផ្តល់មតិយោបល់ទាក់ទងនឹងការផ្តល់ការអនុញ្ញាតឱ្យទីភ្នាក់ងារសុំកូនអន្តរ-

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

9/384

ប្រទេស ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ឬ ការដកហូតការអនុញ្ញាត ជូនអាជ្ញាធរកណ្តាល ទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ។

១០- បំពេញភារកិច្ចផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសតាមការចាំបាច់ ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញា របស់ព្រះរាជាណាចក្រកម្ពុជា និង តាមការប្រគល់អំណាចរបស់អាជ្ញាធរកណ្តាល ។

## ជំពូកទី ៤

## លក្ខខណ្ឌសម្រាប់សុំកូន

### ផ្នែកទី ១

### កូនសុំ

**មាត្រា១០.–**

កុមារដែលអាចជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌទាំងអស់ ដូចខាងក្រោម :

១- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-កុមារមានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអាចអនុញ្ញាតបានដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។ ក្នុងករណី កុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

៣- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៤- កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែលស្ថិតនៅក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត ។

៥- កុមារនោះត្រូវបានប្រកាសថាអាចសុំជាកូនចិញ្ចឹមបាន ដោយអនុលោមតាមមាត្រា ១៧ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

10/35 Ksl

ក្នុងករណីសុំកូនដោយសាច់ញាតិ សុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលរស់នៅក្នុង ឬ ក្រៅមណ្ឌលកុមារកំព្រា ។

**មាត្រា ១១.-**

ករណីមានកុមារត្រូវបានរកឃើញ និង បញ្ជូនមកមណ្ឌលកុមារកំព្រា ហើយរកមិនឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានមណ្ឌលកុមារកំព្រា ត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត អំពីវត្តមានរបស់កុមារ ដែលបានចូលមកស្នាក់នៅក្នុងមណ្ឌល យ៉ាងយូរបំផុតរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីពេលដែលកុមារមកដល់មណ្ឌល ។ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជី ស្តីពីកុមារដែលត្រូវបានរាយការណ៍ថាត្រូវបានគេបោះបង់ចោល ។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាលសម្រាប់អនីតិជនមុន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈទៅតាមលទ្ធភាពដូចជា ទូរទស្សន៍ វិទ្យុ ឬ សារព័ត៌មាន និង រូបភាពរបស់កុមារនោះ ។ ជនណាដែលអះអាងថាខ្លួនជាឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ជននោះត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទងជាសាច់ញាតិ ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជនជាមួយកុមារស្របទៅតាមបទប្បញ្ញត្តិជាធរមាន ។

បន្ទាប់ពីការផ្សព្វផ្សាយដំណឹងរយៈពេល ៥ (ប្រាំ) ខែ នៅតែរកមិនឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាល សម្រាប់អនីតិជនមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការខិតខំស្រាវជ្រាវនេះ ហើយត្រូវផ្ញើមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបោះបង់ចោល ។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ រហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត គឺជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ បញ្ញត្តិស្តីពីអាណាព្យាបាលសម្រាប់អនីតិជនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ត្រូវយកអនុវត្តផងដែរ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន គ្មានសិទ្ធិផ្តល់ការយល់ព្រមលើសុំកូនទេ ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលត្រូវបោះបង់ចោល ។

ករណីកុមារដែលត្រូវបោះបង់ចោលពុំអាចរកឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយពុំមានសំបុត្រអត្រានុកូលដ្ឋានកំណើត ប្រធានមណ្ឌលកុមារកំព្រា ត្រូវសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតកុមារនោះ ទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

**មាត្រា ១២.-**

ប្រសិនបើ អ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ចូលឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលអ្នកអនុវត្តអំណាចមេបារបស់ខ្លួន បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ១៣.-**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើត ហើយបើមិនអាចធ្វើទៅបានទេ ត្រូវទុកដាក់កុមារតាមរយៈសុំកូនក្នុងស្រុកនៅក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងពិនិត្យរកលក្ខណសម្បត្តិសុំកូនអន្តរប្រទេស

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ព្រះរាជវាំង

ក្រសួងព្រះបរមរាជវាំង

35

ksl

នៅពេលវិធានការនានា ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបានបញ្ចប់ កុមារអាចនឹងត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីស្តីពីកុមារដែលកំណត់ថាមានលក្ខណ-សម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

## ផ្នែកទី ២
## ការយល់ព្រមលើសុំកូន

**មាត្រា ១៤.-**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចខាងក្រោមនេះ :

ក- ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និង ម្តាយ ការយល់ព្រមត្រូវផ្តល់ដោយឪពុក និង ម្តាយរបស់កុមារនោះ ។

ខ- ក្នុងករណីដែលឪពុក ឬ ម្តាយណាមួយរបស់កុមារបានស្លាប់ ឬ ស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុក ឬ ម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់ ។

គ- ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬ ស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ ។

**មាត្រា ១៥.-**

ការយល់ព្រមខាងលើត្រូវផ្តល់ឱ្យដោយសេរី និង ច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬ ការបញ្ឆុះបញ្ឆូលតាមរយៈការផ្តល់ ឬ ការសន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយឡើយ និង ដោយបានដឹងអំពីផលវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១៦.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិន មុននឹងផ្តល់ការយល់ព្រម ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ ដល់អ្នកដែលត្រូវផ្តល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រម ការបញ្ចប់នូវបុត្តភាព ព្រមទាំងការបញ្ចប់សិទ្ធិនិងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ត្រូវប្រាប់អំពីបែបបទ និង រយៈពេលបញ្ឈប់ការយល់ព្រមដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍របស់ខ្លួនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

ទោះក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

មេឃុំ ឬ ចៅសង្កាត់ និងភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធានាថា រាល់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាការយល់ព្រមដែលគោរពទៅតាមខ្លឹមសារនៃមាត្រា ១៥ នៃច្បាប់នេះ ។

មេឃុំ ឬ ចៅសង្កាត់ ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមនេះ ក្រោយពីបានពិនិត្យថា ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និង បានប្រាប់យ៉ាងត្រឹមត្រូវអំពីអានុភាពនៃការយល់ព្រមនេះ ។

**មាត្រា ១៧.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មុនពេលសេចក្តីសម្រេចរបស់តុលាការស្តីពីការសុំកូនធម៌ជាស្ថាពរ ។ ការបញ្ឈប់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន ។ មេឃុំ ឬ ចៅសង្កាត់ខាង

លំនៅឋានរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ និង ត្រូវប្រគល់កំណត់ហេតុចម្លងដែលមានសេចក្តីបញ្ជាក់នៅលើកំណត់ហេតុនោះ ទៅឱ្យឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

**មាត្រា ១៨.-**

នីតិវិធីការសុំកូនអាចប្រព្រឹត្តទៅបាន លុះត្រាតែផុតកំណត់ពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

**មាត្រា ១៩.-**

ករណីឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចប្តឹងសុំឱ្យតុលាការប្រកាសដកហូតអំណាចមេបាពីឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ បញ្ឈប់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬ ការបញ្ឈប់ការយល់ព្រមនេះ ធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់កុមារ ឬ បណ្តាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារ ។ ពាក្យបណ្តឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ បដិសេធ ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ។

**មាត្រា ២០.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ដែលយល់ថា ការយល់ព្រមរបស់ខ្លួនបានមកពីការបង្ហាញឆន្ទៈដែលមានវិការៈ ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ ឬ លុបចោលការយល់ព្រមរបស់ខ្លួនបាន រហូតដល់មុនដីកាសម្រេចរបស់តុលាការលើសុំកូនចូល

## ផ្នែកទី ៣
## អ្នកសុំ

**មាត្រា ២១.-**

អ្នកសុំដែលអាចអនុញ្ញាតឱ្យសុំកុមារយកទៅចិញ្ចឹមជាកូនបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌ ដូចតទៅ :

១-អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី ៣០(សាមសិប)ឆ្នាំ និង មានអាយុលើសកូនសុំយ៉ាងតិច ២២(ម្ភៃពីរ)ឆ្នាំ និង យ៉ាងច្រើនបំផុត ៤៥(សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន ។

២-ក្នុងករណីដែលអ្នកសុំមិនបានបំពេញតាមចំណុច ១ ខាងលើ ហើយក្នុងករណីសុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឱ្យ បាន ក្នុងស្ថានភាពដូចតទៅ :

ក-អ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬ

ខ-អ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត ឬ

គ-អ្នកសុំ សុំកុមារដែលត្រូវការការថែទាំពិសេស ឬ ស្ថានភាពផ្សេងទៀត ដែលបម្រើឧត្តមប្រយោជន៍របស់កុមារ ។

៣-ក្នុងករណីអ្នកសុំមានប្តី ឬ ប្រពន្ធ ការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ទ្ធណាម្ខាង សុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

៤-ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និង ច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និង អនុញ្ញាតនូវបុត្តភាពនៃសុំកូនពេញលេញ ។

៥-ប្រទេសនៃសញ្ជាតិ ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា ។

៦-អ្នកសុំត្រូវមានលក្ខណសម្បត្តិ និង លក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របទៅតាមច្បាប់ប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៧-អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬ កំពុងត្រូវបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមារយាទ ឬ ការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬ ក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ ។

៨-អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្រប និង ការគាំទ្រចាំបាច់ដល់កូនសុំ ។

៩-អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកសុំកូនគ្មានកូន ឬ មានកូនតែម្នាក់នៅក្នុងបន្ទុក ។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន ។

## ជំពូកទី ៥

## នីតិវិធីសុំកូន

### ផ្នែកទី ១

### នីតិវិធីរដ្ឋបាល

**មាត្រា ២២.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមាន ព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹម សាវតារជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពរបស់កុមារ និង ប្រវត្តិសុខភាពគ្រួសាររបស់កុមារ និង សេចក្តីត្រូវការជាពិសេសណាមួយរបស់កុមារ ។

ក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អតីតជនរបស់កុមារត្រូវបានធ្វើរួចហើយ ។

រដ្ឋបាលសុំកូនអន្តរប្រទេសក៏ត្រូវធានាផងដែរថា រាល់ការយល់ព្រមចាំបាច់ទាំងឡាយត្រូវបានធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ ។

ROYAUME du CAMBODGE * LE MINISTERE du PALAIS ROYAL *

17/3/..

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាប់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និង/ឬ ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ ។

**មាត្រា ២៣.-**

អ្នកសុំត្រូវដាក់ពាក្យសុំកូនទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាដោយភ្ជាប់មកជាមួយនូវឯកសាររួមមាន :

១-ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណសម្បត្តិ និង មានភាពសមស្រប សម្រាប់សុំកូនដោយផ្អែកលើការវាយតម្លៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារ បរិយាកាសសង្គម មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុករាប់រងចំពោះសុំកូនអន្តរប្រទេស ។

២-ព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

៣-ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំ ដែលក្នុងនោះរួមមានឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន ។

៤-ព័ត៌មានទាក់ទងនឹងលក្ខណសម្បត្តិផ្សេងៗរបស់កុមារ ដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន ។

៥-ភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយ កូនសុំនោះត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល ។

ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំង ដែលមានការបញ្ជាក់ត្រឹមត្រូវ ។

មាត្រា ២៤.–

ពាក្យសុំដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ត្រូវបញ្ជូនមកក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ ។ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្តល់យោបល់ និង ត្រូវបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំ ។ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ ដោយបញ្ជាក់ថា ខ្លួនបានទទួលពាក្យសុំកូន ។

មាត្រា ២៥.–

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និង វិភាគទាននានា សម្រាប់ជួយឧបត្ថម្ភដល់ជីវីសនានានៃការថែទាំជិនួស និង ការជួយឧបត្ថម្ភទូទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និង កម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹង រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ក្រៅពីនេះ មិនត្រូវយកថ្លៃសោហ៊ុយសុំកូនពីអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូន ។ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនបង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬ ទៅតាមសោហ៊ុយសុំកូនមួយៗដែលនឹងត្រូវបញ្ជូនទៅឱ្យមណ្ឌលកុមារកំព្រាណាមួយ ឬ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនធ្វើការផ្តល់សោហ៊ុយ អំណោយ ឬ ការទូទាត់ ទោះក្នុងរូបភាពណាក៏ដោយឱ្យ ទៅមណ្ឌលកុមារកំព្រាដែលកុមារនៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬ ទៅឱ្យបុគ្គលិក នាយក ឬ សមាជិកនៃគណៈគ្រប់គ្រងទោះជាដោយផ្ទាល់ ឬ ដោយប្រយោលក្តី ។

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

9/35

**មាត្រា ២៦.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតសុំកូន ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។ ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ហើយ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវបញ្ជាក់ថា អ្នកសុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នេះហើយ ។

ក្នុងករណីដែលសំណុំលិខិតដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស មិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលឯកសារដែលនៅខ្វះ ឬ កែតម្រូវរួច។

ក្នុងករណីអ្នកសុំខកខានមិនបានផ្តល់ឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃរដ្ឋបាលសុំកូនអន្តរប្រទេសបានជូនដំណឹងអំពីឯកសារដែលមិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ នោះពាក្យសុំកូនអន្តរប្រទេសត្រូវទុកជាមោឃៈ ។

ក្នុងករណីបដិសេធពាក្យសុំ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវមានបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ ។

**មាត្រា ២៧.-**

ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវ ហើយអ្នកសុំបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់នេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារទាំងឡាយដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន និងត្រូវផ្ដល់ជូនអំពីលក្ខណសម្បត្តិរបស់អ្នកសុំណាដែលត្រូវគ្នាល្អបំផុតនឹងលក្ខណសម្បត្តិរបស់កុមារ ។

ក្នុងការផ្តល់ដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិចារណាឱ្យបានសមស្របទៅលើអត្ថប្រយោជន៍នៃការបន្តឱ្យមានការបីបាច់ ថែរក្សាកុមារ ដូចពេលកន្លងមក ព្រមទាំងពិចារណាទៅលើសាវតារសង្គម ជាតិពន្ធុ សាសនា និងវប្បធម៌របស់កុមារ ។

**មាត្រា ២៨.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលត្រូវបានផ្តល់ រួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការយល់ព្រមចាំបាច់នានា ត្រូវបានទទួលរួចហើយ និងមូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារជាមួយអ្នកសុំនោះទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីពិនិត្យនិងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពីអត្តសញ្ញាណឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារឡើយ លើកលែងតែករណីសុំកូនដោយសាច់ញាតិ ។

**មាត្រា ២៩.-**

អ្នកសុំត្រូវឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមសុំកុមារ ដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្តល់ឱ្យតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនបានឆ្លើយតបមករដ្ឋបាលសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុបសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្ញើសំណុំឯកសាររបស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសអាចចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ហើយរដ្ឋបាលសុំកូនអន្តរប្រទេសអាចផ្តល់កុមារនោះឱ្យទៅអ្នកសុំផ្សេងទៀតបាន ។ ប្រាក់ចំណាយ សោហ៊ុយ និង វិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបានបង្វិលជូនវិញឡើយ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

2/35

ក្នុងករណីអ្នកសុំបានឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្តល់ឱ្យខ្លួននៅលើកទីមួយទេ អ្នកសុំនោះអាចស្នើសុំឱ្យរដ្ឋបាលសុំកូនអន្តរប្រទេសផ្តល់កុមារជាលើកទីពីរបាន ។ ការផ្តល់នេះមិនត្រូវអនុញ្ញាតឱ្យធ្វើជាលើកទីបីឡើយ ។

ចំពោះអ្នកសុំដែលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ អ្នកសុំនោះអាចដាក់ពាក្យសុំកូនសាជាថ្មីស្របតាមនីតិវិធីនៃច្បាប់នេះ ។ ក្នុងការសម្រេចអំពីការសុំឱ្យមានការផ្តល់សាជាថ្មី ឬ ការទទួលពាក្យសុំកូនសាជាថ្មី រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬ ឆ្លើយតបថា មិនមានបំណងសុំកុមារដែលបានផ្តល់ពីលើកមុននាពេលកន្លងមក ។

**មាត្រា ៣០.-**

បន្ទាប់ពីអ្នកសុំ បានបញ្ជាក់ការយល់ព្រមរបស់ខ្លួនស្របតាមបទប្បញ្ញត្តិក្នុងមាត្រា ២៩ នៃច្បាប់នេះ ហើយអាជ្ញាធរកណ្តាលនៃប្រទេសទទួល បានយល់ព្រមលើការសម្រេចនេះ រដ្ឋបាលសុំកូនអន្តរប្រទេសតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ត្រូវរៀបចំឱ្យមានការជួបគ្នារវាងអ្នកសុំ និង កុមារដែលត្រូវបានផ្តល់រួចហើយ ។

ការជួបគ្នានេះត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទមួយសមស្របសម្រាប់អ្នកសុំ និង រដ្ឋបាលសុំកូនអន្តរប្រទេស និង ត្រូវមានវត្តមានមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង ។ ការជួបគ្នានេះ ត្រូវធ្វើក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ ។

មុនការជួបគ្នារវាងអ្នកសុំ និង កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើសម្ភាសន៍អ្នកសុំ និង ធានាថា អ្នកសុំ និង កុមារត្រូវបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មាន ការផ្លាស់ប្តូររូបថត និង វិធានការចាំបាច់ផ្សេងៗទៀត ដើម្បីការជួបគ្នានេះ ។

ករណីមានសហព័ទ្ធ បើសហព័ទ្ធណាម្ខាងមិនអាចមកបាន សហព័ទ្ធនោះត្រូវធ្វើលិខិតប្រគល់សិទ្ធិឱ្យទៅសហព័ទ្ធម្ខាងទៀត ធ្វើជាអ្នកតំណាងរបស់ខ្លួន ដើម្បីធ្វើសកម្មភាពក្នុងការសុំកូននោះ ។ លិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល ។

2/35

Kol

ក្នុងករណីអ្នកសុំមិនមកក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ដោយគ្មានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឱ្យបានដឹងអំពីអានុភាពដែលកើតចេញពីសុំកូននេះ ហើយត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវយល់ដឹងឱ្យបានច្បាស់ អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធដល់សុំកូន ក្នុងនោះមានជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណាដោយផ្អែកទៅតាមវ័យ និង កម្រិតយល់ដឹងរបស់កុមារ ។ សំអាងស្តីពីការយល់ព្រមរបស់កុមារត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍ និង ការជួបគ្នាខាងលើនេះ ។

**មាត្រា ៣១.-**

បទប្បញ្ញត្តិ ដែលមានចែងក្នុងជំពូកនេះត្រូវយកមកអនុវត្តផងដែរចំពោះសុំកូនដោយសាច់ញាតិ ។

**មាត្រា ៣២.-**

ក្នុងករណីរដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថា អ្នកសុំ និង កុមារបំពេញបាននូវលក្ខណាវិនិច្ឆ័យ និង លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយសុំកូននេះពិតជាបានឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការជួបគ្នារវាងអ្នកសុំ និង កុមារ ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវដាក់សំណុំលិខិតទាំងនេះ ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការពិនិត្យ និង ផ្តល់អនុសាសន៍លើដំណើរការសុំកូន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៣៣.—**

ក្រោយពីទទួលអនុសាសន៍លើដំណើរការសុំកូនពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដាក់ពាក្យសុំកូនដែលបានផ្តល់ងរួច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសុំដីកាសម្រេចសុំកូន ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជូនពាក្យសុំកូនទៅសាលាដំបូងរាជធានីភ្នំពេញដោយភ្ជាប់មកជាមួយនូវសំណុំឯកសាររបស់កុមារ និង អ្នកសុំ ព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទទទួលពាក្យសុំ ។ ឯកសារចាំបាច់ទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និង មានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស ។

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

## ផ្នែកទី ២
## នីតិវិធីតុលាការ

**មាត្រា ៣៤.—**

សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ។

តុលាការដែលមានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ត្រូវយកបទប្បញ្ញត្តិស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងមកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស លើកលែងតែមានបទប្បញ្ញត្តិពិសេសដូចមានចែងនៅក្នុងច្បាប់នេះ ។

**មាត្រា ៣៥.—**

អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០ (មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យសុំ ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និង សកម្មភាពខាងនីតិវិធីផ្សេងៗទៀត

ដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស ។ តុលាការត្រូវបង្គាប់ឱ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន ។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពី ១.០០០.០០០ (មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និង បង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន ។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ ។

**មាត្រា ៣៦.-**

ជាគោលការណ៍ សំណុំឯកសារ និង របាយការណ៍ដែលដាក់ជូនតុលាការដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវសន្មតជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិ សុំកូនរបស់កុមារ និង ភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំលើកលែងតែមានភស្តុតាងផ្ទុយមកបញ្ជាក់ ។

ក្នុងករណីចាំបាច់ តុលាការអាចបង្គាប់ឱ្យអ្នកតំណាងរដ្ឋបាលសុំកូនអន្តរប្រទេសមកបំភ្លឺបន្ថែមអំពីលទ្ធផលនៃការស្រាវជ្រាវ និង អនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសរួមទាំងឯកសារ របាយការណ៍ និង ភស្តុតាងជាឯកសារពាក់ព័ន្ធដែលគាំទ្រលទ្ធផលនៃការស្រាវជ្រាវខាងលើ ។

**មាត្រា ៣៧.-**

តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថា :

ក- លក្ខណវិនិច្ឆ័យ ឬ លក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ ។

ខ- ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងផ្តល់ការយល់ព្រម ។

គ- ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារផ្នែកទី ២ ជំពូកទី ៤ នៃច្បាប់នេះ ។

ឃ- មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល យល់ព្រមលើការទុកដាក់កុមារ ។

ច- កុមារនឹងត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេស

ឆ- សុំកូនអន្តរប្រទេសនេះពិតជាឧត្តមប្រយោជន៍របស់កុមារ ។

25/85

Kol

**មាត្រា ៣៨.-**

តុលាការសម្រេចសេចក្តីអំពីរឿងក្តីដែលទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

ក្នុងករណីមានភាពចាំបាច់ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកសុំ ឬ អ្នកតំណាង ឬ អ្នកមានអំណាចមេបាម្ខាង ឬ ទាំងពីរ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសពាក់ព័ន្ធ និងសាក្សីផ្សេងទៀត ដើម្បីផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ ។

**មាត្រា ៣៩.-**

តុលាការត្រូវលើកយកសំណុំរឿងសុំកូនអន្តរប្រទេសមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំកូន ។ តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំ និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ ដែលបានកំណត់នៅក្នុងមាត្រា ៤០ នៃច្បាប់នេះ ។ ក្នុងករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពររហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ ។

**មាត្រា ៤០.-**

បុគ្គលដែលមានសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ចំពោះដីកាសម្រេចនោះបាន ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលខ្លួនទទួលបានការជូនដំណឹងអំពីដីកាសម្រេច ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ)

ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេច ។

អំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដែលកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើមិនអាចពន្យារបានឡើយ ។

សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្តឹងជំទាស់នោះមកវិនិច្ឆ័យ និង ចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងជំទាស់ ។

ដីកាសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ ។

## ជំពូកទី ៦
## អានុភាពនៃស៊ុំកូន

**មាត្រា ៤១.-**

ស៊ុំកូនអន្តរប្រទេសត្រូវតែជាស៊ុំកូនពេញលេញ ។ ស៊ុំកូនអន្តរប្រទេសមានអានុភាពបង្កើតនូវទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយ និង កូនជាអចិន្ត្រៃយ៍ ដោយផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ហើយវាបញ្ចប់ញាតិភាពរវាងកុមារ និង ឪពុកម្តាយបង្កើតរបស់ខ្លួន ។

**មាត្រា ៤២.-**

អានុភាពផ្សេងទៀតនៃស៊ុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬ ប្រសិនបើគ្មានច្បាប់រួមមួយទេ ត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

## ជំពូកទី ៧
## ការជូនដំណឹងពីចំណាត់ការ និង នីតិវិធី
## បន្ទាប់ពីបញ្ចប់ដំណើរការស៊ុំកូនអន្តរប្រទេស

**មាត្រា ៤៣.-**

[illegible] ជាសមាជិក [illegible] ស៊ុំកូនអន្តរប្រទេស ត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីស៊ុំកូន វិធានការ ដែលអាជ្ញាធរមានសមត្ថកិច្ចបានចាត់ការ និង ការវិវត្តនៃការសុំកូននៅគ្រប់

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ដំណាក់កាលរបស់នីតិវិធីសុំកូនឱ្យបានទៀងទាត់ ទៅអ្នកសុំតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាត ។

**មាត្រា ៤៤.–**

ក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវជូនដំណឹងទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អំពីដីកាសម្រេចនេះ ។

នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ ដោយអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការ ទាក់ទងនឹងសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចេញលិខិតបញ្ជាក់អនុលោមតាមមាត្រា ២៣ នៃអនុសញ្ញានេះ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំពិធីប្រគល់កុមារ និង លិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំ និង ផ្តល់នូវលិខិតឆ្លងដែន ទិដ្ឋាការ និង ឯកសារចាំបាច់នានា ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួល ត្រូវអមដំណើរដោយអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធានាថាការផ្ទេរកុមារទៅកាន់ប្រទេសទទួល ប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរដល់សេចក្តីត្រូវការនានារបស់កុមារ ។

**មាត្រា ៤៥.–**

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីផ្តល់ ឬ សម្របសម្រួលសេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារចិញ្ចឹម និង គ្រួសារបង្កើតតាមការចាំបាច់ ។

ក្រោយពីកុមារត្រូវបានទទួលការអនុញ្ញាតឱ្យធ្វើជាកូន ឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារមករដ្ឋបាលសុំកូនអន្តរប្រទេសជារៀងរាល់ ៦ (ប្រាំមួយ) ខែម្តង ក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ១ ឆ្នាំម្តង រហូតដល់កុមារអាយុ ១៨ ឆ្នាំ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ក្រសួងព្រះបរមរាជវាំង

ឪពុកម្តាយចិញ្ចឹមត្រូវផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ឬ ប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប ។

**មាត្រា ៤៦.-**

រដ្ឋបាលសុំកូនអន្តរប្រទេស និង សាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាទុកសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ឆ្នាំ គិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ ។

សំណុំឯកសារ និង កំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ទោះជារក្សាទុកនៅតុលាការ រដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និង អ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាការសម្ងាត់ ។ ក៏ប៉ុន្តែសំណុំឯកសារនិងកំណត់ហេតុ ឬ ព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារ និង កំណត់ហេតុទាំងនោះអាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬ ការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានតម្រូវការទាក់ទងនឹងករណី ឬ នីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬ កាលៈទេសៈពិសេសផ្សេងទៀត ។

ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំ ក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ ។ កូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អំពីផលវិបាកនៃការដឹងអត្តសញ្ញាណរបស់ខ្លួន អាចត្រូវបានអនុញ្ញាតឱ្យមើលសំណុំលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះជាឧត្តមប្រយោជន៍របស់កូនសុំ ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និង កំណត់ហេតុទាក់ទងនឹងអត្តសញ្ញាណខ្លួន ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា កូនសុំទទួលបានការពិគ្រោះយោបល់សមស្របមុននឹងមើលព័ត៌មាននៅក្នុងសំណុំលិខិតរបស់ខ្លួន ។

29/55

## ជំពូកទី ៨
## ការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារ

**មាត្រា ៤៧.-**

មានតែទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ស្របតាមមាត្រាជាបន្តបន្ទាប់ដូចខាងក្រោមប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

ចំនួនទីភ្នាក់ងារមកពីប្រទេសទទួលនីមួយៗ ដែលអនុញ្ញាតឱ្យផ្តល់សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវកំណត់ដោយកិច្ចព្រមព្រៀងរួមគ្នាមួយរវាងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និង អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ។

**មាត្រា ៤៨.-**

ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានលក្ខណសម្បត្តិដូចតទៅ :

១- មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ។

២- មានទិសដៅមិនស្វែងរកផលចំណេញ និង បានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ ។

៣- មានអ្នកដឹកនាំនិងមានបុគ្គលិកដែលមានសមត្ថភាពប្រកបដោយគុណធម៌ និង សីលធម៌ ព្រមទាំងបានទទួលការបណ្តុះបណ្តាល និង មានបទពិសោធន៍ធ្វើការងារក្នុងវិស័យសុំកូនអន្តរប្រទេស ។

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវបានអនុញ្ញាតឱ្យបើក ឬ យកមណ្ឌលកុមារកំព្រា ជាប្រភពដើម្បីផ្គត់ផ្គង់ទារក និង កុមារកំព្រា នៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

**មាត្រា ៤៩.-**

ទីភ្នាក់ងារនីមួយៗត្រូវបានចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមាន របស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត ទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ មុនពេលដាក់ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេស ។ ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវចុះកិច្ចសន្យាស្តីពីប្រតិបត្តិការសុំកូនអន្តរប្រទេស និង បំពេញបែបបទផ្សេងៗទៀត តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ៥០.-**

ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅព្រះរាជាណាចក្រកម្ពុជា ដែលដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម :

១- ពាក្យសុំការអនុញ្ញាតដោយមានការយល់ព្រម និង ទទួលស្គាល់ពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

២- ឯកសារសង្ខេបអំពីប្រវត្តិ និង សកម្មភាពរបស់ទីភ្នាក់ងារ ។

៣- ច្បាប់ចម្លងដែលមានបញ្ជាក់ត្រឹមត្រូវអំពីការអនុញ្ញាតឱ្យបើកទីភ្នាក់ងារពីប្រទេសទទួលរបស់ខ្លួន ចំពោះទីភ្នាក់ងារអន្តរជាតិ ។

៤- ច្បាប់ចម្លងលិខិតចុះបញ្ជីដែលមានបញ្ជាក់ត្រឹមត្រូវដូចមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ។

៥- លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ ។

៦- ជីវប្រវត្តិសង្ខេបនិងរូបថតរបស់សមាជិកក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រង ។

៧- ជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលបានទទួលការអនុញ្ញាតឱ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារចំពោះកិច្ចការសុំកូនអន្តរប្រទេស ។ អ្នកតំណាងទាំងនេះមិនត្រូវឱ្យលើសពីពីរនាក់ និង មិនមែនជានាយក នាយករង ឬ បុគ្គលិកនៃមណ្ឌលកុមារកំព្រាណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

៨- ឯកសារភស្តុតាងនានាដែលបញ្ជាក់ថាអ្នកតំណាងដូចមានចែងក្នុងចំណុចទី ៧ ខាងលើ គ្មានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសនៅប្រទេសដើមរបស់ខ្លួន និង នៅប្រទេសចុងក្រោយដែលខ្លួនរស់នៅ ក្នុងករណីប្រទេសខុសគ្នា ។

៩- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសុំកូនអន្តរ-ប្រទេស រវាងព្រះរាជាណាចក្រកម្ពុជា និង ប្រទេសរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្នុងករណីដែលប្រទេសនោះមិនមែនជារដ្ឋភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសទេ ។

១០- របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មឯករាជ្យ និង កិច្ចព្រមព្រៀងផ្តល់ជំនួយមនុស្សធម៌ ឬ ការជួយឧបត្ថម្ភដល់កុមារកំព្រានានា នៅក្នុងព្រះរាជាណា-ចក្រកម្ពុជា ។

១១- តម្រូវការផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចយល់ថាចាំបាច់ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ ដូចមានចែងនៅក្នុងនីតិវិធីទាក់ទងនឹងការផ្តល់ការអនុញ្ញាត ។

ច្បាប់ចម្លងចំនួនមួយច្បាប់នៃពាក្យសុំ និង សំណុំលិខិតសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារ ត្រូវផ្ញើជូនស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួល ដែលទីភ្នាក់ងារធ្វើប្រតិបត្តិការនៅទីនោះ ។

**មាត្រា ៥១.–**

ក្នុងកំឡុងពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំការអនុ-ញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅទីភ្នាក់ងារវិញអំពីការសម្រេចជាផ្លូវការរបស់ខ្លួន ។ ក្នុងករណីមានការបដិសេធ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ។

**មាត្រា ៥២.–**

មានតែអ្នកតំណាងដែលមានឈ្មោះក្នុងសំណុំឯកសារពាក្យសុំការអនុញ្ញាតតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើជាអ្នកតំណាងទីភ្នាក់ងារនៅក្នុងដំណើរការសុំកូនអន្តរប្រទេស ។ ក្នុងករណីអ្នកតំណាងដែលបានទទួលការអនុញ្ញាត ត្រូវជំនួសដោយអ្នកផ្សេងនោះ ទីភ្នាក់

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL

ងារត្រូវដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការអនុញ្ញាតជាថ្មីឡើងវិញ។

**មាត្រា ៥៣.-**

ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ត្រូវផ្តល់ឱ្យសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ ហើយអាចអនុញ្ញាតឱ្យបន្តទៀតបាន ដោយទីភ្នាក់ងារត្រូវដាក់ពាក្យសុំសាជាថ្មី និងត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៤៨ មាត្រា ៤៩ និង មាត្រា ៥០ នៃច្បាប់នេះ ដរាបណាសេវារបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅតែចាំបាច់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

**មាត្រា ៥៤.-**

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចព្យួរ ឬ ដកហូតការទទួលស្គាល់ ឬ បដិសេធការទទួលស្គាល់ ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឱ្យឃើញថាទីភ្នាក់ងារសុំកូនអន្តរប្រទេស ជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចតទៅ :

១- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឱ្យឪពុកម្តាយ ឬ ឪពុក ឬ ម្តាយបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើត ដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស ។

២- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុកម្តាយ ឬឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត ។

៣- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

32/35

៤- អំពើក្លែងបន្លំ ឬ សមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

៥- អំពើរៀបចំឱ្យមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបន្លំតបន្លំ ការគំរាមកំហែង ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ សន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយ ។

៦- ការបញ្ចេញសំណុំឯកសារ និង កំណត់ហេតុទាំងអស់ ឬ មួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬ តុលាការមានសមត្ថកិច្ច ។

៧- ការបង្ខាប់ ឬ ការទទួលដោយផ្ទាល់ ឬ ដោយប្រយោល នូវថ្លៃប្រាក់កាស ទំនិញ ឬ សេវា ដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន ។

៨- ការផ្តល់ប្រាក់កាស ទំនិញ ឬ សេវាទៅឱ្យមន្ត្រី ឬ អ្នកតំណាងណាមួយនៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្តាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ឬ មន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យផ្តល់នូវសិទ្ធិជាអាទិភាពនៅក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ ។

៩- ការផ្សាយពាណិជ្ជកម្ម ឬ ការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬ រូបថតរបស់កុមារណាមួយដែលជាកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយឱ្យដាក់ពាក្យសុំកូន ។

១០- ការតែងតាំង ឬ ចាត់តាំងអ្នកតំណាងណាមួយដោយមិនមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១១- ការចូលរួមក្នុងការរៀបចំការផ្គូផ្គង ឬ ការទាក់ទងគ្នារវាងអ្នកសុំ និង ឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារក្នុង គោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ ។

១២- ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមានៃការធានាសិទ្ធិចំពោះកុមារ និង បទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៥៥.–

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនអនុវត្តតាមកថាខណ្ឌទី ១ មាត្រា ៤៧ ឬ កថាខណ្ឌទី ២ មាត្រា ៤៨ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ការដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ប្រាក់ពិន័យអន្តរការណ៍នេះត្រូវបង់ចូលទៅក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ ។

ក្នុងករណីទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៥៦.–**

បទល្មើសពាក់ពន្ធ័ទៅនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៥៧.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥៨.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

នស/រកម/១២០៩/០២៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

លេខ ១០៥៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ឆ្នាំ២០០៩